# គិហិបដិបត្តិ ពិស្តារ

ដកស្រង់ រៀបរៀងដោយ

**សាមណេរ ប៉ែន វិបុល**

ជាសមណសិស្សពុទ្ធិកវិទ្យាល័យព្រៃវែង

**បោះពុម្ពលើកទី ២**

**ចំនួន ៥១00 ក្បាល**

**ព.ស. ២៥៤៩ គ.ស. ២00៦**

## អារម្ភកថា

ខ្ញុំបានដកស្រង់និងរៀបរៀងនូវសៀវភៅនេះ ឡើងដោយមានគោលគំនិតទាំងឡាយដូចតទៅ :

-ដោយសំណូមពររបស់ពុទ្ធបរិស័ទទាំងឡាយ មានញោមប្រុសស្រីរបស់ខ្ញុំព្រះករុណាអាត្មាជាដើមចង់បានសៀវភៅ គិហិបដិបត្តិ ពិស្តារនេះ ដើម្បីសិក្សារៀនសូត្រ ។

-ទុកជាធម្មទានក្នុងឱកាសបុណ្យដង្ហែគម្ពីរព្រះត្រៃបិដក និង បព្វ-ជ្ជាឧបសម្បទា ដែលប្រព្រឹត្តទៅ នៅថ្ងៃទី 0២ ខែ មីនា ឆ្នាំ ២00៦ នេះ ។

-ដើម្បីជាការរួមចំណែកក្នុងការលើកស្ទួយដល់វិស័យអប់រំនៅក្នុងសំណាក់ពុទ្ធសាសនា ។

-ជាការផ្សព្វផ្សាយ និង ពង្រឹងនូវព្រះពុទ្ធសាសនា ឱ្យបានស្ថិតស្ថេរគ្រប់ ៥000 ព្រះវស្សា ។

គោលបំណងទាំងអស់នេះហើយដែលនាំឱ្យកកើតជាសៀវភៅនេះឡើង ។ ខ្ញុំអ្នករៀបរៀងជឿថាសៀវភៅនេះនឹងមានការខុសឆ្គងដោយអចេតនា ទៅលើចំណុចណាមួយពុំខានឡើយ ហើយខ្ញុំក៏សង្ឃឹមថាលោកអ្នកវិញ្ញូជនទាំងអស់ នឹងអភ័យទោសហើយជួយកែតំរូវមិនខានឡើយ ។ ត្បិតអីបូរាណសុភាសិតបានពោលថា " *រាល់ការធ្វើទាំងឡាយរាំងអីនឹង*

*មានល្បើង* ”។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់សាធុសប្បុរសទាំងឡាយ ដែលបានជួយខ្នះខ្នែងក្នុងការងារធម្មទាននេះ ។

ដោយអំណាចបុញ្ញកម្មនៅក្នុងពេលនេះ សូមលោកជូនដល់ញោម ប្រុស **ពុំ ប៉ែន** ញោមស្រី **មឺស ស្រីវ៉ន** និង ពុទ្ធបរិស័ទទាំងអស់ ព្រមទាំង ពពួកញាតិគ្រប់ជាន់ថ្នាក់ សូមជួបប្រទះតែសេចក្តីសុខ សេចក្តីចំរើន ហើយទីបំផុតបានដល់ព្រះនិព្វានកុំបីសល់ម្នាក់ឡើយ ។

វត្ត សំសមី ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៦ ព-ស ៤៥៤៩ / គ-ស ២០០៦

**សាមណេរ ប៉ែន វិបុល**

# ជីវប្រវត្តិសង្ខេប

## សាមណេរ ប៉ែន វិបុល

សាមណេរ **ប៉ែន វិបុល** កើតនៅថ្ងៃ ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៨៤ នៅក្នុងភូមិ មេលប់ ឃុំ រកា ស្រុក ពារាំង ខេត្តព្រៃវែង ។

ញោមប្រុស នាម **ពុំ ប៉ែន**

ញោមស្រី នាម **មឺស ស្រីវ៉ន**

គាត់ទាំង ២ នាក់ ជាឧបាសក ឧបាសិកា នឹង ជាកសិករ ។

សាមណេររូបនេះ មាន បងប្អូនបង្កើត ចំនួន ៤ នាក់ គឺ

១- លោក **ប៉ែន ប៊ុន**

២- អ្នកស្រី **ប៉ែន ស្រីវ៉េត**

៣- កញ្ញា **ប៉ែន ស្រីវ៉ុន**

៤- សាមណេរ **ប៉ែន វិបុល**

កាលអាយុបាន ៩ ឆ្នាំ ឪពុកម្តាយ បានចាត់ឱ្យចូលរៀននៅសាលាបឋមសិក្សា មេលប់ រហូតដល់អាយុ ១៤ ឆ្នាំ បានបញ្ចប់បឋមសិក្សា ហើយបានបន្តទៅ សិក្សានៅអនុវិទ្យាល័យទៀត ដែលសាលានោះមាន ឈ្មោះថា វិទ្យាល័យ ញ៉ឹម វណ្ណដា ពារាំង ។

-ថ្ងៃ ៧ ១៥ ។ ៦ ឆ្នាំ ថោះ ឯកស័ក ក្នុង គិម្ហរដូវត្រូវនឹងថ្ងៃទី២៩ខែ ឧសភា ឆ្នាំ ១៩៩៩ បានចូលសាងផ្នួសក្នុងសំណាក់ព្រះពុទ្ធសាសនា

នៅពទ្ធសីមា វត្តមេលប់ ឃុំ រកា ដែលមានព្រះគ្រូ **និត សារ៉ៃ វិរិយធម្មោ** អតីត ជាព្រះគ្រូអនុគណ ស្រុកពារាំងនិងជាព្រះចៅអធិការ វត្តមេលប់ ជាឧបជ្ឈាយ៍ ហើយព្រះឧបជ្ឈាយ៍ឱ្យនាមបញ្ញត្តិ ថា **សតិសំវរោ** ដែលមានព្រះសង្ឃប្រមាណ ១២ អង្គ បួសជាមួយ ។

-ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០០ បានទៅសិក្សានៅពុទ្ធិកបឋមសិក្សា ឆ្នាំទី ១ នៅវត្តសិរីបន្ទាយដែក ឃុំ បន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល ក្រោមការគ្រប់គ្រង ដោយព្រះចៅអធិការ ព្រះនាម **មាស ឈឺន** និង លោកគ្រូ ឧទ្ទេសាចារ្យ **សុខ ខាន់** បានមួយវស្សា។

-ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០១ បានបន្តទៅសិក្សានៅពុទ្ធិកបឋមសិក្សាឆ្នាំទី ២ នៅវត្ត កន្លែង ឃុំ ដីឥដ្ឋ ស្រុក កៀនស្វាយ ខេត្តកណ្ដាល ក្រោមការគ្រប់គ្រង ដោយព្រះគ្រូ ចៅអធិការ ព្រះនាម **ទូច ចន្ថា** ឧទ្ទេសាចារ្យ **ព្រុំ សោម** បានមួយវស្សា ។

-ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០២ បានទៅសិក្សានៅពុទ្ធិកបឋមសិក្សាឆ្នាំ ទី ៣ នៅវត្តមុនីសាគរ ឃុំ ក្បាលកោះ ស្រុក កៀនស្វាយ ខេត្តកណ្ដាល ក្រោមការគ្រប់គ្រង ដោយព្រះគ្រូ ចៅអធិការ ព្រះនាម **ហុក សុវណ្ណី** ហៅ **កុយ** ឧទ្ទេសាចារ្យ **ថាច់ សុមេធ** និង សាស្ត្រាចារ្យ **ចាន់ ប៊ុច** បានមួយវស្សា ។

-ថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០០០ បានប្រលងជាប់សញ្ញាប័ត្រធម្ម-





វិន័យថ្នាក់ត្រី នៅវត្តស្លាកែត ស្រុកកៀនស្វាយ ។

-ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០១ បានប្រលងជាប់សញ្ញាប័ត្រធម្មវិន័យថ្នាក់ទោ នៅវត្តស្លាកែត ស្រុកកៀនស្វាយ។

-ថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០០២ បានប្រលងជាប់សញ្ញាប័ត្រធម្មវិន័យថ្នាក់ឯក នៅវត្តស្លាកែត ស្រុកកៀនស្វាយ។

-ថ្ងៃទី ៩-១០ ខែ កុម្ភៈ ឆ្នាំ ២០០២បានប្រលងជាប់សញ្ញាប័ត្របឋមសិក្សាបឋមភូមិ (សាលាបាលីរង ) នៅមណ្ឌលសាលាវិទ្យាល័យចតុម្មុខ ភ្នំពេញ ជាប់ជាស្ថាពរ ។

-ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០២ បានប្រលងចូលរៀនពុទ្ធិកវិទ្យា—ល័យ ខេត្តព្រៃវែង ជាស្ថាពរដែរ ។

-ថ្ងៃទី២-៣-៤ ខែកុម្ភៈ ឆ្នាំ ២០០៦ បានប្រលងជាប់សញ្ញាប័ត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិ នៅមណ្ឌលពុទ្ធិកវិទ្យាល័យខេត្តស្វាយរៀង នៅ វត្តជម្ពូព្រឹក្សា ។

បច្ចុប្បន្នស្នាក់នៅ **វត្តសំសមី** ទីរួមខេត្តព្រៃវែង ក្រោមការគ្រប់គ្រង ដោយព្រះចៅអធិការ ព្រះនាម **ហុក យ៉ាន សន្តិធម្មោ** បានបីវស្សាហើយ។

## សេចក្តីថ្លែងអំណរគុណ

អាត្មាភាពនាម **ប៉ែន វិបុល**ជាសមណសិស្សពុទ្ធិកវិទ្យាល័យខេត្តព្រៃវែង សូមថ្លែងអំណរគុណចំពោះ ឧបាសិកា **សុខ អ៊ីម** ព្រមទាំងបុត្រ និងពុទ្ធបរិស័ទទាំងឡាយ ដែលបានជួយជាបច្ច័យ សំរាប់បោះពុម្ពនូវ សៀវភៅ គិហិបតិបត្តិ ពិស្តារសំរាប់ជាធម្មទានដល់ពុទ្ធបរិស័ទទូទៅ ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសីលវតីទាំងអស់នៅពុទ្ធមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាក្រកម្ពុជា ( ភ្នំអដ្ឋវាស្ស ) ដែលបានជួយខ្នះខ្នែងក្នុងការងារធម្មទាននេះ ។

សូមថ្លែងអំណរគុណ ចំពោះ លោក **ម៉ឺង វណ្ណា** ជានាយករងនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រៃវែងដែលបានជួយវាយ អត្ថបទព្រះធម៌នេះ ។

ដោយអានុភាពនៃបុញ្ញកម្មនេះ សូមឧទ្ទិសមហាកុសលប្រគេនដល់ព្រះសព ព្រះគ្រូ **និត សាវ៉ៃ** ព្រះសពព្រះគ្រូធម្មវិបស្សនា **សំ ប៊ុនធឿន កេតុធម្មោ** លោកយាយ **សីលវតី ឆាវ និល** និង ពពួកញាតិទាំងឡាយក្នុងត្រៃភព ។

***សូមអនុមោទនា !***

## <u>មាតិកា</u>

**លេខរៀង** **ទំព័រ**


អារម្ភកថា............................................................................................២
ជីវប្រវត្តិ សាមណេរ ប៉ែន វិបុល................................................................៤
សេចក្តីថ្លែងអំណរគុណ..............................................................................៧
មាតិកា....................................................................................................៨
បទសរភញ្ញ...........................................................................................១១
បទសូត្រដាក់ទង់.....................................................................................១២
បទសូត្រលើកទង់.....................................................................................១៣
ធម៌អញ្ជើញទេវតា ( សគ្គេ ) ......................................................................១៤
រតនត្តយបូជា..........................................................................................១៧
ពុទ្ធរតនប្បណាម.....................................................................................១៧
ធម្មរតនប្បណាម.....................................................................................២៣
សង្ឃរតនប្បណាម..................................................................................២៧
រតនប្បណាមបែបសង្ខេប........................................................................៣៣
នមស្ការបូជនីយវត្ថុ ជាទីគោរព.................................................................៤០
នមស្ការព្រះរតនត្រៃ................................................................................៤១
នមស្ការពុទ្ធបាទ....................................................................................៤៣
ពុទ្ធបាទនមសក្ការគាថា..........................................................................៤៥
នមស្ការធាតុចេតិយ................................................................................៤៧
បត្តិទានកថា..........................................................................................៥៣
ផ្សាយមេត្តាធម៌......................................................................................៥៧

បត្តិទានគាថា ឥមិនា ប្រែ.............................................................៦១
បត្ថនាគាថា ប្រែ..........................................................................៦២
ខមាបនគាថា ប្រែ.........................................................................៦៤
អាកាសដ្ឋា ប្រែ...........................................................................៦៥
តេជះខ្ញុំសាង...............................................................................៦៧
បត្តិទានគាថា ( យំ កិញ្ចិ ) ..............................................................៦៨
បុព្វភាគបដិបត្តិ............................................................................៧១
ឧបាសកនិទ្ទេស.............................................................................៧៩
វិធីសមាទាន និច្ចសីល និង ឧបោសថសីល..................................៨៧
ឯកជ្ឈសមាទាន..........................................................................១០២
អង្គនៃនិច្ចសីល...........................................................................១០៨
អង្គនៃឧបោសថសីល...................................................................១១០
ឧបោសថកាលសង្ខេប..................................................................១១៣
ភាវេតព្វកិច្ច..............................................................................១១៧
អកុសលកម្មបទ..........................................................................១២៣
កុសលកម្មបទ.............................................................................១២៨
ធម្មទេសនាយាចនគាថា និង សរសើរព្រះធម៌ទេសនា...................១៣០
ពុទ្ធជយមង្គលគាថា.....................................................................១៣៥
បរាភវសូត្រ ប្រែជាពាក្យកាព្យ.....................................................១៤២
មង្គលសូត្រ.................................................................................១៥០
ភាសិតោវាទសង្ខេប....................................................................១៦៦
សំវេជនីយធម៌.............................................................................១៦៨
ប្រស្នាត្រៃគុណ **របស់ព្រះ សីលវរះ រស់ កែវ (រតនញ្ញាណ)**........១៧២
សន្និកថា ......................................................................................២២៥

## បទសរភញ្ញ

១-សូមថ្វាយបង្គំ ព្រះស-ម្ពុទ្ធ          ប្រសើរបំផុត ក្នុង លោ-កា

ជាគ្រូនៃមនុស្ស និងទេ-ព្តា ទ្រង់ត្រាស់ទេស្នា ប្រដៅ-សត្វ
ចង្អុលឱ្យដើរ ផ្លូវក-ណ្តាល មាគ៌ាត្រកាល អាចក-ម្ចាត់
ទុក្ខភ័យចង្រៃ ឱ្យខ្ចាយ-បាត់ អាចកាត់សង្សា រៈទុក្ខ-បាន ។
២-សាស្នាព្រះអង្គ នៅសព្វ-ថ្ងៃ សត្វមាននិស្ស័យ ពីបូ-រាណ
ប្រឹងរៀនប្រឹងស្តាប់ ចេះចាំ-បាន កាន់តាមលំអាន បានក្តី-សុខ
ឥតមានសុខណា ស្មើក្តី-ស្ងប់ បញ្ចប់ត្រឹមសុខ ឃ្លាតចាក-ទុក្ខ
តាំងពីលោកនេះ តទៅ-មុខ ក្តីសុខនឹងមាន ព្រោះធម៌-ស្ងប់ ។
៣-ខ្ញុំសូមបង្គំ ឆ្ពោះព្រះ-ធម៌ ព្រះសង្ឃបវរ ទាំងគ្រប់-សព្វ
រួមជាត្រៃរ័ត្ន គួរគោ-រព ជាម្លប់ត្រជាក់ នៃលោ-កា
ព្រះរូបព្រះធាតុ នៃព្រះ-ពុទ្ធ វិសុទ្ធតាងអង្គ ព្រះសា-ស្តា
សូមគុណត្រៃរ័ត្ន ជួយខេម-រា ឱ្យបានសុខា តរៀង-ទៅ ! ។

សម្តេចព្រះសង្ឃរាជ **ជួន ណាត** ( ជោតញ្ញាណោ )

## បទស្មូត្រដាក់ទង់ ព្រះពុទ្ធសាសនា

១-ជាតិយើងអ្នកកាន់សាសនា ត្រូវដឹងច្បាស់ថាព្រះពុទ្ធជិនស្រី
ទ្រង់មានឆព្វណ្ណរង្សី គឺ ព្រះរស្មី ទាំងប្រាំមួយពណ៌ ។
២-ផ្សាយចេញពីព្រះកាយទ្រង់ រុងរឿងឫទ្ធិរុង ប្រសើរបវរ
ឆ្មៀលឆ្វាត់កាយឆើតឆាយល្អ ទាំងប្រាំមួយពណ៌ ស្រស់ល្អសោភា ។
៣-កំណើតនៃព្រះរស្មី កើតដោយបារមី នៃព្រះភគវា
ធ្វើទានឥតមានរុញរា កាលដែលនៅជា ព្រះពោធិសត្វ ។
៤-រស្មីពណ៌ខៀវនោះណា កាលឆ្មៀលនេត្រាទ្រង់ដោយចិត្តកាត់
ធ្វើទានដល់ឥន្ទព្រាហ្មណ៍ពិត កាលនៅជាក្សត្រ នាមស្រីពិរាស្រ្ត ។
៥-រស្មីពណ៌លឿងភ្លឺថ្លា កាលដែលទ្រង់អារ សាច់ផែធ្វើមាស
បិទពុទ្ធរូបភ្លឺល្អឱភាស ព្រះឥន្ទជាងមាស ទ្រង់វ៉ៃយបណ្ឌិត ។
៦-រស្មីក្រហមនោះណា កាលដែលមាតាពស់ខាំស្លាប់ពិត
បុទុមស៊ូប្តូរជីវិត កាត់បេះដូងបិទ ធ្វើថ្នាំមាតា ។
៧-រស្មីពណ៌សសុទ្ធសាធ កាលដែលព្រះបាទ វេស្សន្តរក្សត្រា
ឱ្យទានដំរីស សោភា ដែលព្រះប្រាថ្នា យកពោធិញ្ញាណ ។
៨-រស្មីពណ៌ដូចជើងហង្ស កាលមាតាទ្រង់ យក្ខចាប់យកបាន
វិជ្ជាធរអារសាច់ខ្លួនប្រាណ ឱ្យយក្ខសាមាន្យ ស៊ូប្តូរជីវិត ។
៩-រស្មីភ្លឺផ្លេកពណ្ណរាយ កាលជាទន្សាយ ឈ្មោះសោមបណ្ឌិត
ឱ្យទានសាច់ឈាមជីវិត ដល់ឥន្ទព្រាហ្មណ៍ពិត ថាអត់អាហារ ។
១០-រស្មី ខៀវ-លឿង-ក្រហម ស ហង្សបាទ ព្រមភ្លឺផ្លេកអស្ចារ្យ
ត្រូវជាប្រាំមួយប្រការ ក្មេងចាស់កុមារ ចូរចាំទុកអើយ ។

## បទស្មូត្រលើកទង់ព្រះពុទ្ធសាសនា

១-សូមមើលទង់ជ័យ ឆព្វណ្ណរង្សី ដែលមានរស្មី ភ្លឺស្រស់ល្អ
ខៀវលឿងក្រហម ព្រមទាំងពណ៌ស ហង្សបាទនិងពណ៌ ដ៏ភ្លឺផ្លេក ។
២-ប្រទេសតូចធំ បានស្មគ្រ័ស្មាគម ជំនុំគ្នាច្រើន អនេក
ព្រមយករស្មី ព្រះពុទ្ធគួរត្រេក ប្រសើរពន់ពេកក្រៃកន្លង ។
៣-ធ្វើជាសញ្ញា ទង់ជ័យសាសនា នៃសម្ពុទ្ធធំ ចម្បង
ចូរយើងរាល់គ្នា យកចិត្តចាំចង នឹកដល់ព្រះអង្គ ជាអម្ចាស់ ។
៤-ទោះជាតិផ្សេងគ្នា ក៏ត្រូវដឹងថា សុទ្ធសឹងតែជា ពុទ្ធសាសនិ៍
ត្រូវមានសាមគ្គី ទាំងក្មេងទាំងចាស់ ប្រឹងប្រែងឱ្យណាស គ្រប់ៗគ្នា ។
៥-សូមសាសនាពុទ្ធ ថ្កុំថ្កើងខ្ពស់ផុត រុងរឿងវិសុទ្ធថ្លៃថ្លា ហើយមាន
ជ័យជោគ ផ្សាយពេញលោកា ដោយជនជ្រះថ្លា ច្រើនសែនលាន ។
៦-មានចិត្តស្នេហា គោរពបូជា ចំពោះព្រះធម៌ ដ៏កល្យាណ
ទាំងមនុស្សទេព្តា ស្នេហាគ្រប់ប្រាណ ប្រាថ្នាចង់បាន សេចក្តីសុខ ។
៧-យើងខេមរជាតិ នាំគ្នាខ្មីឃ្មាត កាន់ធម៌នឹងបាន ផុតទុក្ខ
រួបរួមសាមគ្គី ពីនេះទៅមុខ យើងនឹងបានសុខ ក្សេមក្សានត្រាណ ។
៨-ព្រមព្រៀងប្រព្រឹត្ត កាន់ធម៌សុចរិត ឆ្ពោះទៅកាន់ឋាន និព្វាន
ជាទីផុតទុក្ខ បានសុខក្សេមក្សាន្ត ជាតិយើងនឹងបាន សោយសុខា ។

## ធម៌អញ្ជើញទេវតា

សរជ្ជំ សសេនំ សពន្ធុំ នរិន្ទំ

បរិត្តានុភាវោ សទា រក្ខតូតិ

ផរិត្វាន មេត្តំ សមេត្តា ភទន្តា

អវិក្ខិត្តចិត្តា បរិត្តំ ភណន្តុ

អ្នកដ៏ចំរើនទាំងឡាយ ជាអ្នកប្រកបដោយមេត្តា ចូរផ្សាយនូវមេត្តាចិត្ត ដោយគិតដូច្នេះថា សូមអានុភាពនៃព្រះបរិត្ត រក្សានូវព្រះមហាក្សត្រជាធំជាងនរជន ព្រមទាំងរាជសម្បត្តិ ព្រមទាំងសេនាមាត្យ ព្រមទាំងព្រះរាជវង្សានុវង្ស សព្វៗកាលរៀងទៅ ហើយកុំមានចិត្តរាយមាយ ចូរសូត្រនូវព្រះបរិត្ត ។

សមន្តា ចក្កវាឡេសុ អត្រាគច្ឆន្តុ ទេវតា

សទ្ធម្មំ មុនិរាជស្ស សុណន្តុ សគ្គមោក្ខទំ

ទេវតាទាំងឡាយ ក្នុងចក្រវាឡទាំងឡាយ ដោយជុំវិញ ចូរមកប្រជុំគ្នាក្នុងទីនេះ ចូរស្តាប់នូវព្រះសទ្ធម្ម ជាធមិអាចឱ្យនូវសួគ៌និងព្រះនិព្វាន (របស់ព្រះអនាវរណញ្ញាណ) ជាស្តេចនៃអ្នកប្រាជ្ញ ។

សគ្គេ កាមេ ច រូបេ គិរិសិខរតដេ ចន្តលិក្ខេ វិមានេ ទីបេ រដ្ឋេ ច គាមេ តរុវនគហនេ គេហវត្ថុម្ហិ ខេត្តេ ភុម្មា ចាយន្តុ ទេវា ជលថលវិសមេ យក្ខគន្ធព្វនាគាតិដ្ឋន្តា សន្តិកេ យំ មុនិវរវចនំ សាធវោ មេ សុណន្តុ

ទេវតាទាំងឡាយដែលស្ថិតនៅក្នុងស្ថានសួគ៌ ដែលជាកាមភពនិងរូបភពក្តី ភូមិទេវតាទាំងឡាយដែលស្ថិតនៅក្នុងទិព្វវិមាន គឺលើកំពូលភ្នំ ឬ ភ្នំដែលជាប់ក្តី ព្វដ៏អាកាសក្តី នៅនាកោះនិងដែននិងស្រុកក្តី នៅនាដើមព្រឹក្សានិងព្រៃញាតស្បាតឬទីស្រែចម្ការក្តី យក្ខនិងគន្ធនិងនាគទាំងឡាយដែលស្ថិតនៅនាទីទឹកទីគោក ឬ ទីមិនរាបស្មើ ដែលនៅក្នុងទីជិតនេះក្តី សូមអញ្ជើញមកប្រជុំគ្នា (ក្នុងទីនេះ) ពាក្យឯណាដែលជាពាក្យព្រះសាក្យមុនីដ៏ប្រសើរ (ដែលយើងនឹងសូត្រឥឡូវនេះ) លោកអ្នកសប្បុរសទាំងឡាយ ចូរស្តាប់នូវពាក្យនោះ (អំពីសំណាក់) នៃខ្ញុំ (ដោយ គោរព)

ធម្មស្សវនកាលោ អយម្ភទន្តា បពិត្រលោកអ្នកដ៏ចំរើនទាំងឡាយ ពេលនេះ ជាពេលគួរនឹងស្តាប់នូវព្រះធមិ ។

ធម្មស្សវនកាលោ អយម្ភទន្តា  បពិត្រលោកអ្នកដ៏ចំរើនទាំងឡាយ ពេលនេះ ជាពេលគួរនឹងស្តាប់នូវព្រះធម៌ ។

ធម្មស្សវនកាលោ អយម្ភទន្តា  បពិត្រលោកអ្នកដ៏ចំរើនទាំងឡាយ ពេលនេះជាពេលគួរនឹងស្តាប់ នូវព្រះធម៌ ។



## <u>រតនត្តយបូជា</u>

ឥមេហិ ទីបធូបាទិសក្ការេហិ  ពុទ្ធំ  ធម្មំ  សង្ឃំ  អភិបូជយាមិ មាតាបិតាទីនំ  គុណវន្តានញ្ច  មយ្ហញ្ច  ទីឃរត្តំ  អត្ថាយ ហិតាយ សុខាយ ។

*ប្រែថា :* ខ្ញុំព្រះករុណាសូមបូជាចំពោះព្រះ ពុទ្ធ ធម៌ សង្ឃ } ជាម្ចាស់

ដោយគ្រឿងសក្ការៈទាំងឡាយ  មានទៀន  និង  ធូបជាដើមនេះ  ដើម្បីសេចក្តីចំរើន  ដើម្បីជាប្រយោជន៍  ដើម្បីសេចក្តីសុខ  ដល់អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង   ដល់ខ្ញុំព្រះករុណាផង អស់កាលជាអង្វែងទៅហោង ។

## <u>ពុទ្ធរតនប្បណាម</u>

*ថ្វាយបង្គំព្រះពុទ្ធរតនៈ*

នមោ  តស្ស

ភគវតោ   អរហតោ   សម្មាសម្ពុទ្ធស្ស ។

*ប្រែថា :*  វីកិរិយានមស្សការថ្វាយបង្គំនៃខ្ញុំព្រះករុណា   ចូរមាន

ដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

*( សូត្របាលី ៣ ចប់ សំរាយតែ ១ ចប់ ក៏បាន )*

យោ សន្និសិន្នោ វរពោធិមូលេ
មារំ សសេនំ មហតឹ វិជេយ្យោ
សម្ពោធិមាគច្ឆិ អនន្តញាណោ
លោកុត្តមោ តំ បនមាមិ ពុទ្ធំ ។

*ប្រែថា :* ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចំរើននូវព្រះអនាបាណស្សតិកម្មដ្ឋាន លើរតនបល្ល័ង្ក ក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរ បានផ្ចាញ់នូវមារាធិរាជព្រមទាំងសេនាដ៏ច្រើន ហើយទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ មានប្រាជ្ញារកទីបំផុតគ្មាន ព្រះអង្គប្រសើរជាងសត្វលោក ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធអង្គនោះដោយគោរព ។

**ក្រាបថ្វាយបង្គំម្តង**

*នមស្សការព្រះសម្មាសម្ពុទ្ធដូចសេចក្តីខាងលើនេះ គឺនមស្សការដោយសង្ខេប មិនបានញែកកាលចេញជាបីឡើយ បើនមស្សការដោយពិស្តារវិញ ទើបញែកកាល ចេញជា ៣ ដូចសេចក្តីខាងក្រោមនេះ ។*

យេ ច ពុទ្ធា អតីតា ច
យេ ច ពុទ្ធា អនាគតា
បច្ចុប្បន្នា ច យេ ពុទ្ធា
អហំ វន្ទាមិ សព្វទា ។

*ប្រែថា :* ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធនិព្វានកន្លងទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធក្នុងកាលខាងមុខក្តីព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណាដែលបានត្រាស់ជាព្រះពុទ្ធក្នុងភទ្ទកប្បនេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយនោះគ្រប់កាលទាំងពួង ។

**ក្រាបថ្វាយបង្គំម្តង**

*រួចហើយគប្បីតាំងចិត្តរំឭកដល់គុណទាំង ១០ ព្រះនាម ដោយបង្អោនកាយវាចាថា :*

ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណ-
សម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ
សត្ថាទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។

*ប្រែថា :* ឥតិបិ សោ ភគវា អរហំ ព្រះដ៏មានព្រះភាគ អង្គនោះ ទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវពោល គឺកិលេស ព្រមទាំងវាសនា គឺកាយបយោគ និង វចីបយោគ សម្មាស-ម្ពុទ្ធោ ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេ-យ្យធម៌ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ វិជ្ជាចរណសម្បន្នោ ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះ ព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ និង វិជ្ជា ៨ និង ចរណៈ ១៥ សុគតោ ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អ យាងទៅកាន់សុន្ទរស្ថាន គឺអមតមហានិព្វាន លោកវិទូ ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវ ត្រៃលោក អនុត្តរោ ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន បុរិសទម្មសារថិ ទ្រង់ព្រះនាមថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលមានឧបស្ស័យ គួរនឹងទូន្មានបាន សត្ថាទេវមនុស្សានំ ទ្រង់ព្រះនាមថា សត្ថាទេវមនុស្សានំ ព្រោះព្រះអង្គជាសាស្ត្រាចារ្យ នៃទេវតានិងមនុស្សទាំងឡាយ ពុទ្ធោ ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ហើយញ៉ាំងឱ្យអ្នកដទៃត្រាស់ដឹងផង ភគវា ទ្រង់ព្រះនាម ភគវា ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ចាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

*រឭកដល់ពុទ្ធគុណរួចហើយ គប្បីប្រកាសប្តេជ្ញាខ្លួនដោយពាក្យសច្ចៈថា:*

នត្ថិ មេ សរណំ អញ្ញំ
ពុទ្ធោ មេ សរណំ វរំ
ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។

*ប្រែថា* នត្ថិ មេ សរណំ អញ្ញំ វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណាមិនមានឡើយ ពុទ្ធោ មេ សរណំ វរំ មានតែព្រះពុទ្ធជាម្ចាស់ជាទីពឹងទីរឭក ដ៏ប្រសើររបស់ខ្ញុំព្រះករុណា ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ សូមសិរីសួស្តីជ័យមង្គលចូរមានដល់ខ្ញុំព្រះករុណាដោយកិរិយាពោល នូវពាក្យសច្ចនេះ ។

*ប្តេជ្ញាដូច្នេះរួចហើយ គប្បីសូត្រសូមខមាទោសនឹងព្រះពុទ្ធជាម្ចាស់ថា :*

ឧត្តមង្គេន វន្ទេហំ
បាទបំសុំ វរុត្តមំ
ពុទ្ធេ យោ ខលិតោ
ទោសោ ពុទ្ធោ ខមតុ តំ មមំ ។

*ប្រែថា :* ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវលម្អងធូលីព្រះបាទនៃព្រះសម្មាសម្ពុទ្ធ ដ៏ប្រសើរខ្ពង់ខ្ពស់ដោយអវៈយវៈដ៏ឧត្តមគឺត្បូង ពុទ្ធេ យោ ខលិតោ ទោសោ ទោសឯណា ដែលខ្ញុំព្រះករុណាធ្វើឱ្យភ្លាំងភ្លាត់ហើយក្នុងព្រះពុទ្ធជាម្ចាស់ ពុទ្ធោ ខមតុ តំ មមំ សូមព្រះពុទ្ធជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។

***ក្រាបថ្វាយបង្គំម្តង***

***ពៀរមិនរង្វាប់ ដោយការចងពៀរទេ***
***ពៀររមែងរង្វាប់ ដោយការមិនចងពៀរ ៕***

# ធម្មរតនប្បណាម

*ថ្វាយបង្គំធម្មរតនៈ*

អដ្ឋង្គិការិយបថោ ជនានំ
មោក្ខប្បវេសាយ ឧជូ ច មគ្គោ
ធម្មោ អយំ សន្តិករោ បណីតោ
និយ្យានិកោ តំ បនមាមិ ធម្មំ ។

*ប្រែថា* ព្រះសទ្ធម្មឯណា ជាធម៌ប្រកបដោយអង្គ ៨ ប្រការ ជាគន្លងដំណើរនៃ ព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ក្នុងកិរិយាញ៉ាំងជន ដែលប្រាថ្នានូវព្រះនិព្វាន ឱ្យចូលទៅកាន់ព្រះនិព្វានបាន ព្រះធម៌នេះជាធម៌ធ្វើឱ្យត្រជាក់រម្ងាប់បង់ នូវភ្លើងទុក្ខ ភ្លើងកិលេស ជាធម៌ដ៏ឧត្តមជាគុណ ញ៉ាំងសត្វឱ្យចេញចាកសង្សារទុក្ខ ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសទ្ធម្មនោះដោយគោរព ។

***ក្រាបថ្វាយបង្គំម្តង***

*នមស្សការដល់ព្រះសទ្ធម្ម ដូចសេចក្តីខាងលើនេះ គឺនមស្សការដោយសង្ខេប មិនបានញែកកាលចេញជា ៣ ឡើយ បើនមស្សការដោយពិស្តារវិញ ទើបញែកកាលជាបី ដូចសេចក្តីខាងក្រោម :*

យេ ច ធម្មា អតីតា ច

យេ ច ធម្មា អនាគតា

បច្ចុប្បន្នា ច យេ ធម្មា

អហំ វន្ទាមិ សព្វទា ។

*ប្រែថា* ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ដែលនិព្វានកន្លងទៅហើយក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធនឹងមានមក ក្នុងកាលខាងមុខក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធទ្រង់ប្រតិស្ឋានទុកក្នុង កាលសព្វថ្ងៃនេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធម៌ទាំងឡាយនោះគ្រប់កាលទាំងពួង ។

**ក្រាបថ្វាយបង្គំធម៌**

*រួចហើយគប្បីតាំងចិត្តរឭកដល់ធម្មគុណដោយបង្អោនកាយវាចាថា :*

ស្វាក្ខាតោ ភគវតា ធម្មោ

សន្ទិដ្ឋិកោ អកាលិកោ

ឯហិបស្សិកោ ឱបនយិកោ

បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។

*ប្រែថា* ស្វាក្ខាតោ ភគវតា ធម្មោ ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដក ជាធម៌គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងហើយដោយល្អ ធម្មោ ព្រះនព្វលោកុត្តរធម៌ មាន ៩ ប្រការ គឺ មគ្គ ៤ ផល ៤ និព្វាន ១ សន្ទិដ្ឋិកោ ជាធម៌គឺព្រះអរិយបុគ្គលទាំងពួងដឹងពិតឃើញពិតដោយបច្ចវេក្ខណញ្ញាណ គឺថានឹងបានដឹងដោយស្តាប់ដោយជឿបុគ្គលដទៃនោះ ៗ ក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង អាកាលិកោ ជាធម៌ឱ្យនូវផលមិនរង់ចាំកាល គឺថា កាលបើព្រះអរិយមគ្គកើតឡើងហើយព្រះអរិយផលក៏កើតក្នុងលំដាប់គ្នា មិនបានឃឺតយូរឡើយ ឯហិបស្សិកោ ជាធម៌គួរដល់ ឯហិបស្សវិធី គឺថា បើព្រះអរិយបុគ្គលដែលបានសំរេចមគ្គផលហើយក៏គួរនឹងហៅបុគ្គលដទៃឱ្យចូលមកមើលបាន ឱបនយិកោ ជាធម៌គឺព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួនដោយអំណាចនៃភាវនា បច្ចត្តំ វេទិតព្វោ វិញ្ញូហិ ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយមានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹងគប្បីឃើញច្បាស់ ក្នុងចិត្តនៃខ្លួន ។

*រឭកដល់ព្រះធម្មគុណដូច្នេះរួចហើយ គប្បីប្រកាសខ្លួនដោយពាក្យសច្ចៈថា :*

នត្ថិ មេ សរណំ អញ្ញំ
ធម្មោ មេ សរណំ វរំ
ឯតេន សច្ចវជ្ជេន
ហោតុ មេ ជយមង្គលំ ។

*ប្រែថា* នត្ថិ មេ សរណំ អញ្ញំ វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណាមិនមានឡើយ ធម្មោ មេ សរណំ វរំ មានតែព្រះធម៌ជាម្ចាស់ ជាទីពឹងទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ សូមសិរីសួស្តីជយមង្គលចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

*ប្តេជ្ញាខ្លួនដូច្នោះរួចហើយ គប្បីសូត្រសូមខមាទោស នឹងព្រះធម៌ជាម្ចាស់ ថា :*

ឧត្តមង្គេន វន្ទេហំ
ធម្មញ្ច ទុវិធំ វរំ
ធម្មេ យោ ខលិតោ
ទោសោ ធម្មោ ខមតុ តំ មមំ ។

*ប្រែថា :* ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះធម៌ដ៏ប្រសើរមានពីរប្រការ គឺ ព្រះបរិយត្តិធម៌ និងព្រះនព្វលោកុត្តរធម៌ ដោយអវៈយវៈដ៏ឧត្តម គឺត្បូង ធម្មេ យោ ខលិតោ ទោសោ ទោសឯណាដែលខ្ញុំព្រះករុណាធ្វើអោយភ្លាំងភ្លាត់ហើយក្នុងព្រះធម៌ជាម្ចាស់ ធម្មោ ខមតុ តំ មមំ សូមព្រះធម៌ជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។

***ក្រាបថ្វាយបង្គំម្តង***

## សង្ឃរតនប្បណាម

*ថ្វាយបង្គំព្រះសង្ឃរតនៈ*

សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ
សន្តិន្ទ្រិយោ សព្វមលប្បហីនោ
គុណេហិនេកេហិ សមិទ្ធិបត្តោ
អនាសវោ តំ បនមាមិ សង្ឃំ ។

*ប្រែថា* ព្រះអរិយសង្ឃឯណាដ៏បរិសុទ្ធវិសេស ជាទក្ខិណេយ្យបុគ្គលប្រសើរ មានឥន្ទ្រិយរម្ងាប់បង់ហើយ មានមន្ទិលគឺរាគាទិក្កិលេស

បន្សាត់បង់ហើយ ជាព្រះសង្ឃដល់ហើយនូវកិរិយាសម្រេចដោយគុណទាំងឡាយដ៏ច្រើន ជាព្រះសង្ឃមានអាសវធម៌មិនមាន គឺថា ជាព្រះខីណាស្រព ខ្ញុំព្រះករុណាសូមក្រាបថ្វាយ បង្គំនូវព្រះអរិយសង្ឃនោះដោយគោរព ។

**ក្រាបថ្វាយបង្គំម្តង**

*នមស្សការដល់ព្រះអរិយសង្ឃដូចខាងលើនេះ គឺនមស្សការដោយសង្ខេប មិនបានញែកកាលចេញជា ៣ ឡើយ បើនមស្សការដោយពិស្តារវិញ ទើបញែកកាលជាបី ដូចសេចក្តីខាងក្រោមនេះ:*

យេ ច សង្ឃា អតីតា ច
យេ ច សង្ឃា អនាគតា
បច្ចុប្បន្នា ច យេ សង្ឃា
អហំ វន្ទាមិ សព្វទា ។

*ប្រែថា* ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសំរេចមគ្គនិងផលកន្លងទៅហើយក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គនិងផលក្នុងកាលខាងមុខក្តី ព្រះសង្ឃទាំងឡាយឯណាដែលជាព្រះសង្ឃ បានសម្រេចមគ្គនិងផលក្នុងកាល ជាបច្ចុប្បន្ននេះក្តីខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសង្ឃទាំងឡាយនោះគ្រប់កាលទាំងពួង ។

**ក្រាបថ្វាយបង្គំម្តង**

*រួចហើយគប្បីតាំងចិត្តរឭកដល់សង្ឃគុណដោយបង្អោនកាយវាចាថា:*

សុបដិបន្នោ ភគវតោ សាវកសង្ឃោ
ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ
ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ
សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ
យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា
ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ
បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ
អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

*ប្រែថា* សុបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃគឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវ័ក នៃព្រះដ៏មានព្រះភាគលោកប្រតិបត្តិដោយត្រង់គឺប្រតិបត្តិជាមជ្ឈិមបដិបទា ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹង

នូវព្រះនិព្វាន ជាស្ថានក្សេមផុតចាកទុក្ខទាំងពួង សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្មគឺប្រតិបត្តិគួរដល់ សីល សមាធិ បញ្ញា យទិទំ ចត្តារិ បុរិសយុគានិ ព្រះសង្ឃឯណាបើរាប់ជាគូនៃបុរសទាំងឡាយ មាន ៤ គូ គឺ ព្រះសង្ឃដែលបានសំរេចនូវសោតាបត្តិមគ្គ និង សោតាបត្តិផល ជាគូ ១ សកទាគាមិមគ្គ និង សកទាគាមិផលជាគូ ១ អនាគាមិមគ្គ និង អនាគាមិផលជាគូ ១ អរហត្តមគ្គ និង អរហត្តផលជាគូ ១ អដ្ឋ បុរិសបុគ្គលា បើរាប់រៀងជាបុរសបុគ្គល មាន ៨ គឺព្រះសង្ឃដែលបានសម្រេចនូវ សោតាបត្តិមគ្គ ១សោតាបត្តិផល១សកទាគាមិមគ្គ ១ សកទាគាមិផល ១ អនាគាមិមគ្គ ១ អនាគាមិផល ១ អរហត្តមគ្គ ១ អរហត្តផល១ ឯស ភគវតោ សាវកសង្ឃោ ព្រះសង្ឃទាំងនោះជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ អាហុនេយ្យោ លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា បាហុនេយ្យោ លោកគួរទទួលនូវអាគន្តុក-ទាន គឺទានដែលបុគ្គលតាក់តែងដើម្បីញាតិ និង មិត្ត ដែលមកអំពីទិសផ្សេងៗហើយបង្អោនចូលមកបូជា ទក្ខិណេយ្យោ លោកគួរទទួលនូវទាន ដែលបុគ្គលជឿនូវកម្ម និងផលនៃកម្មហើយបូជា អញ្ជលិករណីយោ លោកគួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជគឺបុណ្យនៃសត្វលោក រកខេត្តដទៃក្រៃលែងជាគ្មាន ។

*រឭកដល់សង្ឃគុណ ដូច្នេះរួចហើយ គប្បីប្រកាសប្តេជ្ញាខ្លួនដោយពោលពាក្យសច្ចៈថា :*

នត្ថិ មេ សរណំ អញ្ញំ  
សង្ឃោ មេ សរណំ វរំ  
ឯតេន សច្ចវជ្ជេន  
ហោតុ មេ ជយមង្គលំ ។

*ប្រែថា* នត្ថិ មេ សរណំ អញ្ញំ វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណាមិនមានឡើយ សង្ឃោ មេ សរណំ វរំ មានតែព្រះសង្ឃជាម្ចាស់ជាទីពឹងទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ សូមសិរីសួស្តីជ័យមង្គលចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

*ប្ដេជ្ញាខ្លួនដូច្នោះរួចហើយគប្បីសូត្រ សូមខមាទោសនឹងព្រះសង្ឃជាម្ចាស់ ថា :*

ឧត្តមង្គេន វន្ទេហំ

សង្ឃញ្ច ទុវិធោត្តមំ

សង្ឃេ យោ ខលិតោ ទោសោ

សង្ឃោ ខមតុ តំ មមំ ។

*ប្រែថា :* ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះសង្ឃដ៏ប្រសើរមានពីរប្រការគឺ សម្មតិសង្ឃ និង អរិយសង្ឃ ដោយអវៈយវៈដ៏ឧត្តមគឺត្បូង សង្ឃេ យោ ខលិតោ ទោសោ ទោសឯណាដែលខ្ញុំព្រះករុណាធ្វើឱ្យភ្លាំងភ្លាត់ ហើយក្នុងព្រះសង្ឃជាម្ចាស់ សង្ឃោ ខមតុ តំ មមំ សូមព្រះសង្ឃជាម្ចាស់អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។

***ក្រាបថ្វាយបង្គំម្ដង***

*វិធីនមស្សការថ្វាយបង្គំនូវព្រះរតនត្រ័យ មិនចំពោះកាល និង ថ្វាយបង្គំនូវព្រះរតនត្រ័យក្នុងកាលទាំង ៣ និង សេចក្ដីរឭកគុណព្រះរតន - ត្រ័យ និងពាក្យប្ដេជ្ញាខ្លួនចំពោះព្រះរតនត្រ័យ និងថ្វាយបង្គំសុំខមាទោសចំពោះព្រះរតនត្រ័យទាំង ៥ ន័យដែលបានពោលមកហើយ ក្នុងខាងដើមនោះ ក៏ចប់ប៉ុណ្ណេះដោយពិស្ដារ ។ អ្នកដែលមានសទ្ធាប្រាថ្នា នឹងនមស្ស-ការព្រះរតនត្រ័យនោះបើមានពេលឱកាសល្មម និងសូត្រនមស្សការទាំង ៣ បទឱ្យបានចប់សព្វគ្រប់ដោយសេចក្ដីពិស្ដារដូចបែបយ៉ាងខាងដើមនោះ ។*

## រតនប្បណាម បែបសង្ខេប

*ព្រមទាំងបូជាគ្រឿងសក្ការៈ*

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

*ប្រែដូចមុន*

ឥតិបិ សោ ភគវា អរហំ ។ល។ ភគវាតិ

តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ

តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។

*ប្រែថា:* ឥតិបិសោ ភគវា អរហំ ព្រះដ៏មានព្រះភាគអង្គនោះទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹក

សត្រូវពោលគឺ កិលេស ព្រមទាំងវាសនា គឺកាយបយោគ និង វចីបយោគ ។ល។ ភគវា ទ្រង់ព្រះនាមថា ភគវា ព្រោះព្រះអង្គមាន ដំណើរទៅកាន់ត្រៃភពខ្ជាក់ចោលហើយ គឺថាព្រះអង្គ មិនត្រឡប់កើតទៀតឡើយ តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គប្រកបព្រមហើយដោយគុណមានគុណថា អរហំ ជាដើមនោះដោយសិរសាគឺត្បូង តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ ខ្ញុំព្រះករុណាសូមបូជាចំពោះនូវ ព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយមានប្រមាណប៉ុណ្ណេះ ។

### ក្រាបថ្វាយបង្គំម្តង

ស្វាក្ខាតោ ភគវតា ធម្មោ ។ល។
បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ
តំ ស្វាក្ខាតាទិគុណសំយុត្តំ
ធម្មំ សិរសា នមាមិ ។
តញ្ច ធម្មំ ឥមេហិ
សក្ការេហិ អភិបូជយាមិ ។

*ប្រែថា* ស្វាក្ខាតោ ភគវតា ធម្មោ ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដក ជាធម៌គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងហើយដោយល្អ ។ល។ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ជាធម៌គឺអ្នកប្រាជ្ញាទាំងឡាយមានឧគ្ឃដិតញ្ញូបុគ្គលជាដើមគប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះធម៌ជាម្ចាស់ ដ៏ប្រកបព្រមហើយ ដោយគុណមានគុណថា ស្វាក្ខាតោ ជាដើមនោះ ដោយសិរសាគឺត្បូង តញ្ច ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះធម៌ជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយមានប្រមាណប៉ុណ្ណេះ ។

### ក្រាបថ្វាយបង្គំម្តង

សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ។ល។
អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។
តំ សុប្បដិបន្នា ទិគុណសំយុត្តំ សង្ឃំ
សិរសា នមាមិ តញ្ច សង្ឃំ
ឥមេហិ សក្ការេហិ អភិបូជយាមិ ។

*ប្រែថា:* សុប្បដិន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវ័កនៃព្រះមានព្រះភាគលោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លង ព្រះនព្វលោកុត្តរធម៌ ។ល។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជគឺបុណ្យនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន តំ សុប្បដិបន្នាទិគុណសំយុត្តំ សង្ឃំ សិរសា នមាមិ ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះ សង្ឃជាម្ចាស់ដ៏ប្រកបព្រមហើយដោយគុណមានគុណថា សុប្បដិបន្នោ ជាដើមនោះដោយសិរសាគឺត្បូង តញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ ខ្ញុំព្រះករុណាសូមបូជា ចំពោះនូវព្រះសង្ឃជាម្ចាស់នោះដោយគ្រឿងសក្ការៈទាំងឡាយមានប្រមាណប៉ុណ្ណេះ ។

**ក្រាបថ្វាយបង្គំម្តង**

ឥច្ចេវមច្ចន្តនមស្សនេយ្យំ
នមស្សមានោ រតនត្តយំ យំ
បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ
តស្សានុភាវេន ហតន្តរាយោ ។

*ប្រែថា* ខ្ញុំសូមនមស្សការ លើកហត្ថាឱនសិរសី បង្គំគុណទាំងបីខ្ពស់លើសលប់ត្រៃលោកា ។ សូមបុណ្យកងកុសល ឱ្យបានដល់យើងខ្ញុំណា ពេញពោរស្មើធារា ដូចជលសាធំទូលាយ ។ សូមឱ្យកំចាត់បង់អពមង្គលទាំងឡាយ ឱ្យចៀសចេញចាកឆ្ងាយ ក្តីអន្តរាយកុំបីមាន ។ ដោយកំលាំងអនុភាព បុញ្ញលាភជាប្រធាន កងបុញ្ញរាសីមាន សូមបានក្សាន្តកុំមានមោះ ។ ដោយគុណនមស្ការ ត្រ័យរតនាប្រសើរខ្ពស់ សូមអានិសង្សនោះ ដាក់ដល់ឋាននិព្វានហោង ។

## សុភមង្គលគាថា

*ពាក្យពោលប្រកាសសូមសេចក្តីល្អ សេចក្តីចំរើនគ្រប់យ៉ាង*

ហោតុ សព្វំ សុមង្គលំ
រក្ខន្តុ សព្វទេវតា
សព្វពុទ្ធានុភាវេន
សោត្ថិ ហោតុ និរន្តរំ ។

*ប្រែថា* ហោតុ សព្វំ សុមង្គលំ សុភមង្គលគឺសេចក្តីចំរើនដ៏ល្អគ្រប់យ៉ាង ចូរមានដល់ខ្ញុំ រក្ខន្តុ សព្វទេវតា ទេវតាទាំងពួងទាំងឡាយចូររក្សានូវខ្ញុំ សព្វពុទ្ធានុភាវេន ដោយអនុភាពនៃព្រះពុទ្ធគប់ព្រះអង្គ សោត្ថិហោតុ និរន្តរំ សូមសិរីសួស្តីចូរមានដល់ខ្ញុំឱ្យ

បានគ្រប់ពេលកុំបីមានចន្លោះឡើយ ។

ហោតុ សព្វំ សុមង្គលំ

រក្ខន្តុ សព្វទេវតា

សព្វធម្មានុភាវេន

សោត្ថិ ហោតុ និរន្តរំ ។

*ប្រែថា* ហោតុ សព្វំ សុមង្គលំ សុភមង្គលគឺសេចក្តីចំរើនដ៏ល្អគ្រប់យ៉ាង ចូរមានដល់ខ្ញុំ រក្ខន្តុ សព្វទេវតា ទេវតាទាំងពួងទាំងឡាយចូររក្សានូវខ្ញុំ សព្វធម្មានុភាវេន ដោយអនុភាពនៃព្រះធម៌ទាំងពួង សោត្ថិ ហោតុ និរន្តរំ សូមសិរីសួស្តីចូរមានដល់ខ្ញុំឱ្យបានគ្រប់ពេលកុំបីមានចន្លោះឡើយ ។

ហោតុ សព្វំ សុមង្គលំ

រក្ខន្តុ សព្វទេវតា

សព្វសង្ឃានុភាវេន

សោត្ថិ ហោតុ និរន្តរំ ។

*ប្រែថា* ហោតុ សព្វំ សុមង្គលំ សុភមង្គលគឺសេចក្តីចំរើនដ៏ល្អគ្រប់យ៉ាង ចូរមានដល់ខ្ញុំ រក្ខន្តុ សព្វទេវតា ទេវតាទាំងពួងទាំងឡាយចូររក្សានូវខ្ញុំ សព្វសង្ឃានុភាវេន ដោយអនុភាពនៃព្រះសង្ឃទាំងពួងទាំងឡាយ សោត្ថិ ហោតុ និរន្តរំ សូមសិរីសួស្តីចូរមានដល់ខ្ញុំឱ្យបានគ្រប់ពេលកុំបីមានចន្លោះឡើយ ។

***ចប់ត្រៃប្រណាមដោយសង្ខេបតែប៉ុណ្ណោះ***

**<u>ពុទ្ធភាសិត</u>**

*វាចា សូម្បីមានដល់ទៅមួយពាន់មាត់ក៏ដោយ តែជាវាចា មិនប្រកបដោយបទ ដែលមានប្រយោជន៍ វាចានោះគឺជាវាចា មិនប្រសើរសោះឡើយ បទដែលប្រកបដោយប្រយោជន៍មួយបទដែលបុគ្គលបានស្តាប់ហើយស្ងាប់រម្ងាប់បានបទនោះជាបទប្រសើរជាង ។*

## នមស្ការបូជនីយវត្ថុ ជាទីគោរព

វន្ទាមិ ចេតិយំ សព្វំ សព្វដ្ឋានេសុ បតិដ្ឋិតំ
សារីរិកធាតុ មហាពោធិ ពុទ្ធរូបំ សកលំ សទា ។

ខ្ញុំសូមថ្វាយបង្គំ ឆ្ពោះព្រះបរមចេតិយ
ព្រមទាំងព្រះសារី- រិកធាតុនៃព្រះពុទ្ធ ។
និងមហាពោធិព្រឹក្ស ដែលគួរនឹកដោយលំអុត
លំឱនចិត្តបរិសុទ្ធ លើកកំបង់អញ្ជលី ។
និងព្រះពុទ្ធរូប តំណាងព្រះអង្គមុនី
ដែលឋិតនៅគ្រប់ទី ឋាននាៗ នោះទាំងអស់ ។
( ដោយតេជៈនៃគុណ ព្រះមានបុណ្យប្រសើរខ្ពស់
ដែលតែងតែរំលស់ រំដោះទុក្ខភ័យអន្តរាយ ។
សូមឱ្យខ្ញុំបានសុខ ឃ្លាតចាកទុក្ខផងទាំងឡាយ
សត្រូវទោះជិតឆ្ងាយ សូមឱ្យក្លាយមកជាមិត្រ ។
សូមទាន់ព្រះអរិ- យមេត្តេយ្យថ្លៃវិសិដ្ឋ
សូមបានឃើញធម៌ពិត សមដូចចិត្តប្រាថ្នាហោង ) ។

## នមស្ការព្រះរតនត្រ័យ
## យោកប្បកោដីហិបិ

*ប្រែជាពាក្យកាព្យប្លែកមួយបែបទៀត*

យោ កប្បកោដីហិបិ អប្បមេយ្យំ កាលំ ករោន្តោ អតិទុក្ករានិ ខេទំ គតោ លោកហិតាយ នាថោ នមោ មហាការុណិកស្ស តស្ស ព្រះពុទ្ធជាទីពឹង ជាពុំនឹងសព្វសត្វា ព្រះអង្គកាលប្រាថ្នា ធ្វើកសាងអស់កាលយូរ ។ រាប់ដោយកោដិកប្បា ច្រើនគណនាហួសគិតគូរ បានត្រាស់ជាសព្វញ្ញូ ត្រាស់ជាគ្រូលើភពឋាន ។ ធ្វើកម្មជាកម្រ មនុស្សនិករត្រាប់ពុំបាន តោកយ៉ាកលំបាកប្រាណព្រោះប្រយោជន៍ដល់សព្វសត្វ ។ ខ្ញុំសូមឱនសិរសា ចិត្តប្រាថ្នាបង្គំថ្វាត់ ព្រះពុទ្ធករុណាសត្វ នោះជាទីពឹងសព្វកាល ។

អសម្ពុធំ ពុទ្ធនិសេវិតំ យំ ភវាភវំ គច្ឆតិ ជីវលោកា
នមោ អវិជ្ជាទិកិលេសជាលំ វិទ្ធំសិនោ ធម្មវរស្ស តស្ស ។

សត្វតែងកើតស្លាប់បង់ ព្រោះចំណង់កម្មជាគោល
ឱ្យវិលវល់អន្ទោល ក្នុងភពតូច និង ភពធំ ។
ហេតុតែមិនដឹងធម៌ ជាម្ចាស់ល្អស្អាតសុខុម

គឺព្រះពុទ្ធសេពសម ចិត្តខ្ញុំសូមនមស្ការ ។
នូវធម៌ប្រពៃពិត វិសេសសុទ្ធនោះឯងណា
កាត់បង់អវិជ្ជា គឺបណ្ដេញកិលេសហើយ ។

គុណេហិ យោ សីលសមាធិបញ្ញា វិមុត្តិញ្ញាណប្បភុតីហិ យុត្តោ ខេត្តញ្ជនានំ កុសលត្ថិកានំ តមរិយសង្ឃំ សិរសា នមាមិ ។

ព្រះសង្ឃអង្គសាវ័ក មានសំវរៈសទ្ធាទ្រង់
តបដោយគុណសីលត្រង់ នឹងសមាធិ បញ្ញា ។
នឹងវិមុត្តិញ្ញាណ កិលេសគ្មានក្នុងអាត្មា
ជាបុញ្ញក្ខេត្តា ជនត្រូវការជាកុសល ។
ខ្ញុំសូមឱនសិរសី ដល់ព្រះអរិយបុគ្គល
ជាបុត្រព្រះទសពល ជាមង្គលដល់សព្វសត្វ ។

ឥច្ចេវមច្ចន្ត នមស្សនេយ្យំ នមស្សមានោ រតនត្តយំ យំ បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ តស្សានុភាវេន ហតន្តរាយោ ។

ខ្ញុំសូមនមសក្ការ លើកហត្ថាឱនសិរសី
បង្គំគុណទាំងបី ខ្ពស់លើសលប់ត្រៃលោកា ។
សូមបុណ្យកងកុសល ឱ្យបានដល់យើងខ្ញុំណា
ពេញពោរស្មើធារា ដូចជលសាធំទូលាយ ។
សូមឱ្យកំចាត់បង់ អពមង្គលទាំងឡាយ
ឱ្យចៀសចេញចាកឆ្ងាយ ក្ដីអន្តរាយកុំបីមាន ។
ដោយកំលាំងអានុភាព បុញ្ញលាភជាប្រធាន
កងបុណ្យរាសីមាន សូមបានក្សាន្តកុំមានមោះ ។
ដោយគុណនមស្ការ ត្រ័យរតនាប្រសើរខ្ពស់
សូមអានិសង្សនោះ ដាក់ដល់ឋាននិព្វានហោង ។

## នមស្ការពុទ្ធបាទ

វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ
តិលោកកេតុំ តិភវេកនាថំ
យោ លោកសេដ្ឋោ សកលំ កិលេសំ
ឆេត្វាន ពោធេសិ ជនំ អនន្តំ ។

ព្រះសម្មាសម្ពុទ្ធអង្គឯណា ព្រះអង្គប្រសើរក្នុងលោក ទ្រង់កាត់បង់នូវកិលេសទាំងអស់បានហើយ ញុំាងជនជាអនន្តឱ្យត្រាស់ដឹងហើយ ខ្ញុំសូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធនោះ ព្រះអង្គឆ្លងផុតពីច្រាំងនៃភពហើយ ព្រះអង្គជាទង់ជ័យនៃត្រៃលោក មានតែព្រះអង្គមួយ ជាទីពឹងនៃសព្វសត្វក្នុងត្រៃភព ។

យំ នម្មទាយ នទីយា បុលិនេ ច តីរេ
យំ សច្ចពន្ធគិរិកេ សុមនាចលគ្គេ
យំ តត្ថ យោនកបុរេ មុនិនោ ច បាទំ
តំ បាទលញ្ឆនមហំ សិរសា នមាមិ ។

ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) លើផ្នូរខ្សាច់ ទៀបឆ្នេរនៃស្ទឹងឈ្មោះ នម្មទា ស្នាមព្រះបាទឯណា (ដែលព្រះ-សម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) លើភ្នំសច្ចព័ន្ធ នឹងលើភ្នំសុមនកូដ ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) ក្នុងយោនកបុរី ខ្ញុំសូមក្រាបថ្វាយបង្គំ ដោយត្បូងចំពោះទៅព្រះបាទ នឹងស្នាមព្រះបាទទាំងនោះនៃព្រះសក្យមុនី ។

សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ
យោនកបុរេ នម្មទាយ នទីយា
បញ្ចបាទវរំ ឋានំ អហំ វន្ទាមិ ទូរតោ ។

ខ្ញុំសូមនមស្ការអំពីចម្ងាយ នូវស្ថានដែលមានព្រះបាទដ៏ប្រសើរ ៥ កន្លែង គឺ ស្ថានលើភ្នំសុវណ្ណមាលិក ១ លើភ្នំសុវណ្ណបពិត ១ លើភ្នំសុមនកូដ ១ ក្នុងយោនកបុរី ១ ក្បែរស្ទឹងនម្មទា ១ ។

## ពុទ្ធបាទនមស្ការគាថា (ប្រែជាកាព្យ)

វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ
តិលោកកេតុំ តិភវេកនាថំ
យោ លោកសេដ្ឋោ សកលំ កិលេសំ
ឆេត្វាន ពោធេសិ ជនំ អនន្តំ ។

ព្រះសព្វញ្ញុពុទ្ធ វិសេសត្រៃលោកា
គ្មានមនុស្ស ឬ ទេវតា ព្រហ្មមារណាប្រដូចបាន ។
កំចាត់នូវកិលេស គ្មានឱ្យសេសនៅសល់ខាន
ញុំាងជនទាំងប៉ុន្មាន ជាអនន្តឱ្យត្រាស់ដឹង ។
ខ្ញុំសូមថ្វាយបង្គំ នូវព្រះបរមជាទីពឹង
ព្រះអង្គឆ្លងផុតស្ទឹង បានដល់ច្រាំងនៃភពហើយ ។
ព្រះអង្គជាទង់ជ័យ ធំត្រឹយេបង្ហាញត្រើយ
តែមួយព្រះអង្គហើយ ជាទីពឹងក្នុងត្រៃភព ។
មារព្រហ្មទាំងទេពតា នឹងមនុស្សាតែងគោរព
ចូលជ្រកនៅក្រោមម្លប់ ពោធិញ្ញាណបានសុខា ។

យំ នម្មទាយ នទីយា បុលិនេ ច តីរេ
យំ សច្ចពន្ធគិរិកេ សុមនាចលគ្គេ
យំ តត្ថ យោនកបុរេ មុនិនោ ច បាទំ
តំ បាទលញ្ឆនមហំ សិរសា នមាមិ ។

សូមថ្វាយបង្គំ ទសករប្រណម្យ ឆ្ពោះត្រង់ស្នាមព្រះបាទា
ដែលមានព្រះជោគ ទ្រង់ព្រះមេត្តា ជាន់ទុកជាស្លាកថ្លៃ ។
បាទមួយនៅនា ស្ទឹងនម្មទា ត្រង់ឆ្នេរខ្សាច់ប្រសើរក្រៃ
បាទមួយទ្រង់ជាន់ ទុកនៅព្ធ- ដ៏ភ្នំគិរីសច្ចពន្ធ័ ។
បាទមួយនៅភ្នំ សុមនកូដ រហូតកំពូលដ៏សោភ័ណ
ព្រះបាទមួយទៀត ព្រះទ្រង់ជាន់ ទុកនៅនាយោនបុរិ ។
សូមបន្ទន់ កាយវាចា នឹងចិត្តជ្រះថ្លាឱនសិរសី
បង្គំព្រះបាទ ព្រះជិនស្រី សូមសុខសួស្តីគ្រប់វេលា ។

សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ
យោនកបុរេ នម្មទាយ នទីយា
បញ្ចបាទវរំ ឋានំ អហំ វន្ទាមិ ទូរតោ ។

ខ្ញុំសូមនមស្ការអំពីចម្ងាយ នូវឋានទាំងឡាយដែលមានព្រះបាទ
ទាំង ៥ កន្លែង ដែលព្រះមុនីនាថ ទ្រង់ឈានព្រះបាទលើកំពូលភ្នំ ។
សុវណ្ណមាលិកមួយនោះជាធំ មួយនៅលើភ្នំសុវណ្ណបពិត
មួយនៅលើភ្នំសុមនកូដប្រាកដ មួយនៅរាជរដ្ឋយោនកបុរី ។
មួយនៅក្បែរស្ទឹងនម្មទាជលធី ទាំងប្រាំនាទីដែលទ្រង់ប្រទាន
ទុកឱ្យសព្វសត្វប្រតិបត្តិជាស្ពាន ដោយព្រះទ្រង់ញាណប្រទានទុកឱ្យ ។

## នមស្ការធាតុចេតិយ

មហាគោតមសម្ពុទ្ធោ កុសិនារាយ និព្វុតោ
ធាតុវិត្ថារកំ កត្វា តេសុ តេសុ វិសេសតោ ។

ព្រះគោតមបរមសម្ពុទ្ធដ៏ប្រសើរ ព្រះអង្គបរិនិព្វានហើយជិតក្រុងកុសិនារាធ្វើនូវកិរិយាផ្សាយនូវព្រះសារីរិកធាតុ ក្នុងទីទាំងឡាយនោះ ៗ ដោយផ្សេង ៗគ្នា ។

ឧណ្ហីសំ ចតស្សោ ទាឋា អក្ខកា ទ្វេ ច សត្តមា
អសម្ភិន្នា វ តា សត្ត សេសា ភិន្នា វ ធាតុយោ ។

ព្រះសារីរិកធាតុទាំងឡាយនោះ ដែលមិនបែកចេញ មាន ៧ អង្គ គឺព្រះឧណ្ហីសធាតុ ១ ព្រះទាឋធាតុ ៤ ព្រះអក្ខកធាតុ ២ ព្រះសារីរិកធាតុដ៏សេសក្រៅពីនោះសុទ្ធតែបែកចេញ ( ជាចំណែកតូច ៗ )

មហន្តា បញ្ច នាឡិ ច　　មជ្ឈិម ច ឆ នាឡិយោ
ខុទ្ទកា បញ្ច នាឡិ ច　　សម្ភិន្នា តិវិធា មតា ។

ព្រះបរមធាតុទាំងឡាយដែលបែកចេញ លោកពោលថាមាន ៣ យ៉ាងគឺ ព្រះខ្នាតធំវាល់បានចំនួន ៥ នាឡិ ព្រះធាតុខ្នាតកណ្តាលវាល់បានចំនួន ៦ នាឡិ ព្រះធាតុខ្នាតតូចវាល់បានចំនួន ៥ នាឡិ ។

មហន្តា ភិន្នាមុគ្គា ច　　មជ្ឈិមា ភិន្នតណ្ឌុលា
ខុទ្ទកា សាសបមត្តា　　ឯវំ ធាតុប្បមាណិកា ។

ព្រះបរមធាតុទាំងឡាយ មានប្រមាណយ៉ាងនេះគឺព្រះធាតុធំ មានទំហំប៉ុនកំណាត់គ្រាប់សណ្តែកបាយ ព្រះធាតុខ្នាតកណ្តាលមានទំហំប៉ុនគ្រាប់អង្ករ ព្រះធាតុខ្នាតតូចមានទំហំប៉ុនគ្រាប់ស្ពៃ ។

មហន្តា សុវណ្ណវណ្ណា　　មជ្ឈិមា ផលិកប្បតា
ខុទ្ទកា ពកុលវណ្ណា　　តាបិ វន្ទាមិ ធាតុយោ ។

ព្រះបរមធាតុទាំងឡាយ (មានពណ៌ផ្សេងគ្នា យ៉ាងនេះគឺ) ព្រះធាតុខ្នាតធំមានពណ៌ដូចមាស ព្រះធាតុខ្នាតកណ្តាល មានពណ៌ដូចកែវផលិត ព្រះ-ធាតុខ្នាតតូច មានពណ៌ដូចផ្កាថ្កុល ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះបរមធាតុទាំងឡាយនោះ ។

ឯកោ ថូបោ រាជគហេ　　ឯកោ វេសាលិយា អហុ
ឯកោ កបិលវត្ថុស្មឹ　　ឯកោ ច អលកប្បកេ
ឯកោ ច រាមគាមស្មឹ　　ឯកោ ច វេដ្ឋទីបកេ
ឯកោ បាវេយ្យកេ មល្លេ　　ឯកោ ច កុសិនារកេ ។

ព្រះសថូប ១ ព្រះតិស្ឋាននៅក្នុងក្រុងរាជគ្រឹះ ព្រះសថូប ១ ព្រះតិស្ឋាន នៅក្នុងក្រុងវេសាលី ព្រះសថូប ១ ប្រតិស្ឋាននៅក្នុងក្រុងកបិលព័ស្តុ ព្រះសថូប ១ ប្រតិស្ឋាននៅក្រុងអលកប្បកៈ ព្រះសថូប ១ ប្រតិស្ឋាននៅក្នុងរាមគ្រាម ព្រះសថូប ១ ប្រតិស្ឋាននៅក្នុងក្រុងវេដ្ឋទីបកៈ ព្រះសថូប ១ ប្រតិស្ឋាននៅក្នុងក្រុងបាវេយ្យកៈ ក្នុងមល្លរដ្ឋជនបទព្រះសថូប ១ ប្រតិ-ស្ឋាននៅក្នុងក្រុងកុសិនារា ។

ឯតេ សារីរិកា ថូបា　　ជម្ពូទីបេ បតិដ្ឋិតា
បូជិតា នរទេវេហិ　　អហំ វន្ទាមិ ធាតុយោ ។

ព្រះសថូប (ទាំង ៨) នុ៎ះជាព្រះសថូបបញ្ចុះព្រះបរមសារីរិកធាតុប្រតិស្ឋាន នៅក្នុងជម្ពូទីប ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវ ព្រះបរមសារីរិកធាតុ

ទាំងឡាយ (ក្នុងព្រះសថូបទាំង ៨ នោះ) ដែលទេវតា នឹងមនុស្សទាំងឡាយតែងបូជា ។

ឯកា ទាឋា តិទសបុរេ ឯកា នាគបុរេ អហុ
ឯកាគន្ធារវិសយេ ឯកា សីហឡទីបកេ។

ព្រះទាឋធាតុអង្គ១ ប្រតិស្ឋាននៅក្នុងស្ថានត្រ័យត្រឹង្ស ព្រះទាឋធាតុអង្គ១ ប្រតិស្ឋាននៅក្នុងពិភពនាគព្រះទាឋធាតុអង្គ ១ប្រតិស្ឋាននៅក្នុងគន្ធារ រដ្ឋ ព្រះទាឋធាតុអង្គ ១ ប្រតិស្ឋាន ១ ប្រតិស្ឋាននៅក្នុងសីហឡទ្វីប ។

ឥមា ចតូសុ ឋានេសុ សត្ថុ ទាឋា បតិដ្ឋិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ។

ព្រះទាឋធាតុទាំងឡាយនេះ របស់ព្រះបរមសាស្តា ប្រតិស្ឋាននៅក្នុងទីទាំងឡាយ ៤ កន្លែងខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះធាតុទាំង-ឡាយ ដែលទេវតា នឹងមនុស្សទាំងឡាយតែងបូជា ។

ឧទ្ធំ ទក្ខិណទាឋា ច តាវតឹសេ បតិដ្ឋិតា
អធោ ទក្ខិណទាឋា ច សីហឡទីបេ បតិដ្ឋិតា
វាមទាឋា ច ឧទ្ធម្បិ គន្ធាររដ្ឋេ បតិដ្ឋិតា
វាមទាឋា ច អធោបិ នាគលោកេ បតិដ្ឋិតា
បូជិតោ នរទេវេហិ អហំ វន្ទាមិ ធាតុយោ។

ព្រះទាឋធាតុស្តាំខាងលើ ប្រតិស្ឋានក្នុងស្ថានតាវតឹង្ស ព្រះទាឋធាតុស្តាំខាងក្រោយប្រតិស្ឋាន នៅក្នុងសីហឡទ្វីប ព្រះទាឋធាតុឆ្វេងខាងលើ ប្រតិស្ឋាននៅក្នុងដែនគន្ធារៈ ព្រះទាឋធាតុឆ្វេងខាងក្រោម ប្រតិស្ឋានក្នុងពិភពនាគ ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះធាតុទាំងឡាយ ដែលទេវតា នឹង មនុស្សទាំងឡាយតែងបូជា ។

ព្រហ្មលោកេ ទុស្សធាតុ វាមអក្ខកធាតុយោ
សព្វេ ព្រហ្មាភិបូជេន្តិ ថូបំ ទ្វាទសយោជនំ។

ព្រះទុស្សធាតុ និងព្រះអក្ខកធាតុខាងឆ្វេង ប្រតិស្ឋាននៅក្នុងព្រហ្មលោក ព្រហ្មទាំងឡាយទាំងអស់គ្នា តែងបូជាព្រះសថូបកំពស់ ១២ យោជន៍ (ដែលបញ្ចុះនូវព្រះធាតុទាំងនោះ) ។

តាវតឹសម្ហិ ទេវានំ ចូឡាមណិម្ហិ កេសកំ
សព្វេ ទេវាភិបូជេន្តិ បសន្នា ពុទ្ធសាសនេ
បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ។

ទេវតាទាំងឡាយទាំងពួង ដែលជាអ្នកជ្រះថ្លាក្នុងព្រះពុទ្ធសាសនា តែងបូជានូវព្រះកេសធាតុដែលប្រតិស្ឋាននៅក្នុងចូឡាមណីចេតិយ របស់ទេវតាទាំងឡាយក្នុងស្ថានត្រៃត្រឹង្ស ខ្ញុំព្រះករុណាសុំក្រាបថ្វាយបង្គំនូវព្រះធាតុទាំងឡាយដែលទេវតា និង មនុស្សទាំងឡាយតែងបូជា ។

ចត្តាឡីស សមាទន្តា កេសា លោមា នខាបិច
ទេវា ហរន្តិ ឯកេកំ ចក្កវាឡបរម្បរា
បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ។

ព្រះទន្តធាតុទាំងឡាយ ៤០ គត់ផង ព្រះកេសធាតុទាំងឡាយផង ព្រះ-លោមធាតុទាំងឡាយផង ព្រះនខាធាតុទាំងឡាយផង ទេវតាទាំងឡាយនាំទៅនូវព្រះធាតុ ១ អង្គៗកាន់ចក្រវាឡដទៃ គឺព្រះធាតុ ១ អង្គៗ ព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះធាតុទាំងឡាយ ដែលធាតុទាំងឡាយដែលទេវតា និង មនុស្សទាំងឡាយតែងបូជា ។

អដ្ឋារស ទ្វេ វស្សសតេ ធម្មាសោកោ តទា អហុ
ចតុរាសីតិសហស្សា ចេតិយា ច ការាបិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ។

នាកាលព្រះពុទ្ធសករាជបាន ២១៨ ឆ្នាំ មានព្រះមហាក្សត្រ ១ អង្គព្រះនាមធម្មាសោក ក្នុងកាលនោះព្រះអង្គបានកសាងចេតិយ ៨ ហ្មឺន ៤ ពាន់ ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះធាតុទាំងឡាយ (ក្នុងព្រះចេតិយទាំងនោះ) ដែលទេវតា និង មនុស្សទាំងឡាយតែងបូជា ។

## **បត្តិទានគាថា**

យា ទេវតា សន្តិ វិហារវាសិនី
ថូបេ ឃរេ ពោធិឃរេ តហឹ តហឹ
តា ធម្មទានេន ភវន្តុ បូជិតា
សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ
ថេរា ច មជ្ឈា នវកា ច ភិក្ខវោ
សារាមិកា ទានបតី ឧបាសកា
គាមា ច ទេសា និគ្គមា ច ឥស្សរា
សប្បាណភូតា សុខិតា ភវន្តុ តេ
ជលាពុជា យេបិ ច អណ្ឌសម្ភវា
សំសេទជាតា អថ វោបបាតិកា
និយ្យានិកំ ធម្មវរំ បដិច្ចតេ

សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ ។

ឋាតុ ចិរំ សតំ ធម្មោ ធម្មធរា ច បុគ្គលា
សង្ឃោ ហោតុ សមគ្គោ វ អត្ថាយ ច ហិតាយ ច
អម្ហេ រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ
វុឌ្ឍឹ សម្បាបុណេយ្យាម ធម្មារិយប្បវេទិតេ ។

*ប្រែថា:* យា ទេវតា សន្តិ វិហារវាសិនី ថូបេ ឃរេ ពោធិឃរេ តហឹ តហឹ ទេវតាទាំងឡាយឯណា មានប្រក្រតីក្នុងទីវត្ត ជាទីនៅនៃសង្ឃ ឰដ៏ខឿនព្រះសថូប ឰដ៏ខឿនពោធិព្រឹក្សក្នុងទីនោះៗ តា ធម្មទានេន ភវន្តុ បូជិតា ទេវតាទាំងឡាយនោះ ជាបុគ្គលគឺយើងទាំងឡាយបូជាហើយដោយធម្មទាន ,

សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ ចូរធ្វើនូវសួស្តីក្នុងមណ្ឌលនៃវត្តជាទីនៅនៃសង្ឃនេះ ,

ថេរា ច មជ្ឈា នវកា ច ភិក្ខវោ ភិក្ខុទាំងឡាយជាថេរៈក្តី ជាកណ្តាលក្តី ទើបនឹងបួសថ្មីក្តី,

សារាមិកា ទានបតី ឧបាសកា ឧបាសក និង ឧបាសិកាទាំងឡាយដែលជាម្ចាស់នៃទាន ព្រមទាំងអារាមិជន គឺញោមវត្តក្តី,

គាមា ច ទេសា និគមា ច ឥស្សរា ជនទាំងឡាយដែលជាអ្នកស្រុកក្តី ជាអ្នកប្រទេសក្តី ជាអ្នកនិគមក្តី ដែលជាឥស្សរៈជាធំក្តី ,

សប្បាណភូតា សុខិតា ភវន្តុ តេ សត្វទាំងឡាយនោះៗ ចូរឱ្យបានដល់នូវសេចក្តីសុខ ,

ជលាពុជា យេបិ ច អណ្ឌសម្ភវា សំសេទជាតា អថវោបបាតិកា មួយវិញទៀត សត្វទាំងឡាយឯណាដែលជាជលាពុជៈកំណើតក្តី ដែលជាអណ្ឌជៈកំណើតក្តី ដែលជាសំសេទជៈកំណើតក្តី ដែលជាឧបបាតិកៈកំណើតក្តី,

និយ្យានិកំ ធម្មវរំ បដិច្ចតេ សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ សត្វទាំងឡាយទាំងអស់នោះ កាលបើបានអាស្រ័យ នូវធម៌ដ៏ប្រសើរជានិយ្យានិកធម៌ហើយ ចូរធ្វើនូវធម៌ជាគ្រឿងអស់ទៅនៃទុក្ខចុះ ,

ឋាតុ ចិរំ សតំ ធម្មោ សូមឱ្យធម៌របស់សប្បុរសទាំងឡាយស្ថិតនៅអស់កាលយូរអង្វែងទៅ ,

ធម្មធរា ច បុគ្គលា បុគ្គលអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ (ចូរស្ថិតនៅអស់កាលយូរអង្វែងទៅ ),

សង្ឃោ ហោតុ សមគ្គោ វ សូមព្រះសង្ឃព្រមព្រៀងគ្នា

អត្ថាយ ច ហិតាយ ច ដើម្បីសេចក្តីចំរើនផង ដើម្បីសេចក្តីសម្រេចផលប្រយោជន៍ផង ,

អម្ហេ រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ សូមព្រះសទ្ធម្មរក្សានូវយើងទាំងឡាយ សូមរក្សានូវអ្នកដែលប្រព្រឹត្តធម៌ទាំងឡាយទាំងអស់ផង ,

វុឌ្ឍី សម្បាបុណេយ្យាម ធម្មារិយប្បវេទិតេ សូមឱ្យយើងទាំងឡាយបានដល់នូវសេចក្តីចំរើនក្នុងធម៌ ដែលព្រះអរិយៈទាំងឡាយលោកសម្តែងហើយ ។

**គាថានេះសំរាប់សូត្រ**

**ក្នុងកាលចប់ធម៌ទេសនា ឬ សូត្រធម៌ណាចប់ហើយ**

បទពិចារណា

*ជនដែលយើងបញ្ឈឺហើយមិនខឹង ប្រសិនបើមិនមែន*
*ជាអ្នកមានមេត្តា ករុណា ទេនោះ គឺជាជនដែលគួរប្រយ័ត្ន ។*

## ផ្សាយមេត្តាធម៌មួយបែបទៀត

សព្វេ សត្តា អវេរា ហោន្តុ សុខិតា ហោន្តុ
និទ្ទុក្ខា ហោន្តុ អព្យាបជ្ឈា ហោន្តុ
អនីឃា ហោន្តុ ទីឃាយុកា ហោន្តុ
អរោគា ហោន្តុ សម្បត្តីហិ សមិជ្ឈន្តុ
សុខី អត្តានំ បរិហរន្តុ ។
ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ ។

*ប្រែថា:* សព្វេ សត្តា អវេរា ហោន្តុ សូមឱ្យសត្វទាំងឡាយទាំងពួងកុំមានពៀរនឹងគ្នា ។

សុខិតា ហោន្តុ សូមឱ្យបាននូវសេចក្តីសុខ
និទ្ទុក្ខា ហោន្តុ សូមកុំឱ្យមានទុក្ខ
អព្យាបជ្ឈា ហោន្តុ សូមកុំឱ្យបៀតបៀនដល់គ្នានឹងគ្នា
អនីឃា ហោន្តុ សូមកុំឱ្យមានសេចក្តីព្រួយលំបាក
ទីឃាយុកា ហោន្តុ សូមឱ្យមានអាយុវែង

អរោគា ហោន្តុ សូមកុំឱ្យមានរោគ

សម្បត្តីហិ សមិជ្ឈន្តុ សូមឱ្យបានសំរេចនូវសម្បត្តិគ្រប់យ៉ាង

សុខី អត្តានំ បរិហរន្តុ សូមឱ្យរក្សានូវខ្លួនជាសុខស្រួលចុះ

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ ។

មួយទៀត សត្វទាំងឡាយទាំងពួង ដែលដល់ហើយនូវសេចក្តីទុក្ខ សូមឱ្យជាសត្វបាត់សេចក្តីទុក្ខទៅ ដែលដល់ហើយនូវភ័យ សូមឱ្យជាសត្វបាត់ភ័យទៅ ដែលដល់ហើយនូវសេចក្តីសោក សូមឱ្យជាសត្វបាត់សេចក្តីសោកទៅហោង ។

## ផ្សាយមេត្តាធម៌ចំពោះទិសទាំង ១០

សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ មច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ មច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

*ប្រែថា:* សត្វទាំងឡាយទាំងពួង ( ដែលស្ថិតនៅ ) ក្នុងទិសបូពិ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ

សត្វទាំងឡាយទាំងពួង ( ដែលស្ថិតនៅ ) ក្នុងទិសអាគ្នេយ៍ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សត្វទាំងឡាយទាំងពួង ( ដែលស្ថិតនៅ ) ក្នុងទិសទក្សិណ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ

សត្វទាំងឡាយទាំងពួង ( ដែលស្ថិតនៅ ) ក្នុងទិសនិរតី សូមកុំឱ្យមាន

ព្យេរនឹងគ្នា មានតែសេចក្ដីសុខ ។

សព្វេ មច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សត្វទាំងឡាយទាំងពួង ( ដែលស្ថិតនៅ ) ក្នុងទិសបច្ចិម សូមកុំឱ្យមាន ព្យេរនឹងគ្នា មានតែសេចក្ដីសុខ ។

សព្វេ មច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ

សត្វទាំងឡាយទាំងពួង ( ដែលស្ថិតនៅ ) ក្នុងទិសពាយ័ព្យ សូមកុំឱ្យមាន ព្យេរនឹងគ្នា មានតែសេចក្ដីសុខ ។

សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សត្វទាំងឡាយទាំងពួង ( ដែលស្ថិតនៅ ) ក្នុងទិសឧត្តរ សូមកុំឱ្យមាន ព្យេរនឹងគ្នា មានតែសេចក្ដីសុខ ។

សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ

សត្វទាំងឡាយទាំងពួង ( ដែលស្ថិតនៅ ) ក្នុងទិសឦសាន សូមកុំឱ្យមាន ព្យេរនឹងគ្នា មានតែសេចក្ដីសុខ ។

សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សត្វទាំងឡាយទាំងពួង ( ដែលស្ថិតនៅ ) ក្នុងទិសខាងក្រោម សូមកុំឱ្យ មានព្យេរនឹងគ្នា មានតែសេចក្ដីសុខ ។

សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សត្វទាំងឡាយទាំងពួង ( ដែលស្ថិតនៅ ) ក្នុងទិសខាងលើ សូមកុំឱ្យ មានព្យេរនឹងគ្នា មានតែសេចក្ដីសុខ ។

## បត្តិទានគាថា

ឥមិនា បុញ្ញកម្មេន ឧបជ្ឈាយា គុណុត្តរា
អាចរិយូបការា ច មាតាបិតា បិយា មមំ
សុរិយោ ចន្ទិមា រាជា គុណវន្តា នរាបិ ច
ព្រហ្មា មារា ច ឥន្ទ្រា ច លោកបាលា ច ទេវតា
យមោ មិត្តា មនុស្សា ច មជ្ឈត្តា វេរិកាបិ ច
សព្វេ សត្តា សុខី ហោន្តុ បុញ្ញានិ បកតានិ មេ
សុខញ្ច តិវធំ ទេន្តុ ខិប្បំ បាបេថ វោមតំ ។

ឥមិនា បុញ្ញកម្មេន ដោយបុញ្ញកម្មនេះ ឧបជ្ឈាយា គុណុត្តរា ឧបជ្ឈាយ៍ទាំងឡាយ មានគុណដ៏ខ្ពង់ខ្ពស់ក្ដី អាចរិយូបការា ច អាចារ្យទាំងឡាយមានឧបការក្ដី មាតាបិតា បិយា មមំ មាតានិងបិតាជាទីស្រឡាញ់នៃខ្ញុំក្ដី សុរិយោ ចន្ទិមា រាជា ព្រះអាទិត្យ ព្រះចន្ទ័

និង ព្រះរាជាក្តី គុណវន្តា នរាបិ ច មួយវិញទៀត ជនទាំងឡាយដែលជាអ្នកមានគុណក្តី ព្រហ្មា មារា ច ឥន្ទ្រា ច ពួកព្រហ្មក្តី មារក្តី ព្រះឥន្ទ្រទាំងឡាយក្តី លោកបាលា ច ទេវតា ទេវតាទាំងឡាយជាអ្នករក្សានូវលោកក្តី យមោ មិត្តា មនុស្សា ច យមរាជក្តី ពួកមនុស្សជាទីរាប់អានគ្នាក្តី មជ្ឈត្តា វេរិកាបិ ច មួយវិញទៀត សត្វទាំងឡាយដែលមានចិត្តជាឧបេក្ខាក្តី មានពៀរនឹងគ្នាក្តី សព្វេ សត្តា សុខី ហោន្តុ សព្វសត្វទាំងឡាយចូរឱ្យបាននូវសេចក្តីសុខ បុញ្ញានិ បកតានិ មេ បុណ្យទាំងឡាយដែលខ្ញុំបានធ្វើហើយ សុខញ្ច តិវិធំ ទេន្តុ សូមឱ្យបាននូវសេចក្តីសុខទាំង ៣ ប្រការ (គឺសុខក្នុង មនុស្ស, ទេវតា និង ព្រះនិព្វាន) ខិប្បំ បាបេថ វោមតំ អ្នកទាំងឡាយចូរដល់នូវព្រះនិព្វាន ឈ្មោះអមតៈ ដោយឆាប់រួសរាន់ទាន់ចិត្ត ។

## បត្ថនាគាថា

ឥមិនា បុញ្ញកម្មេន ឥមិនា ឧទ្ទិសេន ច
ខិប្បាហំ សុលភេចេវ តណ្ហុប្បាទានឆេទនំ
យេ សន្តានេ ហីនាធម្មា យាវ និព្វានតោ មមំ
នស្សន្តុ សព្វទាយេវ យត្ថ ជាតោ ភវាភវេ
ឧជុចិត្តោ សតិប្បញ្ញោ សល្លេខោ វិរិយោម្ហិ វា
មារា លភន្តុ នោកាសំ កាតុញ្ច វិរិយេសុ មេ
ពុទ្ធោ ទីបវរោ នាថោ ធម្មោ នាថោ វរុត្តមោ
នាថោ បច្ចេកពុទ្ធោ ច សង្ឃោ នាថោត្តរោ មមំ
តេ សោត្តមានុភាវេន មារោកាសំ លភន្តុ មា ។

ឥមិនា បុញ្ញកម្មេន ដោយបុញ្ញកម្មនេះផង ឥមិនា ឧទ្ទិសេន ច ដោយពាក្យឧទ្ទិសនេះផង ខិប្បាហំ សុលភេចេវ តណ្ហុប្បា-ទានឆេទនំ ខ្ញុំគប្បីបានដោយងាយនូវការកាត់ផ្តាច់តណ្ហា និង ឧបទាន ដោយឆាប់រួសរាន់ យេ សន្តានេ ហីនាធម្មា ធម៌ទាំងឡាយណាដែលថោកទាបមានក្នុងសណ្តាន (នៃខ្ញុំ) យាវ និព្វានតោ មមំ នស្សន្តុ សព្វទាយេវ ធម៌ថោកទាបទាំងនោះ ចូរវិនាសទៅ (ចាកសន្តាន) នៃខ្ញុំសព្វៗ កាលដរាបដល់ព្រះនិព្វាន យត្ថ ជាតោ ភវាភវេ ខ្ញុំកើតហើយក្នុងភពតូចនិងភពធំៗ ណាៗ ឧជុចិត្តោ សតិប្បញ្ញោ សល្លេខោ វិរិយោម្ហិ វា សូមឱ្យជាអ្នកមានចិត្ត

ត្រង់ មានស្មារតីនិងប្រាជ្ញា ទាំងសូមឱ្យមានចិត្តផូរផង់ និង សេចក្តីព្យាយាមផង (ក្នុងភពនោះ ៗ) មារា លភន្តុ នោកាសំ កាតុញ្ច វីរិយេសុ មេ មារទាំងឡាយចូរកុំបាននូវឱកាសដើម្បីធ្វើ (នូវសេចក្តីអន្តរាយ) ក្នុងព្យាយាមទាំងឡាយនៃខ្ញុំ ពុទ្ធោ ទីបវរោ នាថោ ព្រះពុទ្ធដូចជាប្រទីបដ៏ប្រសើរ ព្រះអង្គជាទីពឹង (របស់ខ្ញុំ) ធម្មោ នាថោ វរុត្តមោ ព្រះធម៌ឧត្តមបវរជាទីពឹង (របស់ខ្ញុំ) នាថោ បច្ចេកពុទ្ធោ ច ព្រះបច្ចេកពុទ្ធ ក៏ជាទីពឹង (របស់ខ្ញុំ) សង្ឃោ នាថោត្តរោ មមំ ព្រះសង្ឃជាទីពឹងដ៏ប្រសើររបស់ខ្ញុំ តេ សោត្តមានុភាវេន ដោយឧត្តមានុភាពនៃព្រះពុទ្ធ ព្រះធម៌ ព្រះបច្ចេកពុទ្ធ និង ព្រះសង្ឃទាំងឡាយនោះ មារោកាសំ លភន្តុ មា មារចូរ កុំបាននូវឱកាសឡើយ ។

## ខមាបនគាថា

យេកេចិ ខុទ្ទកា បាណា មហន្តាបិ មយា
ហតា យេ បាណេកេ បមាទេន កាយវាចាមនេហិ
វា បុញ្ញំ មេ អនុមោទន្តុ គណ្ហន្តុ ផលមុត្តមំ
វេរិនោ ចេ បមុញ្ចន្តុ សព្វទោសំ ខមន្តុ មេ ។
យេកេចិ ខុទ្ទកា បាណា មហន្តាបិ មយា ហតា

សត្វទាំងឡាយណាមួយ ជាសត្វតូចក្តី ធំក្តី ដែលខ្ញុំសម្លាប់ហើយ យេ បាណេកេ បមាទេន កាយវាចាមនេហិ វា ទោះសត្វទាំងឡាយណាពួកខ្លះ (ដែលខ្ញុំបៀតបៀនហើយ) ដោយកាយ វាចាចិត្ត ព្រោះសេចក្តីប្រមាទ បុញ្ញំ មេ អនុមោទន្តុ (សត្វទាំងនោះ) ចូរអនុមោទនាត្រេកអរចំពោះបុណ្យរបស់ខ្ញុំ គណ្ហន្តុ ផលមុត្តមំ ចូរទទួលយកនូវផលដ៏ឧត្តមចុះ វេរិនោ ចេ បមុញ្ចន្តុ បើ (សត្វទាំងឡាយណា) មានពៀរនឹងគ្នា (សត្វទាំងឡាយនោះ) ចូររួចដោះចាកពៀរនោះទៅ សព្វទោសំ ខមន្តុ មេ សូមសត្វទាំងឡាយអត់ទោសទាំងពួងដល់ខ្ញុំ ។

## គាថាសុំសេចក្តីសុខ

*សូត្រនៅពេលមានសមាទាន ឬ ពេលធ្វើកុសលណាមួយហើយ*

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ សាសនំ ។
អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា

បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ រាជានោ ។
អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ ញាតយោ ។
អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ បាណិនោ ។
អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ នោ សទា ។

ទេវតាទាំងឡាយ ទោះឋិតនៅនាអាកាសក្តី ទោះឋិតនៅលើផែនដីក្តី នាគទាំងឡាយដែលមានឫទ្ធានុភាពច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ ។

សូមរក្សានូវ { ព្រះពុទ្ធសាសនា / ព្រះមហាក្សត្រទាំងឡាយ / ញាតិទាំងឡាយ / សត្វទាំងឡាយ } ឱ្យបានសេចក្តីសុខចំរើន អស់កាលជាយូរអង្វែង

ទៅ សូមរក្សានូវយើងទាំងឡាយ ឱ្យបានសុខចំរើន សព្វៗកាលអស់កាលជាយូរអង្វែងទៅ ។

## តេជៈខ្ញុំសាង

តេជៈខ្ញុំសាង សំអិតសំអាង ដោយកាយវាចា
សូមសុខសុភាព រួចពីទុក្ខា ឆ្លងដល់ត្រើយមហា
ពោលគឺនិព្វាន ។

គ្រប់ជាន់គ្រប់ជាតិ កុំឱ្យខ្ញុំឃ្លាត ពីសីល និង ទាន
គំនិតខ្ញុំកើត កំណើតខ្ញុំមាន មគ្គផលជាស្ពាន
ដល់ស្ថានថ្ងៃថ្លា ។

សូមជូនមគ្គផល ចំពោះទៅដល់ មាតាបិតា
គុណគ្រូឧប- ជ្ឈាយាចារ្យ គុណញាតិកា
ប្រាំពីរសណ្តាន ។

ជីដូនជីតា រស់នៅក្តីណា លោកម្ចាស់ចែកស្ថាន
ខ្ញុំជូនមគ្គផល កុសលថ្កើងថ្កាន សូមសុខក្សេមក្សាន្ត
ដល់ស្ថានផុតទុក្ខ ។

ខ្ញុំសូមសច្ចា កើតជាតិណា។ សូមឱ្យបានសុខ
សូមមានបញ្ញា ភ្លឺថ្លាមុះមុត រួចផុតពីទុក្ខ
ដល់និព្វានហោង ។

## បត្តិទានគាថា

ពុទ្ធសាសនិកជនដែលបានធ្វើកុសលឯណាមួយរួចហើយ បើមានប្រាថ្នានឹងឱ្យចំរើនផលានិសង្សដល់ខ្លួនដ៏ច្រើនឡើងទៀតនោះ គប្បីឧទ្ទិសផ្សាយផលនៃកុសលនោះដល់សត្វទាំងឡាយដោយកុសលចិត្តជាបុញ្ញកិរិយាវត្ថុ ១០ យ៉ាង ដែលហៅថា បត្តិទាន គឺកិរិយាឱ្យនូវចំណែកបុណ្យដល់អ្នកដទៃ ដោយបត្តិទានគាថានេះ ដូច្នេះថា :

យំ កិញ្ចិ កុសលកម្មំ   កត្តព្វំ កិរិយំ មម
កាយេន វាចា មនសា   តិទសេ សុគតំ កតំ
យេ សត្តា សញ្ញិនោ អត្ថិ   យេ ច សត្តា អសញ្ញិនោ
កតំ បុញ្ញផលំ មយ្ហំ   សព្វេ ភាគី ភវន្តុតេ
យេ តំ កតំ សុវិទិតំ   ទិន្នំ បុញ្ញផលំ មយា
យេ ច តត្ថ ន ជានន្តិ   ទេវា គន្ត្វា និវេទយុំ
សព្វេ លោកម្ហិ យេ សត្តា   ជីវន្តាហារហេតុកា
មនុញ្ញំ ភោជនំ សព្វេ   លភន្តុ មម ចេតសាតិ ។

*ប្រែថា :* យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម អំពើជាកុសលឯណាមួយដែលខ្ញុំគប្បីធ្វើ,

កាយេន វាចា មនសា ដោយទ្វារទាំង ៣ គឺកាយវាចាចិត្ត,

តិទសេ សុគតំ កតំ អំពើជាកុសលទាំងអស់នោះ ដែលខ្ញុំបានធ្វើហើយ ជាកុសលអាចនឹងនាំឱ្យទៅកើតក្នុងឋានត្រៃត្រឹង្សសួគ៌បាន,

យេ សត្តា សញ្ញិនោ អត្ថិ សត្វទាំងឡាយឯណា គឺមនុស្ស ឬទេវតា ឬព្រហ្ម ដែលជាសត្វមានសញ្ញាក្តី,

យេ ច សត្តា អសញ្ញិនោ សត្វទាំងឡាយឯណា ជាអសញ្ញិសត្វ គឺសត្វដែលឥតសញ្ញាក្តី,

កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ សត្វទាំងឡាយទាំងអស់នោះ ចូរឱ្យបាននូវចំណែកផលនៃបុណ្យ ហើយចូរសោយផលនៃបុណ្យដែលខ្ញុំបានធ្វើ ហើយបានឧទ្ទិសផ្សាយឱ្យទៅនេះចុះ,

យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា បុណ្យដែលខ្ញុំបានធ្វើហើយនោះ បើសត្វទាំងឡាយឯណាបានដឹងច្បាស់ហើយ សត្វទាំងឡាយនោះ ចូរឱ្យបានសោយនូវផលនៃបុណ្យ ដែលខ្ញុំបានឧទ្ទិសឱ្យទៅនោះចុះ ,

យេ ច តត្ថ ន ជានន្តិ ម្យ៉ាងទៀត បណ្តាសត្វទាំងនោះ បើសត្វទាំងឡាយឯណាមិនបានដឹងនូវបុណ្យដែលខ្ញុំបានធ្វើហើយនោះ ,

ទេវា គន្ធា និវេទយុំ សូមទេវតាទាំងឡាយអញ្ជើញទៅឱ្យដំណឹងដល់សត្វទាំងឡាយនោះឱ្យបានដឹងផង ថាជនឯណោះគេបានធ្វើបុណ្យ ហើយគេឧទ្ទិសផ្សាយផលបុណ្យនោះមកដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរអនុមោទនាត្រេកអរនឹងបុណ្យគេនោះចុះ ,

សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា សត្វឯណាក្នុងលោកទាំងអស់ ដែលអាស្រ័យនូវអាហារ ហើយរស់នៅ ,

មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ សត្វទាំងឡាយទាំងអស់នោះ ចូរឱ្យបាននូវភោជនជាទីគាប់ចិត្ត ដែលសំរេចដោយបុញ្ញឫទ្ធិ តាមចិត្តដែលខ្ញុំឧទ្ទិសផ្សាយទៅឱ្យនេះចុះ ។

***បុគ្គលដែលគួរប្រយ័ត្នបំផុតគឺខ្លួនយើង !***

# បុព្វភាគបដិបត្តិ

បុរសស្ត្រីដែលមានសទ្ធាជ្រះថ្លាក្នុងគុណព្រះរតនត្រ័យ គឺគុណ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ហើយមានប្រាថ្នានឹងប្ដេជ្ញាខ្លួនជាឧបាសក ឬ ជាឧបាសិកា ជាបុព្វភាគប្បដិបត្តិ គឺសេចក្ដីប្រតិបត្តិជាចំណែកខាងដើម ឱ្យបានពេញស័ប់ជាអ្នកកាន់ព្រះពុទ្ធសាសនា ឬ ជាអ្នកតម្កល់នៅក្នុងព្រះពុទ្ធសាសនានោះ , ដំបូងបង្អស់ត្រូវបញ្ចេញវចីភេទ សូមខមាទោសនឹងព្រះរតនត្រ័យ ក្នុងទីចំពោះព្រះភ័ក្ត្រព្រះពុទ្ធរូបក៏បាន ចំពោះមុខបុគ្គល គឺភិក្ខុ ១ រូបក៏បាន ចំពោះមុខគណៈ គឺភិក្ខុ ២ រូប ឬ ៣ រូបក៏បាន ចំពោះសង្ឃ គឺភិក្ខុទាំងឡាយ តាំងពី ៤ រូប ឡើងទៅក៏បាន លុះសូមខមាទោសរួចហើយ ត្រូវបញ្ចេញវចីភេទពោលប្រកាសប្ដេជ្ញាខ្លួនឱ្យជាអ្នកបានដល់ព្រះត្រៃសរណគមន៍ ជាឧបាសក ឬជាឧបាសិកា ក្នុងព្រះពុទ្ធសាសនាជាខាងក្រោយ រួចហើយត្រូវសមាទាននិច្ចសីលរក្សាឱ្យខ្ជាប់តទៅ, បើមានសទ្ធាជ្រះថ្លា ក៏គប្បីរក្សាឧបោសថសីល តាមកាលកំណត់ដែលត្រូវរក្សាម្ដងៗនោះផង នឹង មានផលានិសង្សច្រើន ដោយលំដាប់ៗឡើង ។

ឯពាក្យសូមខមាទោសនឹងព្រះរតនត្រ័យនោះ បើបុរសតែម្នាក់ ឬ ស្ត្រីតែម្នាក់ ត្រូវសូត្រថា :

អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមុឡ្ហំ

យថាអកុសលំ/ យោហំ / យាហំ / ភន្តេ កាយេន វា វាចាយ វា មនសា វា ភគវតោ / ពុទ្ធស្ស វា ធម្មស្ស វា សង្ឃស្ស វា អគារវំ អកាសឹ / តស្ស / តស្សា /មេ ភន្តេ ភគវា / អយ្យោ / អយ្យា / សង្ឃោ / អច្ចយំ អច្ចយតោ / បដិគ្គណ្ហតុ / បដិគ្គណ្ហន្តុ / អាយតឹ សំវរាយ បពិត្រព្រះដ៏មានព្រះភាគ / ព្រះករុណា / ព្រះករុណាទាំងឡាយ / ព្រះសង្ឃ / ដ៏ចំរើន ទោសកំហុសដែលប្រព្រឹត្តកន្លង គ្របសង្កត់ហើយនូវខ្ញុំព្រះករុណា តាមដោយខ្ញុំព្រះករុណា ជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស បពិត្រព្រះដ៏មានព្រះភាគ / ព្រះករុណា / ព្រះករុណាទាំងឡាយ /ព្រះសង្ឃ / ដ៏ចំរើន ក្រែងខ្ញុំព្រះករុណា បានធ្វើហើយនូវសេចក្តីល្មើស មិនគោរពព្រះដ៏មានព្រះភាគ/ ព្រះពុទ្ធជាម្ចាស់ក្តី ដល់ព្រះធម៌ក្តី ដល់ព្រះសង្ឃក្តី ដោយកាយក្តី ដោយវាចាក្តី ដោយចិត្តក្តី បពិត្រព្រះដ៏មានព្រះភាគ / ព្រះករុណា / ព្រះករុណាទាំងឡាយ /ព្រះសង្ឃ / ដ៏ចំរើន សូមព្រះដ៏មានព្រះភាគ/ ព្រះករុណា /ព្រះករុណាទាំងឡាយ / ព្រះសង្ឃ អត់នូវទោសកំហុសនោះដល់ខ្ញុំព្រះករុណាព្រោះអំពើនៃទោសនោះ ជាសេចក្តីខុសពិត ដើម្បីនឹងបានសង្រួម គឺថា នឹងប្រព្រឹត្តល្អតទៅក្នុងខាងមុខនោះហោង ។

រួចបើជាបុគ្គល ឬគណៈ ឬសង្ឃ ដែលនៅជាប្រធាននៅទីនោះត្រូវទទួលថា សាធុ ( ប្រែថា ) ប្រពៃហើយ ។

បើបុរសត្រូវសូត្រថា យោហំ ថា តស្ស មេ, បើស្ត្រីត្រូវសូត្រថា យាហំ ថា តស្សា មេ, តាមគួរដល់បាលីភាសាដែលត្រូវផ្លាស់តាមបុរសស្ត្រី, ទោះបុរសក្តី ស្ត្រីក្តី បើសូមខមាទោសក្នុងទីចំពោះព្រះភក្រ្តព្រះពុទ្ធរូប ឬ ចំពោះនឹងព្រះស្តូប ព្រះចេតិយ ដែលបញ្ចុះព្រះសារីរិកធាតុព្រះសម្មាសម្ពុទ្ធនោះ ត្រូវសូត្រថា ភគវតោ វា ថា ភន្តេ ភគវា បដិគ្គណ្ហតុ, បើចំពោះនឹងភិក្ខុ ១ រូប ត្រូវសូត្រថា ពុទ្ធស្ស វា ថា ភន្តេ អយ្យោ ថា បដិគ្គណ្ហតុ, បើចំពោះគណៈ គឺភិក្ខុ ២ រូប ឬ ៣ រូប ត្រូវសូត្រថា ពុទ្ធស្ស វា ថា ភន្តេ អយ្យា ថា បដិគ្គណ្ហន្តុ បើចំពោះព្រះសង្ឃ ត្រូវសូត្រថា ពុទ្ធស្ស វា ថា ភន្តេ សង្ឃោ ថា បដិគ្គណ្ហតុ, ត្រង់សេចក្តីប្រែក៏មានរបៀបតាមជួរបាលី ដែលខណ្ឌដោយគំនូសទ្រេត ( / ) នោះដែរ ។

បើសុទ្ធតែបុរស ឬ សុទ្ធតែស្ត្រីច្រើននាក់ ឬ បុរសនិងស្ត្រីច្រើននាក់លាយគ្នា តាំងពីពីរនាក់ឡើងទៅ ហើយសូត្រខមាទោសព្រមគ្នានោះ

ត្រូវសូត្រថា ៖

អច្ចយោ នោ ភន្តេ អច្ចគមា /យថាពាលេ/យថាពាលា/ យថាមុឡ្ហេ/ យថាមុឡ្ហា / យថាអកុសលេ / យថាអកុសលា /យេ /យា / មយំ ភន្តេ កាយេន វា វាចាយ វា មនសា វា ភគវតោ ពុទ្ធស្ស វា សង្ឃស្ស វា អគារវំ អករិម្ហា / តេសំ /តាសំ / នោ ភន្តេ / ភគវា / អយ្យោ / អយ្យា / សង្ឃោ / អច្ចយំ / អច្ចយតោ / បដិគ្គណ្ហតុ / បដិគ្គណ្ហន្តុ / អាយតឹ សំវរាយ ។

( សេចក្តីប្រែដូចគ្នានឹងបែបមុន ប្លែកគ្នាតែត្រង់ពាក្យថា " ខ្ញុំព្រះករុណា " នោះ ក្នុងទីនេះត្រឡប់ប្រែថា " ខ្ញុំព្រះករុណាទាំងឡាយ " ដូច្នេះវិញ, ក្រៅ ពីនោះ នៅដូចគ្នាទាំងអស់ ) ។

បើបុរសត្រូវថា យថាពាលេ យថាមុឡ្ហេ យថាអកុសលេ, យេ មយំ ថា តេសំ នោ, បើស្ត្រីត្រូវថា យថាពាលា យថាមុឡ្ហា យថាអកុសលា, យា មយំ ថា តាសំ នោ បើទុកជាគ្នាច្រើន មាន បុរសស្ត្រីលាយគ្នា ហើយសូត្រសូមខមាទោសព្រមគ្នានោះ ក៏ត្រូវតែសូត្រ ខុសគ្នាត្រង់បទដែលខណ្ឌដោយគំនូសទ្រេតនោះដែរ វៀរលែង តែត្រង់បទ ៣ អន្លើ គឺត្រង់បទថា ភគវតោ វា ពុទ្ធស្ស វា, ភគវា អយ្យោ អយ្យា សង្ឃោ, បដិគ្គណ្ហតុ បដិគ្គណ្ហន្តុ នេះត្រូវសូត្រ ដូចគ្នាទាំងបុរសទាំងស្ត្រី តែបើគ្នាច្រើន ហើយសូត្រសូមខមាទោសព្រម ទាំងអស់គ្នានោះ បើមិនបាច់សូត្រដោយពាក្យជាពហុវចនៈតាមបែប ខាងក្រោយនេះ នឹងសូត្រដោយពាក្យជាឯកវចនៈតាមបែបមុននោះក៏ បាន ព្រោះសូត្រសូមខមាទោសព្រមទាំងអស់គ្នា ។

លុះបានសូមខមាទោសនឹងព្រះរតនត្រ័យដូច្នេះរួចហើយ គប្បី បញ្ចេញវចីភេទប្តេជ្ញាខ្លួនជាអ្នកដល់ព្រះត្រៃសរណគមន៍ គឺ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរឭក ដើម្បីនឹងឱ្យឡើងនាមប្បញ្ញត្តិជាឧបា-សក ឬ ជាឧបាសិកាក្នុងព្រះពុទ្ធសាសនាតទៅ, ឯប្តេជ្ញាខ្លួននោះ នឹងប្តេជ្ញា ក្នុងទីចំពោះព្រះភ័ក្ត្រព្រះពុទ្ធរូបក៏បាន ចំពោះព្រះស្តូប ឬព្រះចេតិយ ដែលបញ្ចុះព្រះសារីរិកធាតុព្រះដ៏មានបុណ្យក៏បាន ចំពោះមុខបុគ្គល ឬ គណៈ ឬសង្ឃក៏បាន ។

បើបុរសតែម្នាក់ ឬ ស្ត្រីតែម្នាក់ សូត្រប្តេជ្ញាខ្លួនចំពោះមុខបុគ្គល ឬ គណៈ ឬ សង្ឃនោះ ត្រូវប្តេជ្ញាដោយពាក្យថា ៖

ឯសាហំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច / ឧបាសកំ / ឧបាសិកំ / មំ អយ្យោ / អយ្យា / សង្ឃោ /ធារេតុ / ធារេន្តុ / អជ្ជតគ្គេ បាណុបេតំ សរណំ គតំ ។ *ប្រែថា* បពិត្រ / ព្រះករុណា /ព្រះករុណាទាំងឡាយ / ព្រះសង្ឃ / ដ៏ចំរើន ខ្ញុំព្រះករុណាសូមដល់នូវព្រះដ៏មានព្រះភាគ ដែលទ្រង់បរិនិព្វានទៅអស់កាលយូរអង្វែងហើយ នោះផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក សូមព្រះករុណា /ព្រះករុណាទាំងឡាយ / ព្រះសង្ឃ / ជ្រាបនូវខ្ញុំព្រះករុណាថាជា / ឧបាសក / ឧបាសិកា / បានដល់ហើយនូវព្រះរតនត្រ័យជាទីពឹងជាទីរឭកស្មើដោយជីវិត តាំងពីថ្ងៃនេះ ជាដើមរៀងទៅ ។

រួចបុគ្គលឬគណៈឬសង្ឃ ត្រូវទទួលថា សាធុ (ប្រែដូចមុន) ។

បើបុរសត្រូវថា ឧបាសកំ, បើស្ត្រីត្រូវថា ឧបាសិកំ, ត្រង់ពាក្យថា អយ្យោ ធារេតុ អយ្យា ធារេន្តុ សង្ឃោ ធារេតុ នេះមានសេចក្តីអធិប្បាយដូចក្នុងវិធីសូមខមាទោសខាងដើម ។

បើគ្នាច្រើនតាំងពីពីរនាក់ឡើងទៅ ទោះសុទ្ធតែបុរសក្តី សុទ្ធតែស្ត្រីក្តី បុរសនិងស្ត្រីលាយគ្នាក្តី ត្រូវសូត្រថា :

ឯតេ មយំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច / ឧបាសកេ / ឧបាសិកាយោ / នោ /អយ្យោ /អយ្យា /សង្ឃោ /ធារេតុ /ធារេន្តុ /អជ្ជតគ្គេ / បាណុបេតេ សរណំ គតេ / បាណុបេតា សារណំ គតា ។ សេចក្តីប្រែដូចគ្នានឹងបែបមុន ប្លែកគ្នាតែត្រង់ពាក្យមុនថា " ខ្ញុំព្រះករុណា " នោះក្នុងទីនេះថា " ខ្ញុំព្រះករុណាទាំងឡាយ " ដូច្នេះវិញក្រៅអំពីនេះនៅដូចគ្នាទាំងអស់ ។

បើបុរសតែម្នាក់ ឬស្ត្រីតែម្នាក់ ហើយសូត្រប្តេជ្ញាខ្លួនចំពោះព្រះពុទ្ធរូប ឬព្រះស្តូប ព្រះចេតិយ ដែលបញ្ចុះព្រះសារីរិកធាតុព្រះដ៏មានបុណ្យនោះ ត្រូវពោលប្តេជ្ញាដោយពាក្យថា :

ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ/ ឧបាសិកំ / មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ ។ (*ប្រែថា*) បពិត្រព្រះដ៏មានព្រះភាគដ៏ចំរើន ខ្ញុំព្រះករុណាសូមដល់នូវព្រះដ៏មានព្រះភាគផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក សូមព្រះដ៏មានព្រះភាគទ្រង់ជ្រាបនូវខ្ញុំព្រះករុណាថាជា ឧបាសក/ឧបាសិកា បានដល់ហើយនូវព្រះរតនត្រ័យ

ជាទីពឹងទីរឭកស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅ ។

បើគ្នាច្រើន ក៏ត្រូវសូត្រដូចន័យមុន ខុសគ្នាតែត្រង់ពាក្យថា ភគវន្តំ ថា ភគវា ប៉ុណ្ណោះ , បើគ្នាច្រើន ហើយនឹងសូត្រប្ដេជ្ញាខ្លួនព្រមគ្នាដោយពាក្យជាឯកវចនៈក៏បាន ពោលសូត្រព្រមទាំងអស់គ្នា ។

បុរសឬស្ត្រី កាលបើបានពោលពាក្យប្ដេជ្ញាខ្លួនជាអ្នកបានដល់ព្រះត្រៃសរណគមន៍ជាទីពឹងជាទីរឭកដូច្នេះរួចហើយ ក៏បាននាមបញ្ញត្តិថា "ឧបាសក" ឬ "ឧបាសិកា" ក្នុងខណៈនោះឯង ។

វិធីសូមខមាទេសក្ដី វិធីប្ដេជ្ញាខ្លួនជាឧបាសក ជាឧបាសិកាក្ដី បើអ្នកដែលមិនចេះសូត្រជាបាលី នឹងសូត្រជាសេចក្ដីសំរាយតាមភាសារបស់ខ្លួននោះក៏បាន, បើចេះសូត្រទាំងបាលី ទាំងសេចក្ដីប្រែសំរាយផង ដូចបានពោលមកហើយនោះជាការប្រពៃពិត តែកុំសូត្រតែបាលីទទេ ដោយមិនដឹងថា អ្វីនោះឡើយ ព្រោះកិច្ចដែលសូត្រខមាទោស និង ប្ដេជ្ញាខ្លួននោះ ចំពោះយកសទ្ធា គឺសេចក្ដីជឿជាក់ និង បញ្ញាជាសម្មាទិដ្ឋិដែលដឹងពិត យល់ត្រូវពិតជាប្រមាណ ។

***ចប់បុព្វភាគបដិបត្តិតែប៉ុណ្ណោះ***

# ឧបាសកនិទ្ទេស

## សម្ដែងអំពីនាមថា ឧបាសក និងធម៌
## របស់ឧបាសកផ្សេងៗ មានសីលជាដើម

ជនដែលមាននាមបញ្ញត្តិថា "ឧបាសក" នោះដោយហេតុដែលបានចូលទៅជិតដល់នូវព្រះរតនត្រ័យ ជាទីពឹងជាទីរឭក ដូចពុទ្ធភាសិតដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងចំពោះមហានាមសក្យរាជ ថា "ម្នាលមហានាម គ្រហស្ថឯណាមួយបានដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងជាទីរឭកគ្រហស្ថនោះឯង បានឈ្មោះថា ឧបាសក (បើស្ត្រីហៅថា ឧបាសិកា) " ។

ម្យ៉ាងទៀត មានបាលីថា *រតនត្តយំ ឧបាសតីតិ ឧបាសកោ* ជនឯណាចូលទៅអង្គុយជិតព្រះរតនត្រ័យ ជននោះឈ្មោះថា ឧបាសក ។

អធិប្បាយថា ជនដែលចូលទៅអង្គុយជិតព្រះរតនត្រ័យនោះ គឺមិនមែនជាចូលទៅអង្គុយជិតព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជានិច្ចដោយរូបកាយនោះទេ គឺលោកសង្គ្រោះយកនាមកាយជាប្រមាណ, សូម្បីជននោះស្ថិតនៅក្នុងទីឆ្ងាយប៉ុន្មាន តែមានសន្តានចិត្តប្រព្រឹត្តជាប់នៅក្នុងគុណព្រះរតនត្រ័យជាទីពឹងជាទីរឭកជានិច្ច, ចិត្តនោះតោងឱនយកគុណព្រះរតនត្រ័យ ជាទីពឹងជាទីរឭកជានិច្ច, បើគ្រាន់តែចូលទៅអង្គុយជិត

ព្រះពុទ្ធដោយរូបកាយ តែសន្តានចិត្តនោះស្ថិតនៅក្នុងទីឆ្ងាយអំពីគុណព្រះរតនត្រ័យ មិនបង្អោនចិត្តទៅក្នុងគុណព្រះរតនត្រ័យទេ ជននោះឈ្មោះថា ស្ថិតនៅឆ្ងាយអំពីគុណព្រះរតនត្រ័យ មិនមែនជា" ឧបាសក, ឧបាសិកា" ឡើយ ។

## សីលនៃឧបាសក

បញ្ចវិរតិចេតនា គឺចេតនាដែលវៀរចាកវេរា ៥ ឈ្មោះ ថាជា " សីលនៃឧបាសក " ដូចពុទ្ធភាសិតដែលព្រះបរមគ្រូជាម្ចាស់ទ្រង់ត្រាស់សម្តែងចំពោះមហានាមសក្យរាជថា " *ម្នាលមហានាម ឧបាសកឯណាបានវៀរចាកបាណាតិបាត គឺ មិនសម្លាប់សត្វ ១ វៀរចាកអទិន្នាទាន គឺ មិនលួចទ្រព្យអ្នកដទៃ ១ វៀរចាកកាមេសុមិច្ឆាចារ គឺមិនប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ វៀរចាកមុសាវាទ គឺមិននិយាយកុហក ១ វៀរចាកសុរាមេរយៈ គឺ មិនផឹកនូវសុរានិងមេរ័យ ១ ឧបាសកនោះឈ្មោះ ថា ឧបាសកមានសីល* " ។

## អាជីវៈនៃឧបាសក

កិរិយាលះបង់នូវជំនួញខុស ៥ ប្រការ ហើយប្រកបកិច្ចការចិញ្ចឹមជីវិតដោយត្រឹមត្រូវតាមធម៌ឈ្មោះថា " អាជីវៈនៃឧបាសក " ដូចមានពុទ្ធបញ្ញត្តិ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ហាមចំពោះភិក្ខុទាំងឡាយថា

បញ្ចិមា ភិក្ខវេ វណិជ្ជា ឧបាសកេន អករណីយា ម្នាលភិក្ខុទាំងឡាយ ជំនួញខុសទាំង ៥ ប្រការ ឧបាសកមិនគប្បីធ្វើឡើយ ។

### ជំនួញខុស ៥ ប្រការនោះគឺ

១-សត្ថវណិជ្ជា ជួញគ្រឿងសាស្ត្រាវុធសំរាប់ប្រហារគឺធ្វើគ្រឿងសាស្ត្រាវុធនោះដោយខ្លួនឯង ឬឱ្យអ្នកដទៃគេធ្វើឱ្យ ឬបានមកដោយហេតុឯណាមួយ ហើយលក់នូវគ្រឿងសាស្ត្រាវុធនោះ ។

២-សត្តវណិជ្ជា ជួញមនុស្ស ។

៣-មំសវណិជ្ជា ជួញសាច់ គឺចិញ្ចឹមនូវសត្វទាំងឡាយ មានគោជាដើមលុះដល់សត្វទាំងឡាយនោះចំរើនធំឡើង ក៏សម្លាប់យកសាច់លក់ ។

៤-មជ្ជវណិជ្ជា ជួញទឹកស្រវឹង គឺផ្សំគ្រឿងស្រវឹងឯណាមួយឱ្យកើតឡើងជាទឹកស្រវឹងដោយខ្លួនឯង ឬទិញគេយកមក ហើយលក់នូវទឹកស្រវឹងនោះ ។

៥-វិសវណិជ្ជា ជួញថ្នាំពិស គឺចាត់ចែងផ្សំថ្នាំពិសឱ្យកើតឡើងដោយខ្លួនឯង ឬឱ្យគេផ្សំឱ្យ ឬបានមកដោយហេតុឯណាមួយ ហើយលក់ថ្នាំពិសនោះ ។

ឧបាសក កាលបើវៀរចាកជំនួញខុសទាំង ៥ ប្រការនេះ ហើយបាន

ប្រតិបត្តិការចិញ្ចឹមជីវិតដោយធម៌ ឈ្មោះថាមានអាជីវធម៌ដោយប្រពៃ ។

## វិបត្តិនៃឧបាសក

ធម្មជាតិដែលញុំាងសីល និង អាជីវធម៌នៃឧបាសកឱ្យវិនាសឈ្មោះ ថា វិបត្តិ ។ វិបត្តិនោះមាន ៥ យ៉ាងគឺ :

១-អស្សទ្ធោ ហោតិ ឧបាសកមិនជឿគុណព្រះរតនត្រ័យ ។

២-ទុស្សីលោ ហោតិ ឧបាសកទ្រុស្តសីល ។

៣-កោតុហលមង្គលិកោ ហោតិ ឧបាសកប្រកបដោយមង្គលភ្ញាក់ផ្អើល ។

៤-មង្គលំ បច្ចេតិ នោ កម្មំ ឧបាសកប្រកាន់ជឿថា មង្គលមានឫកពារវេលាជាដើមឱ្យផល មិនប្រកាន់ជឿថាកម្មជាកុសល និង អកុសលឱ្យផលឡើយ ។

៥-ឥតោ ច ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ តត្ថ ច បុព្វការំ ករោតិ ឧបាសកស្វែងរកតែទក្ខិណេយ្យបុគ្គល គឺបដិគ្គាហកៈ អ្នកទទួលទានខាងក្រៅព្រះពុទ្ធសាសនា ហើយធ្វើទានដល់ទក្ខិណេយ្យបុគ្គលខាងក្រៅព្រះពុទ្ធសាសនានោះ ។

ឧបាសកឯណា ប្រកបដោយវិបត្តិ ៥ យ៉ាងនេះ ត្រង់វិបត្តិណាមួយហើយ, ឧបាសកនោះឈ្មោះថា " *ឧបាសកចណ្ឌាល* " គឺឧបាសកដូចជាមនុស្សចណ្ឌាលផង ឈ្មោះថា" *ឧបាសកមលៈ* " គឺឧបាសកមានធម៌ជាមន្ទិលសៅហ្មងផង ឈ្មោះថា " *ឧបាសកបដិកិដ្ឋៈ* " គឺជាឧបាសកដែលអ្នកប្រាជ្ញទាំងឡាយលោកតិះដៀលផង ។

## សម្បត្តិនៃឧបាសក

ធម្មជាតិដែលញុំាងសីល និងអាជីវធម៌នៃឧបាសកឱ្យបរិបូណ៌ឱ្យបរិសុទ្ធប្រពៃ ឈ្មោះថា "សម្បត្តិ " ។ សម្បត្តិនោះមាន ៥ យ៉ាងគឺ :

១-សទ្ធោ ហោតិ ឧបាសកមានសេចក្តីជឿជាក់ច្បាស់ក្នុងគុណព្រះរតនត្រ័យ ។

២-សីលវា ហោតិ ឧបាសកមានសីល ។

៣-ន កោតុហលមង្គលិកោ ហោតិ ឧបាសកមិនប្រកបដោយមង្គលភ្ញាក់ផ្អើល ។

៤-កម្មំ បច្ចេតិ នោ មង្គលំ ឧបាសកប្រកាន់ជឿថាកម្មជាកុសល និង អកុសលឱ្យផល មិនប្រកាន់ជឿថា មង្គលមានឫក្សពារវេលាជាដើមឱ្យផលឡើយ ។

៥-ន ឥតោ ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ ឥធ ច បុព្វការំ ករោតិ ឧបាសកមិនស្វែងរកទក្ខិណេយ្យបុគ្គល គឺបដិគ្គាហកៈ អ្នកទទួលទានខាងក្រៅព្រះពុទ្ធសាសនាឡើយ ហើយធ្វើទានតែក្នុងទក្ខិណេ-យ្យបុគ្គលក្នុងព្រះពុទ្ធសាសនានោះ ។

ឧបាសកឯណា ប្រកបដោយសម្បត្តិ ៥ យ៉ាងនេះហើយ ឧបាសកនោះមានឈ្មោះថា " *ឧបាសករតនៈ* " គឺឧបាសកដូចជារតនវត្ថុមានកែវជាដើមផងឈ្មោះថា " *ឧបាសកបទុមៈ* " គឺឧបាសកដូចជាផ្កាឈូកមានពណ៌ក្រហមផង ឈ្មោះថា " *ឧបាសកបុណ្ឌរីកៈ* " គឺឧបាសកដូចជាផ្កាឈូកមានពណ៌សផង ។

## គុណនៃឧបាសក

ធម៌សំរាប់ឧបាសកឧបាសិកា ប្រតិបត្តិគ្រប់រូប ដើម្បីនឹងឱ្យកើត ឱ្យចំរើននូវសម្បត្តិទាំងពួង ឈ្មោះថា "គុណ "។ គុណនេះជារបស់ឧបាសកឧបាសិកា ហៅថា " ឧបាសកគុណ " មាន ១០ យ៉ាងគឺ :

១-សង្ឃេន សទ្ធឹ សមាន សុខទុក្ខោ ហោតិ ឧបាសកអ្នករួមសេចក្តីសុខទុក្ខមួយអន្លើដោយភិក្ខុសង្ឃ គឺថាបើ ភិក្ខុសង្ឃមានសេចក្តីសុខ ក៏ត្រេកអរ បើ ភិក្ខុសង្ឃមានសេចក្តីទុក្ខព្រួយ ក៏ព្រួយជាមួយផង ។

២-កាយិកវាចសិកញ្ច សុរក្ខិតំ ហោតិ ឧបាសកមានកាយកម្ម និង វចីកម្មរក្សាហើយដោយប្រពៃ ។

៣-ធម្មោ អធិបតេយ្យោ ហោតិ ឧបាសកមានធម៌ជាអធិបតី គឺថាបើ ប្រព្រឹត្តធ្វើអ្វីៗ រមែងកាន់យកធម៌ជាធំ ជាទីតាំង ជាទីអាងមាំមិនឱ្យខុស មិនឱ្យឃ្លៀងឃ្លាតអំពីធម៌ឡើយ ។

៤-យថា ថាមេន សំវិភារតោ វ ហោតិ ឧបាសកជាអ្នកត្រេកអរ ក្នុងការបរិច្ចាគទាន តាមសមគួរដល់កម្លាំងនៃខ្លួន គឺធ្វើទានតាមសមគួរដល់ទ្រព្យសម្បត្តិតិចនិងច្រើន បើមានតិចក៏ធ្វើតិច បើមានច្រើនក៏ធ្វើច្រើន មិនមានមច្ឆរិយធម៌គ្របសង្កត់សន្តានចិត្តឡើយ ។

៥-ជិនសាសនំ ជានិតុញ្ច វាយមតិ ឧបាសកឧស្សាហ៍ព្យាយាមដើម្បីនឹងឱ្យដឹងច្បាស់នូវសាសនៈ គឺពាក្យប្រៀនប្រដៅ ពាក្យបណ្តាំនៃព្រះជិនស្រី ។

៦-សម្មាទិដ្ឋិកោ វ ហោតិ ឧបាសកជាសម្មាទិដ្ឋិ គឺមានប្រាជ្ញាឃើញត្រូវតាមសេចក្តីពិត ។

៧-អបគតោ កោតុហលមង្គលិកោ វ ហោតិ ឧបាសកប្រាសចាកមង្គលភ្ញាក់ផ្អើល ហើយជាអ្នកមិនប្រកាន់ជឿថា មង្គលមាន

ពួកពារវេលាជាដើមឱ្យផលឡើយ ប្រកាន់ជឿតែកម្មជាកុសល និង អកុសលថាឱ្យផល ។

៨-ជីវិតហេតុបិ អញ្ញំ សត្ថារំ ន ឧទ្ទិសតិ ឧបាសកបើទុកជាមានហេតុគួរដល់នូវសេចក្តីវិនាសជីវិតក្តី ក៏មិនលះបង់ព្រះរតនត្រ័យ ហើយត្រឡប់ទៅកាន់យកមនុស្សដទៃជាគ្រូអាចារ្យ ជាទីពឹងរបស់ខ្លួនថា ប្រសើរជាងព្រះរតនត្រ័យនោះឡើយ ។

៩-សមគ្គារាមោ វ ហោតិ ឧបាសកមានសេចក្តីត្រេកអរក្នុងសាមគ្គីធម៌ គឺសេចក្តីព្រមព្រៀងគ្នា។

១០-សាសនេ ចរតិ ឧបាសកប្រព្រឹត្តល្អក្នុងព្រះពុទ្ធសាសនា គឺប្រព្រឹត្តតាមតែធម៌វិន័យជាពុទ្ធសាសនា ។

ឧបាសកគុណទាំង ១០ យ៉ាងនេះ ឧបាសក ឧបាសិកា គប្បីប្រព្រឹត្តតាមកុំឱ្យឃ្លៀងឃ្លាតឡើយ ព្រោះជាធម៌អាចនឹងធ្វើចិត្តឧបាសក ឧបា-សិកា អ្នកប្រព្រឹត្តឱ្យសុចរិតផូរផង់ក្នុងព្រះពុទ្ធសាសនា ហើយឱ្យបានជាបច្ច័យនៃនិព្វានសម្បត្តិផង ។

**(ចប់ឧបាសកនិទ្ទេស ដោយសង្ខេបប៉ុណ្ណេះ)**

# វិធីសមាទាននិច្ចសីល

ពុទ្ធសាសនិកជនដែលបានដល់ព្រះត្រៃសរណគមន៍ បានឡើងនាមបញ្ញត្តិជាឧបាសក ឬ ឧបាសិកាហើយ កាលបើនឹងសមាទាននូវនិច្ចសីលគឺសីល ៥ ជាបច្ចេកសមាទានអំពីបុគ្គលដទៃគឺភិក្ខុឬ សាមណេរនោះ គប្បីសូធ្យនមស្ការថ្វាយបង្គំរឭកដល់គុណព្រះរតនត្រ័យ ដោយសង្ខេបជាមុនរួចហើយត្រូវសូមនូវនិច្ចសីល ព្រមទាំងព្រះត្រៃសរណគមន៍ចំពោះនឹងភិក្ខុ ឬ សាមណេរ ដែលខ្លួននឹងសមាទាននោះថា

ឧកាស/អហំ/មយំ/ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ/យាចាមិ/យាចាម,

ទុតិយម្បិ/អហំ/មយំ /ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ/យាចាមិ/ យាចាម ។

តតិយម្បិ/អហំ/មយំ /ភន្តេ... ។

*ប្រែថា* សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា/ខ្ញុំព្រះករុណាទាំងឡាយ/សូមនូវសីលទាំងឡាយ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ/ សូមនូវសីល

ទាំងឡាយ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នាជាគម្រប់ពីរដងផង ជាគម្រប់បីដងផង ។

*ឬនឹងសូមថា* ឧកាស/អហំ/មយំ/ភន្តេ/ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ/ យាចាមិ/ យាចាម/អនុគ្គហំ កត្វា សីលំ ទេថ/មេ/នោ/ភន្តេ

ទុតិយម្បិ / អហំ / មយំ / ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ/ យាចាមិ/ យាចាម/អនុគ្គហំ កត្វា សីលំ ទេថ/មេ/នោ /ភន្តេ។

តតិយម្បិ / អហំ / មយំ / ភន្តេ ... ។

*ប្រែថា* សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា/ ខ្ញុំព្រះករុណាទាំងឡាយ/ សូមនូវនិច្ចសីលប្រកបព្រមដោយអង្គ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះឱ្យនូវសីលដល់ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ, បពិត្រព្រះករុណាដ៏ចម្រើនខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ/សូមនូវនិច្ចសីលសីលប្រកបព្រមដោយអង្គ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា ជាគម្រប់ពីរដងផង ជាគម្រប់បីដងផង, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះឱ្យនូវសីលដល់ខ្ញុំព្រះករុណា /ខ្ញុំព្រះករុណាទាំងឡាយ ។

(សូមដូច្នេះក៏បាន តាមសេចក្តីពេញចិត្តរបស់អ្នកសូម) ។

បើអ្នកសមាទានតែម្នាក់ ត្រូវថា អហំ ថា យាចាមិ ត្រង់ប្រែត្រូវថា "ខ្ញុំព្រះករុណា" សូម ថា មេ ត្រង់ប្រែត្រូវថា " ដល់ខ្ញុំព្រះករុណា "បើគ្នាច្រើនតាំងពីពីរនាក់ឡើងទៅ នឹងសូមតែម្នាក់ថា មយំ ថា យាចាម ក៏បាន ត្រង់ប្រែត្រូវថា " ខ្ញុំព្រះករុណាទាំងឡាយ " សូមថា នោ ត្រង់ប្រែត្រូវថា " ដល់ខ្ញុំព្រះករុណាទាំងឡាយ ", តែថាបើគ្នាច្រើនសូធ្យសូមព្រមគ្នានោះ នឹងសូធ្យសូមថា អហំ ថា យាចាមិ ថា មេ ក៏បាន ព្រោះសូធ្យសូមទាំងអស់គ្នា,លុះសូមដូច្នេះរួចហើយ លោកអ្នកឱ្យសីលលោកសូធ្យ នមោ ៣ ចប់ ហើយលោកឱ្យព្រះត្រៃសរណគមន៍ និងនិច្ចសីល, អ្នកសមាទានត្រូវទទួលថាតាមលោក ដោយបញ្ចេញវចីភេទឱ្យឮច្បាស់លាស់, កុំទទួលខ្សឹបៗ ។

លោកសូធ្យថា: នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។ (៣ ដង)

*ប្រែថា* កិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

ពុទ្ធំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹងទីពួក ។

ធម្មំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីពឹងទីពួក ។

សង្ឃំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹងទីពួក ។

ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីពួក ជាគម្រប់ពីរដងផង ។

ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីពួក ជាគម្រប់ពីរដងផង ។

ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃជាទីពឹងទីពួក ជាគម្រប់ពីរដងផង ។

តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធជាទីពឹងទីពួក ជាគម្រប់បីដងផង ។

តតិយម្បិ ធម្មំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវព្រះធម៌ជាទីពឹងទីពួក ជាគម្រប់បីដងផង ។

តតិយម្បិ សង្ឃំ សរណំ គច្ឆាមិខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃជាទីពឹងទីពួក ជាគម្រប់បីដងផង ។

ហើយលោកថា តិសរណគ្គហណំ បរិបុណ្ណំ (ប្រែថា) កិរិយាកាន់យកនូវព្រះត្រៃសរណគមន៍បរិបូណ៌តែប៉ុណ្ណេះ ។ ហើយលោកឱ្យនិច្ចសីលជាបច្ចេកសមាទានថា :

បាណាតិបាតា វេរមណីសិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង គឺសត្វស្លាប់ ។

អទិន្នាទានា វេរមណីសិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឱ្យដោយកាយ ឬ ដោយវាចា ។

កាមេសុ មិច្ឆាចារា វេរមណីសិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តិខុសក្នុងកាមទាំងឡាយ ។

មុសាវាទា វេរមណីសិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ។

រួចហើយលោកអ្នកអោយសីល លោកពោលដាស់តឿនក្រើនរំឮកថា

ឥមានិ បញ្ច សិក្ខាបទានិ សាធុកំ កត្វា អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ *(ប្រែថា)* អ្នក/អ្នកទាំងឡាយគប្បី ធ្វើនូវសិក្ខាបទទាំងឡាយ ៥ នេះឱ្យប្រពៃត្រូវរក្សាឱ្យល្អអស់កាលជានិច្ចដោយសេចក្តីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។

បើអ្នកសមាទានតែម្នាក់ ត្រូវថា " អ្នក " បើគ្នាច្រើនត្រូវថា "អ្នកទាំងឡាយ" ។

អ្នកសមាទានទទួលថា អាម ភន្តេ (ប្រែដូចមុន) ហើយលោកសម្តែងអានិសង្សសីលឱ្យស្តាប់តទៅនេះទៀតថា :

សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា
សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។

*(ប្រែថា)* សត្វទាំងឡាយទៅកាន់ឋានសួគ៌បានក៏ព្រោះសីល សត្វទាំងឡាយបានបរិបូណ៌ដោយភោគៈក៏ព្រោះសីល សត្វទាំងឡាយបានទៅកាន់ទីរំលត់ទុក្ខគឺព្រះនិព្វានក៏ព្រោះសីល ព្រោះហេតុនោះ បុគ្គលជាសប្បុរសគប្បីជម្រះនូវសីលឱ្យបរិសុទ្ធ កុំឱ្យសៅហ្មង ។

អ្នកសមាទានត្រូវទទួលថា សាធុ (ប្រែថា) ប្រពៃហើយ ។

**វិធីសមាទាននិច្ចសីលជាបច្ចេកសមាទាន**
**ចប់តែប៉ុណ្ណេះ**

## វិធីសមាទានឧបោសថសីល

ឧបាសក ឧបាសិកា ជាអ្នករក្សានូវឧបោសថសីល កាលបើដល់ថ្ងៃជិតនឹងរក្សានូវឧបោសថសីល គឺថ្ងៃមុន ១ ថ្ងៃ ដែលកំនត់ថាព្រឹកឡើងនឹងរក្សានូវឧបោសថសីលនោះ គប្បីចាត់ចែងការងារដែលគួរនឹង

ចាត់ចែងមានវិធីចាត់ចែងនូវអាហារជាដើម ដែលជាការងារគឺខ្លួននឹងត្រូវធ្វើឬនឹងត្រូវប្រើឱ្យគេធ្វើក្នុងថ្ងៃស្អែក គឺក្នុងថ្ងៃឧបោសថកាល ឱ្យហើយក្នុងថ្ងៃនោះមុនតែកុំចាត់ចែង ការងារដែលមិនប្រកបដោយធម៌ ដែលជាការងារគឺខ្លួនជា ឧបាសក ឧបាសិកា មិនគួរនឹងចាត់ចែងនោះឡើយលុះដល់ព្រឹកឡើងជាថ្ងៃឧបោសថ កាលត្រូវរក្សានូវឧបោសថសីល គប្បីភ្ញាក់ឡើងអំពីព្រលឹម ហើយខ្ពុរមាត់ជម្រះធ្មេញឱ្យស្អាត រួចហើយបើបានសមាទាននូវឧបោសថសីលក្នុង វេលានោះក៏ជាការប្រពៃ បើឃើញថានឹងសមាទានពី ព្រលឹមនោះមិនទាន់ទេ ក៏គប្បីកំណត់នូវឧបោសថកាលគឺកាលជាទីរក្សានូវឧបោសថសីលក្នុង ១ ថ្ងៃ ១ យប់ នោះដោយបញ្ចេញវាចាអធិដ្ឋានថា :

អជ្ជ ឧបោសថោ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ ឧបោសថិកោ / ឧបោសថិកា / ភវិស្សាមិ *ប្រែថា* ថ្ងៃនេះជាថ្ងៃត្រូវរក្សានូវឧបោសថសីល, ខ្លួនអញនឹងជាអ្នករក្សានូវឧបោសថសីលអស់ថ្ងៃនេះ និង យប់នេះ ។

បើឧបាសក ត្រូវថា ឧបោសថិកោ, បើឧបាសិកា ត្រូវថា ឧបោសថិកា។

បើមិនចេះបាលី នឹងអធិដ្ឋានតាមភាសារបស់ខ្លួនៗ ក៏គួរដោយពិត, លុះអធិដ្ឋានកំណត់កាលដូច្នេះរួចហើយ ត្រូវតាំងវិរតិចេតនាវៀរចាកសីលភេទ គឺហេតុដែលជាទីទម្លាយនូវសីលនោះៗ ឱ្យគ្រប់សិក្ខាបទទាំង ៨,កាលបើអធិដ្ឋានដូច្នេះរួចហើយ តអំពីពេលនោះមក ក៏គប្បីសមាទាននូវ ឧបោសថសីលអំពីបុគ្គលដទៃ មានភិក្ខុជាដើម តាមកាលដែលគួរចុះ បើទុកជាដល់ព្រះអាទិត្យរះខ្ពស់ឡើងប្រមាណពេញពន្លឺធំ ទើបបានសមាទានក្ដី ក៏ឈ្មោះថាបានសមាទានដោយប្រពៃ ឈ្មោះថាបានរក្សានូវឧបោសថសីលពេញកាលកំណត់ ១ ថ្ងៃ ១ យប់ ដោយបរិបូណ៌ ព្រោះអ្នកសមាទានបានធ្វើនូវឧបោសថកាលមិនឱ្យខ្វះខាត ទាំងវិរតិចេតនាសោត ក៏កើតគ្លាបរិបូណ៌ ក្នុងសន្ដាន នឹងបានផលានិសង្សច្រើន។

កាលបើឧបាសក ឧបាសិកា នឹងសមាទាននូវឧបោសថសីលប្រកបព្រមដោយអង្គ ៨ ជាបច្ចេកសមាទានអំពីបុគ្គលដទៃគឺភិក្ខុ ឬ សាមណេរនោះ គប្បីសូធ្យនមស្ការនូវឧបោសថសីល ព្រមទាំងព្រះត្រៃសរណគមន៍ចំពោះភិក្ខុ ឬ សាមណេរ ដែលខ្លួននឹងសមាទាននោះថា :

ឧកាស / អហំ / មយំ/ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ

តិសរណេន សហ អដ្ឋ សីលានិ / យាចាមិ / យាចាម

ទុតិយម្បិ / អហំ / មយំ / ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ

តិសរណេន សហ អដ្ឋ សីលានិ/យាចាមិ /យាចាម ។

តតិយម្បិ / អហំ / មយំ / ភន្តេ ...។

ប្រែដូចក្នុងវិធីសូមនិច្ចសីលខាងដើម ប្លែកគ្នាត្រង់ពាក្យថា អដ្ឋ សីលានិ (*ប្រែថា*) នូវសីលទាំងឡាយ ៨ ។

ឬនឹងសូមថា ឧកាស / អហំ / មយំ / ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ / យាចាមិ / យាចាម / អនុគ្គហំ កត្វា សីលំ ទេថ / មេ / នោ / ភន្តេ ។

ទុតិយម្បិ / អហំ / មយំ / ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ / យាចាមិ / យាចាម / អនុគ្គហំ កត្វា សីលំ ទេថ/មេ / នោ / ភន្តេ។

តតិយម្បិ / អហំ / មយំ / ភន្តេ...។

*ប្រែថា* សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា/ខ្ញុំព្រះករុណាទាំងឡាយ/សូមនូវ ឧបោសថសីល ប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនៅសេចក្តីអនុគ្រោះឱ្យនូវសីលដល់ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ, បពិត្រព្រះករុ-ណាដ៏ចម្រើនខ្ញុំព្រះករុណា/ ខ្ញុំព្រះករុណាទាំងឡាយ/ សូមនូវឧបោសថ-សីល ប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា ជាគម្រប់ពីរដងផង ជាគម្រប់បីដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនៅសេចក្តីអនុគ្រោះឱ្យនូវសីលដល់ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ ។

សូមដូច្នេះក៏បាន តាមសេចក្តីពេញចិត្តរបស់អ្នកសូម ។ សេចក្តីអធិប្បាយអំពីអ្នកសូមតែម្នាក់ និង ច្រើននាក់នោះ ដូចគ្នានឹងវិធីសូមនិច្ចសីលខាងដើម ។

រួចហើយលោកអ្នកឱ្យសីល លោកតាំង នមោ ៣ ចប់ ហើយឱ្យព្រះត្រៃសរណគមន៍, អ្នកសមាទានត្រូវទទួលថាតាមលោក ដូចវិធីសមាទាននិច្ចសីលខាងដើម, រួចហើយលោកឱ្យនូវឧបោសថសីល ជាបច្ចេកសមាទានថា :

បាណាតិបាតា វេរមណីសិក្ខាបទំ សមាទិយាមិ

ប្រែដូចនិច្ចសីល ។

អទិន្នាទានា វេរមណីសិក្ខាបទំ សមាទិយាមិ

ប្រែដូចនិច្ចសីល ។

អព្រហ្មចរិយា វេរមណីសិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តិនូវធម៌មិនប្រសើរ គឺសេពនូវមេថុនធម្ម ។

មុសាវាទា វេរមណីសិក្ខាបទំ សមាទិយាមិ

ប្រែដូចនិច្ចសីល ។

សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណីសិក្ខាបទំ សមាទិយាមិ ប្រែដូចនិច្ចសីល ។

វិកាលភោជនា វេរមណីសិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាបរិភោគនូវភោជនាហារក្នុងកាលខុស ។

នច្ចគីតវាទិតវិសូកទស្សនមាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណីសិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយារាំ និង ច្រៀង និងប្រគំនិងមើលនូវល្បែង ដែលជាសត្រូវដល់កុសលធម៌និងកិរិយាទ្រទ្រង់ និង ប្រដាប់និងតាក់តែងស្អិតស្អាងរាងកាយដោយផ្កាកម្រងនិងគ្រឿងក្រអូបនិងគ្រឿងលាបផ្សេងៗ ។

ឧច្ចាសយនមហាសយនា វេរមណីសិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកទីសេនាសនៈដ៏ខ្ពស់ហួសប្រមាណ និង ទីសេនាសនៈដ៏ប្រសើរ ។

រួចហើយអ្នកសមាទាន សូត្យកំណត់ឧបោសថកាលថា :

ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ

*ប្រែថា* ខ្ញុំព្រះករុណា សូមសមាទាននូវឧបោសថសីល ដ៏ប្រកបព្រមដោយអង្គ ៨ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់បញ្ញត្តទុកហើយនេះ ដើម្បីនឹងរក្សាឱ្យបរិបូណ៌ប្រពៃ អស់កាលកំណត់ថ្ងៃនេះ និងយប់នេះ សូមកុសលចូរជាឧបនិស្ស័យធ្វើឱ្យច្បាស់នូវព្រះនិព្វាន ព្ធដ៏អនាគតទៅឯមុខនោះហោង ។

បាលីនេះគ្រាន់តែជាពាក្យ សម្រាប់ពោលកំណត់កាលឱ្យដឹងថាឧបោសថសីលទាំង ៨ សិក្ខាបទនេះ អ្នកសមាទានត្រូវរក្សាតែត្រឹម ១ ថ្ងៃ១យប់នោះប៉ុណ្ណោះ, ហេតុនេះ បើអ្នកសមាទានបានចេះដឹងច្បាស់ប្រាកដក្នុងឧបោសថកាលហើយ មិនបាច់សូត្យក៏បាន, តែបើទុកជាចេះ

ដឹងច្បាស់ប្រាកដហើយ នឹងសូធ្យបាលីនេះ ព្រមទាំងសេចក្ដីប្រែផងនោះ ក៏ជាការប្រពៃណាស់ ជាហេតុនាំឱ្យរឹតតែចេះស្ទាត់ប្រាកដទាំងអស់គ្នាឡើង ។

រួចហើយ លោកអ្នកឱ្យសីល លោកពោលដាស់តឿនក្រើនរំឭកថាៈ

ឥមានិ អដ្ឋ សិក្ខាបទានិ ឧបោសថសីលវសេន ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សាធុកំ កត្វា អប្បមាទេន សម្មារក្ខិតព្វំ

*ប្រែថា* អ្នកទាំងឡាយគប្បីធ្វើនូវសិក្ខាបទទាំឡាយ ៨ នេះឱ្យប្រពៃ ត្រូវរក្សាឱ្យល្អដោយអំណាចនៃឧបោសថសីល អស់កាលកំណត់ត្រឹម ១ ថ្ងៃ ១ យប់នេះ ដោយសេចក្ដីមិនប្រមាទ គឺកុំបីធ្វេសប្រហែសឡើយ ។

អ្នកសមាទាន ត្រូវទទួលថា អាម ភន្តេ (ប្រែដូចមុន) ។

ហើយលោកសម្ដែងអានិសង្សសីលឱ្យស្ដាប់តទៅទៀតថា :

សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា

សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។

(ប្រែដូចមុន)

អ្នកសមាទានត្រូវទទួលថា សាធុ (ប្រែដូចមុន) ។

កិកីវ អណ្ឌំ ចមរីវ វាលធឹ

បិយំវ បុត្តំ នយនំវ ឯកកំ

តថេវ សីលំ អនុរក្ខមានកា

សុបេសលា ហោថ សទា សគារវា ។

" សត្វត្រដេវរិចរក្សានូវស៊ុតវា យ៉ាងណាមិញ សត្វចាមរីរក្សានូវកន្ទុយវាយ៉ាងណាមិញ មាតារក្សានូវកូនប្រុសតែមួយ យ៉ាងណាមិញ ជនមានភ្នែកម្ខាងរក្សានូវភ្នែក យ៉ាងណាមិញ អ្នកទាំងឡាយកំពុងរក្សាសីលជាអ្នកមានសីលជាទីស្រឡាញ់ ក្រៃលែង ចូលជាអ្នកប្រកបដោយសេចក្ដីគោរពសីល ឱ្យបានសព្វកាល ក៏យ៉ាងនោះដែល" ។

អ្នកសមាទានត្រូវទទួលថា សាធុ (ប្រែដូចមុន) ។

**វិធីសមាទានឧបោសថសីលជាបច្ចេកសមាទាន**
**ចប់តែប៉ុណ្ណេះ**

## ឯកជ្ឈសមាទាន

បើឧបាសក ឧបាសិកា នឹងសមាទាននិច្ចសីល ជាឯកជ្ឈសមាទាន ព្រមទាំងព្រះត្រៃសរណគមន៍ផងនោះ ត្រូវសូមដូច្នេះ :

ឧកាស / អហំ / មយំ / ភន្តេ តិសរណេន សហ ឯកជ្ឈំ កត្វា បញ្ចង្គសមន្នាគតំ និច្ចសីលំ / យាចាមិ / យាចាម/ អនុគ្គហំ កត្វា សីលំ ទេថ / មេ /នោ / ភន្តេ,

ទុតិយម្បិ / អហំ / មយំ / ភន្តេ តិសរណេន សហ ឯកជ្ឈំ កត្វា បញ្ចង្គសមន្នាគតំ និច្ចសីលំ / យាចាមិ /យាចាម / អនុគ្គហំ កត្វា សីលំ ទេថ / មេ /នោ / ភន្តេ។

តតិយម្បិ / អហំ / មយំ / ភន្តេ... ។

*ប្រែថា* សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា/ខ្ញុំព្រះករុណាទាំងឡាយ/សូមនូវនិច្ចសីលប្រកបព្រមដោយអង្គ ៥ ធ្វើឱ្យជា ឯកជ្ឈៈ គឺសមាទានតែម្តង មួយអន្លើដោយព្រះត្រៃសរណគមន៍ បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះឱ្យនូវសីលដល់ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ, បពិត្រព្រះ ករុណាដ៏ចម្រើនខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ/សូមនូវនិច្ចសីល សីលប្រកបព្រមដោយអង្គ ៥ ធ្វើឱ្យជា ឯកជ្ឈៈ គឺសមាទានតែម្តងមួយអន្លើដោយព្រះត្រៃសរណគមន៍ ជាគម្រប់ពីរដងផង ជាគម្រប់បីដងផង, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះឱ្យនូវសីលដល់ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ ។

រួចលោកអ្នកឱ្យសីល លោកតាំង នមោ ៣ ចប់រួចហើយលោកឱ្យព្រះត្រៃសរណគមន៍,រួចប្រាប់អំពីកិច្ចកាន់យកនូវ ព្រះត្រៃសរណគមន៍ដូចក្នុងវិធីបច្ចេកសមាទានខាងដើម រួចហើយលោកឱ្យនិច្ចសីលជាឯកជ្ឈសមាទានថា :

បញ្ចង្គសមន្នាគតំ និច្ចសីលំ សមាទិយាមិ *(ប្រែថា)* ខ្ញុំព្រះករុណា សូមសមាទាននូវនិច្ចសីល ប្រកបព្រមដោយអង្គ ៥។

អ្នកសមាទានត្រូវទទួលថាតាមលោក ឬ លោកនឹងឱ្យថា បញ្ចសីលានិ សមាទិយាមិ *(ប្រែថា)* ខ្ញុំព្រះករុណា សូមសមាទាននូវនិច្ចសីល ទាំងឡាយ ៥ ដូច្នេះក៏បាន។ អ្នកសមាទាន ត្រូវទទួលថាតាមលោក រួចហើយលោកពោលដាស់តឿនក្រើនរំលឹកថា :

ឥមំ បញ្ចង្គសមន្នាគតំ និច្ចសីល សាធុកំ កត្វា អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ *(ប្រែថា)* អ្នក/អ្នកទាំង

ឡាយ/គប្បីធ្វើនូវនិច្ចសីលប្រកបព្រមដោយ អង្គ ៥ នេះឱ្យប្រពៃ ត្រូវរក្សាឱ្យល្អ អស់កាលជានិច្ច ដោយសេចក្តីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។

អ្នកសមាទានត្រូវទទួលថា អាម ភន្តេ *(ប្រែដូចមុន)* រួចហើយលោកសម្តែងអានិសង្សសីលឱ្យស្តាប់តទៅទៀត ដូចក្នុងវិធីបច្ចេកសមាទានខាងដើម ។

សមាទានតែប៉ុណ្ណេះ ក៏ជាការស្រេច ឥតមានសូធ្យញែកឈ្មោះសិក្ខាបទទាំង ៥ រាយមួយម្តងៗ ដូចបច្ចេកសមាទាននោះឡើយ,សមាទានតែប៉ុណ្ណេះហើយ ត្រូវរក្សាដោយតាំងវិរតិចេតនា វៀរឱ្យគ្រប់សិក្ខាបទក្នុងនិច្ចសីលទាំង ៥ ដែលខ្លួនបានចេះចាំស្ទាត់ហើយនោះទៅ ។

បើឧបាសក ឧបាសិកា នឹងសមាទានឧបោសថសីលជាឯកជ្ឈសមាទានព្រមទាំងព្រះត្រៃសរណគមន៍ផងនោះ ត្រូវសូមដូច្នេះថា :

ឧកាស / អហំ / មយំ / ភន្តេ តិសរណេន សហ ឯកជ្ឈំ កត្វា អដ្ឋង្គសមន្នាគតំ ឧបោសថំ/ យាចាមិ /យាចាម/ អនុគ្គហំ កត្វា សីលំ ទេថ / មេ /នោ / ភន្តេ,

ទុតិយម្បិ / អហំ / មយំ / ភន្តេ តិសរណេន សហ ឯកជ្ឈំ កត្វា អដ្ឋង្គសមន្នាគតំ ឧបោសថំ/ យាចាមិ/យាចាម/ អនុគ្គហំ កត្វា សីលំ ទេថ / មេ /នោ / ភន្តេ ,

តតិយម្បិ / អហំ / មយំ / ភន្តេ...។

ប្រែដូចវិធីប្រែសូមនិច្ចសីលជាឯកជ្ឈសមាទានខាងដើម ប្លែកគ្នាតែត្រង់បទថា អដ្ឋង្គសមន្នាគតំ ឧបោសថំ *(ប្រែថា)* នូវឧបោសថសីលប្រកបព្រមដោយអង្គ ៨ ប៉ុណ្ណោះក្រៅពីនោះដូចគ្នាទាំងអស់។

រួចលោកអ្នកឱ្យសីល លោកតាំង នមោ ៣ ចប់ ហើយឱ្យព្រះត្រៃសរណគមន៍, រួចប្រាប់អំពីកិច្ចកាន់យកនូវព្រះត្រៃសរណគមន៍ ដូចន័យមុន រួចហើយលោកឱ្យឧបោសថសីលជាឯកជ្ឈសមាទានថា :

អដ្ឋង្គសមន្នាគតំ ឧបោសថំ សមាទិយាមិ *(ប្រែថា)* ខ្ញុំព្រះករុណា សូមសមាទាននូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨។ អ្នកសមាទាន ត្រូវទទួលថាតាមលោក ឬ លោកនឹងឱ្យថា អដ្ឋ សីលានិ សមាទិយាមិ *(ប្រែថា)* ខ្ញុំព្រះករុណា សូមសមាទាននូវសីលទាំងឡាយ ៨ ដូច្នេះក៏បាន, អ្នកសមាទាន ត្រូវទទួលថាតាមលោករួចហើយ អ្នកសមាទាន សូធ្យកំណត់ឧបោសថកាលថា :

ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ

(ប្រែដូចមុន) ។

*រួចហើយលោកពោលដាស់តឿនក្រើនរំឭកថា :*

ឥមំ អដ្ឋង្គសមន្នាគតំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សាធុកំ កត្វា អប្បមាទេន សម្មារក្ខិតព្វំ (ប្រែថា) អ្នក/អ្នកទាំងឡាយ/ គប្បីធ្វើឧបោសថសីលប្រកបព្រមដោយអង្គ ៨ នេះដោយប្រពៃ ត្រូវរក្សាឱ្យល្អអស់កាលកំណត់ ត្រឹម ១ ថ្ងៃ ១ យប់នេះ ដោយសេចក្តីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។

អ្នកសមាទានត្រូវទទួលថា អាម ភន្តេ *(ប្រែដូចមុន)*។ ហើយលោកសម្តែងអានិសង្សសីលឱ្យស្តាប់តទៅទៀតដូចន័យមុន។

សមាទានតែប៉ុណ្ណេះ ក៏ជាការស្រេច ឥតមានសូធ្យញែកឈ្មោះសិក្ខាបទទាំង ៨ រាយមួយម្តង១ ដូចបច្ចេកសមាទាននោះឡើយ,សមាទានតែប៉ុណ្ណោះហើយ ត្រូវរក្សាដោយតាំងវិរតិចេតនាវៀរឱ្យគ្រប់សិក្ខាបទទាំង ៨ ក្នុងឧបោសថសីល ដែលខ្លួនបានចេះចាំស្ទាត់ហើយនោះទៅ។

**វិធីសមាទានសីលជាឯកជ្ឈសមាទាន**

**ចប់តែប៉ុណ្ណោះ**

សូម្បីតែឧបាសក ឧបាសិកា នឹងអធិដ្ឋាននិច្ចសីល ឬ ឧបោសថសីលដោយខ្លួនឯងក្តី ក៏គប្បីបញ្ចេញវចីភេទអធិដ្ឋាន តាមបែបជាបច្ចេកៈ ឬជាឯកជ្ឈៈ ដូចបានពោលមកហើយនោះចុះ ។

ត្រង់វិធីដែលលោកសម្តែងអានិសង្សសីល ឱ្យអ្នកសមាទានស្តាប់នោះបើលោកអ្នកឱ្យសីល លោកឈ្លាស ចេះចាំច្រើនហើយអាចនឹងសម្តែងក្នុងពេលនោះបាន ក៏គួរនឹងសម្តែងតាមន័យប្លែក១ ដោយអាងលើព្រះពុទ្ធភាសិតឱ្យនាក់សមាទានស្តាប់នោះ ក៏ជាការប្រពៃក្រៃពេក អ្នកសមាទានបានស្តាប់ហើយ ក៏នឹងកើតមានសេចក្តីជ្រះថ្លា ព្រមទាំងចម្រើនសតិបញ្ញាដោយក្រៃលែងឡើងទៀត ហើយនឹងមានផលានិសង្សច្រើនដល់លោកអ្នកឱ្យសីល និងអ្នកសមាទាន ។

**ចប់វិធីសមាទានសីលតែប៉ុណ្ណោះ**

## អង្គនៃនិច្ចសីល

### បាណាតិបាត មានអង្គ ៥

១. បាណោ សត្វមានជីវិត ។

២. បាណសញ្ញិតា សេចក្តីដឹងថាសត្វមាជីវិត។

៣. វធកចិត្តំ គិតនឹងសម្លាប់ ។

៤. ឧបក្កមោ ព្យាយាមនឹងសម្លាប់ ។

៥. តេន មរណំ សត្វស្លាប់ដោយព្យាយាមនោះ ។

### អទិន្នាទាន មានអង្គ ៥

១-បរបរិគ្គហិតំ ទ្រព្យដែលមានម្ចាស់របស់គេហួងហែងរក្សា។

២-បរបរិគ្គហិតសញ្ញិតា សេចក្តីដឹងថា ទ្រព្យមានម្ចាស់ របស់គេហួងហែងរក្សា ។

៣-ថេយ្យចិត្តំ គិតនឹងលួច ។

៤-ឧបក្កមោ ព្យាយាមនឹងលួច ។

៥-តេន ហរណំ លួចបានមកដោយព្យាយាមនោះ ។

### កាមេសុ មិច្ឆាចារៈ មានអង្គ ៤

១-អគមនីយដ្ឋានំ ស្ត្រីដែលមិនគួរនឹងគប់រក គឺស្ត្រីដែលមានគេហួងហែងរក្សា ។

២-តស្មិំ សេវន ចិត្តំ គំនិតនឹងសេពនូវមេថុនធម្មនឹងស្ត្រីនោះ។

៣-ឧបក្កមោ ព្យាយាមនឹងសេពនូវមេថុនធម្មនោះ។

៤-មគ្គេន មគ្គប្បដិបាទនំ ញ៉ាំងមគ្គនិងមគ្គឱ្យដល់គ្នា។

### មុសាវាទៈ មានអង្គ ៤

១-អតថំ វត្ថុ វត្ថុមិនពិត ។

២-វិសំវាទនចិត្តំ គិតនឹងពោលឱ្យខុស ។

៣-តជ្ជោ វាយាមោ ព្យាយាមនឹងពោលឱ្យខុស ។

៤-បរស្ស តទត្ថវិជាននំ ញ៉ាំងអ្នកដទៃឱ្យដឹងច្បាស់នូវសេចក្តីនោះ ។

### សុរាមេរយៈ មានអង្គ ៤

១-មជ្ជនីយវត្ថុ វត្ថុជាទីតាំងនៃសេចក្តីស្រវឹង គឺសុរា និងមេរ័យ ។

២-បាតុកម្យតាចិត្តំ  គិតបំរុងនឹងផឹក ។

៣-តជ្ជោ  វាយាមោ  ព្យាយាមនឹងផឹកនូវទឹកស្រវឹងនោះ ។

៤-តស្ស  បានំ បានផឹកនូវទឹកស្រវឹងនោះឱ្យកន្លងបំពង់កចូលទៅ ។

## អង្គនៃឧបោសថសីល

អង្គនៃ  បាណាតិបាត  និង  អទិន្នាទាន  ដូចនិច្ចសីលខាងដើម

### អព្រហ្មចរិយៈ  មានអង្គ  ៤

១-ភេទនវត្ថុ  វត្ថុជាទីទម្លាយនូវសីល គឺទ្វារទាំង ៣០ ចំពោះត្រង់ទ្វារណាមួយ ។

២-សេវនចិត្តំ  គិតនឹងសេព ។

៣-តជ្ជោ  វាយាមោ  ព្យាយាមនឹងសេពនូវមេថុនធម្ម នោះ ។

៤-មគ្គេន  មគ្គប្បដិបាទនំ  ញ៉ាំងមគ្គ  និង  មគ្គឱ្យដល់គ្នា ។

អង្គនៃ  មុសាវាទ  និង  សុរាមេរ័យ ដូចនិច្ចសីលខាងដើម ។

## វិកាលភោជនៈ  មានអង្គ  ៣

១-វិកាលោ  កាលខុសគឺព្រះអាទិត្យជ្រេរទៅហើយដរាបទល់នឹងអរុណរះ ។

២-យាវកាលិកំ  របស់ដែលគួរបរិភោគបានក្នុងកាលគឺតាំងពីអរុណរះឡើងដរាបដល់ថ្ងៃត្រង់ ។

៣-អជ្ឈោហរណំ  បានលេបចូលទៅក្នុងបំពង់ក ។

នច្ចគីតៈ  ព្រមទាំង  មាលា

រួមគ្នាជាសិក្ខាបទ  ១  មានអង្គ  ៦

១-នច្ចគីតាទិ  ការលែងល្បែងមានរាំ និង ច្រៀងជាដើម ។

២-កត្តុកម្យតាចិត្តំ  គិតបំរុងនឹងធ្វើ ។

៣-សុតទស្សនត្ថាយគមនំ  ទៅដើម្បីនឹងស្តាប់  ឬមើល ហើយបានស្តាប់ ឬមើល ។

៤-មាលាទិ  វត្ថុសម្រាប់ប្រដាប់កាយ មានកម្រងផ្កា ជាដើម ។

៥- ធារណច្ឆន្ទតា  សេចក្តីប្រាថ្នាក់នឹងប្រដាប់តាក់តែ ។

៦-តស្ស  ធារណំ  បានប្រដាប់តាក់តែនូវវត្ថុសម្រាប់  ប្រដាប់

កាយមានផ្កាកម្រងជាដើមនោះ ។

**ឧច្ចាសយនៈ មានអង្គ ៣**

១-ឧច្ចាសយនមហាសយនំ ទីដេកទីអង្គុយដ៏ខ្ពស់ដ៏ប្រសើរ ហួសប្រមាណ ។

២-បរិភោគចិត្តំ គិតនឹងដេក ឬ អង្គុយ ។

៣-បរិភោគករណំ បានដេក ឬ អង្គុយ ។

កាលបើឧបាសក ឧបាសិកា ប្រព្រឹត្តឱ្យកន្លងនូវសិក្ខាបទ ណាៗ លុះតែព្រមដោយអង្គក្នុងសិក្ខាបទនោះៗ ទើបបានឈ្មោះកន្លង, បើមិនទាន់ព្រមដោយអង្គនោះ ក៏មិនបានឈ្មោះថា កន្លងនូវសិក្ខាបទនោះៗ ឡើយ ។

**អង្គនៃនិច្ចសីល និងឧបោសថសីល**
**ចប់តែប៉ុណ្ណេះ**

# ឧបោសថកាលសង្ខេប

ឧបោសថកម្មរបស់ឧបាសក ឧបាសិកាបើពោលដោយកាលដែលជាទីរក្សានូវឧបោសថសីលនោះ មានពីរប្រការគឺ បកតិឧបោសថ ១ បដិជាគរឧបោសថ ១ ។ ឧបោសថកម្មដែលប្រព្រឹត្តទៅដោយប្រក្រតី គឺឧបោសថកម្មដែលអ្នកប្រាជ្ញទាំងឡាយ លោកធ្វើមកហើយអំពីដើម ឈ្មោះថា " បកតិឧបោសថ " ឧបោសថកម្មនៃបុគ្គលភ្ញាក់រឭករឿយៗ គឺរឭកដល់ឧបោសថសីល ដែលជាកុសល គឺខ្លួនត្រូវសន្សំ ឈ្មោះថា "បដិជាគរឧបោសថ " ។

ឯកាលនៃបកតិឧបោសថនោះ ក្នុង ១ ខែមាន ៨ ថ្ងៃគឺថ្ងៃចំណែកខាងសុក្កបក្ខ (ខ្នើត) ៤ថ្ងៃ ខាងកាឡបក្ខ (រនោច) ៤ថ្ងៃ គឺត្រង់ថ្ងៃ ៥កើត ៨កើត, ១៤កើត ១៥កើត, ៥រោច ៨រោច ១៤រោច ១៥រោច បើខែខ្វះត្រង់ថ្ងៃ១៤រោច ថយមក១៣រោចវិញ, ត្រង់ថ្ងៃ ១៥រោច ថយមក១៤រោចវិញ, ក្នុងមួយខែមានកាលនៃបកតិឧបោសថ ៨ថ្ងៃ ដូច្នេះ។

កាលនៃបដិជាគរឧបោសថនោះ ក្នុង១ខែមាន ១១ថ្ងៃ គឺត្រង់ថ្ងៃ ៤កើត ៦កើត ៧កើត ៩កើត ១៣កើត ១រោច ៤រោច ៦រោច ៧រោច ៩រោច ១៣រោច បើខែខ្វះ ត្រង់ថ្ងៃ១៣រោច ថយមក ១២រោចវិញ, ថ្ងៃទាំង១១ ក្នុងខែមួយៗនេះជាថ្ងៃខាងដើម និងខាងចុងនៃបកតិឧបោ-

សថ ឬ ថាជាថ្ងៃអមនៃបកតិឧបោសថ គឺជាកាលនៃបដិជាគរឧបោសថថ្ងៃឯទៀត ក្រៅអំពីបកតិឧបោសថ និង បដិជាគរឧបោសថនោះមាន ១១ថ្ងៃ គឺត្រង់ថ្ងៃ១កើត(១) ២កើត ៣កើត ១០កើត ១១កើត ១២កើត, ២រោច ៣រោច ១០រោច ១១រោច ១២រោច, បើខែខ្វះមានតែ១០ថ្ងៃព្រោះត្រង់ថ្ងៃ១២រោច ទុកជាថ្ងៃបដិជាគរឧបោសថ, ថ្ងៃទាំង ១១ ឬ ១០នេះមិនមែនជាកាលនៃឧបោសថណាមួយឡើយ គ្រប់ខែទាំងអស់ ។

នឹងអធិប្បាយពីកិច្ចដែលនឹងធ្វើនូវឧបោសថកម្ម គឺបកតិឧបោសថ និងបដិជាគរឧបោសថ ជាសេចក្តីខ្លីៗបន្តិច គ្រាន់ជាទីចំណាំសំគាល់របស់ឧបាសក ឧបាសិកាទាំងឡាយក្នុងព្រះពុទ្ធសាសនា, ឯបកតិឧបោសថកម្ម នោះគឺឧបោសថសីល ដែលឧបាសក ឧបាសិកា ត្រូវទទួលសមាទានកាន់រក្សានូវសិក្ខាបទទាំង ៨ ក្នុងបកតិឧបោសថកាល កំណត់ត្រឹមតែ១ថ្ងៃ ១យប់តាមលំដាប់កាលនៃបកតិឧបោសថនោះ, ឯបដិជាគរឧបោសថនោះ គឺឧបោសថសីលដែលឧបាសក ឧបាសិកាត្រូវដុសខាត់សំអាតចិត្ត នឹងរំលឹកដល់សិក្ខាបទទាំង ៨ ដែលជាអង្គនៃឧបោសថសីល តែឧបាសក ឧបាសិកាមិនត្រូវ សមាទានឡើយ គ្រាន់តែបណ្តោះចិត្តឱ្យឃ្លាតឆ្ងាយអំពីកាមគុណ ៥ ហើយបំរុងចាំដំណើរនៃបកតិឧបោសថសីល គឺគ្រាន់តែតាំងចិត្តវៀរគ្រប់សិក្ខាបទទាំង ៨ មានបាណាតិបាតជាដើម ដូចជារក្សានូវឧបោសថសីលក្នុងថ្ងៃបកតិឧបោសថកាលនោះដែរ, ប្លែកគ្នាតែមិនសមាទាន និង សមាទានតែប៉ុណ្ណោះ គឺថាបដិជាគរឧបោសថនោះ មិនមានសមាទានទេ គ្រាន់តែតាំងចិត្តវៀរគ្រប់សិក្ខាបទដែលត្រូវវៀរអស់ថ្ងៃ១ យប់១ ជាកំណត់, ឯបកតិឧបោសថសីលនោះត្រូវសមាទានទទួលកាន់យកនូវសិក្ខាបទទាំង ៨ រក្សាអស់ថ្ងៃ១ យប់១ នោះដែរ, វេលាដល់គ្រប់កំណត់កាលបកតិឧបោសថសីលថយទៅហើយ ត្រូវតាំងចិត្តទៅជូនដំនើរនៃឧបោសថសីលនោះអស់ថ្ងៃ១ យប់១ទៀត គឺតាំងចិត្តវេរគ្រប់សិក្ខាបទទាំង ៨ តែមិនបាច់ទទួលសមាទានទេ គឺគ្រាន់តែញ៉ាំងចិត្តឱ្យប្រព្រឹត្តទៅតាមបកតិឧបោសថសីល ដែលខ្លួនទទួលសមាទានអំពីថ្ងៃម្សិលប៉ុណ្ណោះឯង ។

ឯបកតិឧបោសថកាលនោះ កាលព្រះសម្មាសម្ពុទ្ធគង់ធរមាននៅឡើយ ព្រះអង្គសំដែងទុកថា ក្នុង១ខែមាន៦ ថ្ងៃ : ខាងខ្នើត ៣ ថ្ងៃ ខាងរនោច ៣ថ្ងៃ គឺត្រង់ថ្ងៃ ៨ កើត ៨រោច ហៅថា " អដ្ឋមីឧបោសថ" ១៤កើត ១៤រោច ហៅថា " ចាតុទ្ទសីឧបោសថ " ១៥កើត ១៥ រោច ហៅថា "បណ្ណរសីឧបោសថ ", បើខែខ្វះ ត្រង់ថ្ងៃ១៥រោច ត្រូវថយចុះមកថ្ងៃ១៤រោចវិញ, លុះដល់ព្រះអង្គចូលបរិនិព្វានទៅបាន ៣ ខែព្រះអរហន្តទាំងឡាយ ៥០០ អង្គ មានព្រះអង្គមហាកស្សបត្ថេរជាដើម លោកប្រជុំ

(១) ក្នុងសូត្រខ្លះមានសំដែងថា : ថ្ងៃ ១ កើត ក៏រាប់ថា ជាបដិជាគរឧបោសថ ។

គ្នាធ្វើបឋមសង្គាយនាផ្ទៀងផ្ទាត់ធម៌វិន័យ លោកយល់ឃើញថា នៅរយាលថ្ងៃខាងដើមនោះពេកណាស់, ទើបលោកលើកយកថ្ងៃ ៥កើត ៥ រោចមកកំណត់ទុកជាថ្ងៃបកតិឧបោសថផង រួមគ្នាជាឧបោសថកាលក្នុង ១ខែ៧ មាន ៨ថ្ងៃ ព្រោះត្រង់ថ្ងៃ ៥កើត ៥រោចជាថ្ងៃឧបោសថកាលដែរ ហៅថា " បញ្ចមីឧបោសថ " ។

**ចប់ឧបោសថកាលដោយ**
**សង្ខេបតែប៉ុណ្ណោះ**

**<u>ពុទ្ធភាសិត</u>**

*បុគ្គលនៅកំលោះមានកម្លាំង តែមិនព្យាយាម នៅក្នុងពេលដែលត្រូវព្យាយាម បានចូលដល់ភាពជាអ្នកខ្ជិលច្រអូស មានចិត្តត្រិះរិះធ្លាក់ចុះហើយ ខិលច្រអូសនឹងមិនជួបប្រទះនូវផ្លូវនៃបញ្ញាឡើយ ។*

# ការវេតព្វកិច្ច

ឧបាសក ឧបាសិកា បានទទួលនូវសមាទានឧបោសថសីលក្នុងថ្ងៃឧបោសថកាលនោះរួចហើយ ហើយចង់ឱ្យបានផលានិសង្សច្រើនក្នុងថ្ងៃនោះ ក្នុងយប់នោះ ត្រូវសង្រួមកាយវាចាឱ្យបានសមគួររៀបរយតាមពុទ្ធានុញ្ញាតទុកមក ។

ឯការសង្រួមកាយឱ្យបានសមគួរនោះ គឺត្រូវលះបង់នូវគ្រឿងសៅហ្មងដល់ព្រហ្មចារិយសីល ដែលខ្លួនបានសមាទាន ហើយក្នុងថ្ងៃនោះយប់នោះ ។ សង្រួមវាចាឱ្យបានសមគួរនោះ គឺត្រូវលះបង់តិរច្ឆានថាទាំង ៣២ យ៉ាងមាននិយាយអំពីបាយ ថាអាក្រក់ល្អជាដើម ហើយគួរប្រកបពោលនូវពាក្យជាទីសប្បាយ ១៣ ប្រការ មានពោលអំពីសីល ៥ សីល ៨ និង អានិសង្សនៃសីល ៥ សីល ៨, អំពីសមាធិកម្មដ្ឋានទាំង ៤០, អំពីវិបស្សនាបញ្ញាជាដើម ។

បើបានសង្រួមកាយវាចាសមគួរហើយ, ក្នុងថ្ងៃនោះ យប់នោះត្រូវស្តាប់ធម៌ទេសនា ឬធ្វើនូវធម្មសាកច្ឆា គឺសាកសួរអំពីធម៌, បើមិនបានស្តាប់ធម៌នោះទេត្រូវសង្រួមចិត្ត គឺតាំងចម្រើននូវកម្មដ្ឋានក្នុងសមថកម្មដ្ឋានទាំង ៤០ ប្រការត្រង់កម្មដ្ឋានណាមួយក៏បាន ។ ឯកម្មដ្ឋានទាំង ៤០ នោះមានសេចក្តីពិស្តារក្នុងគម្ពីរវិសុទ្ធិមគ្គបាលី ឬ សម្រាយ ត្រង់សមាធិ

និទ្ទេស ជានិទ្ទេសទី ២, ក្នុងទីនេះមិនបានសំដែងអំពីកម្មដ្ឋានទាំងនោះដោយសព្វគ្រប់ទេ គ្រាន់តែប្រាប់របៀប និង ធម៌ដែលត្រូវចម្រើន នោះខ្លះប៉ុណ្ណោះ ។ ព្រះពុទ្ធភាសិតសំដែងថា " អ្នកដែលនឹងចម្រើននូវកម្មដ្ឋានទាំង ៤០ ប្រការត្រង់កម្មដ្ឋានណាមួយក្តី នោះត្រូវចម្រើននូវមូលកម្មដ្ឋានគឺពុទ្ធានុស្សតិកម្មដ្ឋានជាមុនសិន ហើយទើបឱ្យចម្រើននូវកម្មឯទៀតតទៅតាមគួរដល់អធ្យាស្រ័យ " ។

វិធីដែលនឹងចំរើននោះ ដូច្នេះ :

ឧបាសក ឧបាសិកា មុននឹងចំរើនកម្មដ្ឋាននោះ ត្រូវពិចារណានូវទោសនៃកាមគុណឱ្យឃើញច្បាស់ថា រូប សម្លេង ក្លិន រស ផោដ្ឋព្វៈទាំង ៥ នេះរមែងឱ្យកើតទោសទុក្ខផ្សេងៗ ឬនឹងពិចារណានូវខន្ធ ៥ ឱ្យថាជាអនិច្ចំ ទុក្ខំ អនត្តា គឺឱ្យឃើញថា រូបក្ខន្ធនេះមិនទៀង មិនតាំងនៅតែវិនាសទៅដោយហេតុផ្សេងៗ មានវិនាសដោយចំហាយក្តៅ នឹងត្រជាក់ជាដើម រូបនេះរមែងនាំមកនូវសេចក្តីទុក្ខព្រួយ, រូបនេះរមែងបែកធ្លាយជាធម្មតា រកខ្លឹមសារគ្មានសោះឡើយ ឯវេទនាខន្ធ សញ្ញាខន្ធសង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ សោតក៏ជា អនិច្ចំ ទុក្ខំ អនត្តា ដូចគ្នានឹងរូបក្ខន្ធនោះដែរ ។

ម្យ៉ាងទៀត គប្បីពិចារណាធម៌ដែលជាទីសង្វេគនោះថា ជនទាំងឡាយដែលកើតមកហើយក្នុងលោកនេះ រកទីពឹងពំនាក់ឱ្យមាំមួននោះ ពុំមានសុទ្ធតែជាអ្នកកំព្រាម្នាក់ឯង មានមាតាបិតា ស្វាមីភរិយា កូន ប្រុស-ស្រី មិត្តសម្លាញ់ មានទ្រព្យសម្បត្តិ ក៏ទុកដូចជាគ្មាន ព្រោះថាជនទាំងឡាយមានមាតាបិតា ជាដើមនោះ មិនអាចនឹងបែងចែកសេចក្តីសុខទុក្ខឱ្យដល់គ្នានឹងគ្នាបានឡើយ, មិនអាចនិងជួយការពារ ឬជូនដំណើរគ្នាទៅក្នុងកាល ដែលមរណសង្គ្រាមមកដល់ចំពោះរូបនីមួយៗនោះបានឡើយ ពេលដែលមរណសង្គ្រាមមកដល់ខ្លួន សត្វទាំងអស់ក៏ជាអ្នកឥតមានគ្នីគ្នាឡើយ, បើប្រទះបានសេចក្តីទុក្ខ ដែលកើតអំពីអកុសលកម្មដែលខ្លួនធ្វើហើយក្នុងកាលមុនស្លាប់នោះ ក៏ត្រូវតែទទួលយកនូវសេចក្តីទុក្ខនោះដោយឆាប់រហ័ស ឬ បើប្រទះបានសេចក្តីសុខដែលជាផលនៃកុសលកម្ម ដែលខ្លួនបានសាងល្អមកហើយ ក្នុងពេលមុនស្លាប់នោះក៏ត្រូវទទួលរងនូវសេចក្តីសុខនោះដោយបរិបូណ៌ ចំពោះតែខ្លួនមួយប៉ុណ្ណោះ ទោះខ្លួនមានទ្រព្យសម្បត្តិក្នុងលោកនេះតិចច្រើន ប៉ុន្មានៗក្តីក៏មិនអាចយកទៅផងបានឡើយ ។

កាលបើឧបាសក ឧបាសិកា បានពិចារណាដូច្នេះហើយ ក៏នឹងឃើញថា មនុស្សសត្វប្រុសស្រីទាំងអស់នឹងរកគ្នីគ្នាមកជាទីពឹងពំនាក់ឱ្យបានមាំមួននោះ ពុំមានឡើយ, ឃើញតែគុណទាំងឡាយ មានព្រះពុទ្ធ

ព្រះធម៌ ព្រះសង្ឃ និង ទាន សីល ភាវនា ជាដើមនេះឯង ទើបជាទីពឹងដ៏វិសេស អាចនឹងជួយឧបត្ថម្ភគាំពារទំនុកបំរុងក្នុងកាលដែលមច្ចុសង្គ្រាមមកដល់ផ្តាច់ផ្តិលនូវជីវិតិន្ទ្រិយ៍របស់សត្វទាំងពួងនោះ ឱ្យបានសុខស្រួលរៀងរាបដរាបទៅដល់លោកខាងមុខទៀតបាន ។

ឧបាសក ឧបាសិកា កាលបើបានពិចារណាឃើញសេចក្តីយ៉ាងនេះហើយក៏នឹងមានចិត្តឱនទៅកាន់ ពុទ្ធគុណ ធម្មគុណ សង្ឃគុណ,បើឃើញថាចិត្តរបស់ខ្លួនឱនទៅកាន់ គុណព្រះរតនត្រ័យហើយគប្បីពិចារណានូវព្រះនាមរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទាំង ១០ ព្រះនាម មាន " អរហំ " ជាដើមឱ្យបានកើតសេចក្តីជ្រះថ្លាក្នុងនាមទាំងនោះហើយ គប្បីលើកឡើងនូវព្រះនាមទាំងនោះមកភាវនាគឺថា យកគុណទាំងនោះ មកនឹករំពឹងតែក្នុងចិត្តម្យ៉ាងមិនបានបញ្ចេញវាចាឱ្យលាន់ឮឡើយ ។

ឯកិច្ចដែលនឹងអង្គុយចម្រើនភាវនានោះ ក្នុងបាលីដែលជាពុទ្ធភាសិត បង្គាប់ថាអង្គុយពែនជើង ហើយធ្វើកាយឱ្យត្រង់ល្មមស្រួលហើយបែរមុខឱ្យចំទៅខាងមុខ តម្កល់ស្មារតីឱ្យនឹងនៅក្នុអារម្មណ៍ដែលបំរុងនឹងលើកឡើងមកកាន់វិធីភាវនានោះ ។

វិធីដែលនឹងភាវនាធម៌នោះ មាន ៣ យ៉ាងគឺ :

១.ឱ្យរំពឹងថា ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ ។ល។ ពុទ្ធោ ភគវាតិ ហើយត្រឡប់មកតាំងនឹករំពឹងខាងដើមទៅទៀតរំពឹងយ៉ាងនេះ ទោះ១រយចប់ ឬ១ ពាន់ចប់ក៏បាន តាមកំលាំងសទ្ធា ។

២. នឹងនឹករំពឹងថា សោ ភគវា ឥតិបិ អរហំ សោ ភគវា ឥតិបិ សម្មាសម្ពុទ្ធោ សោ ភគវា ឥតិបិ វិជ្ជាចរណសម្បន្នោ ។ល។ សោ ភគវា ឥតិបិ ភគវា ហើយត្រឡប់មកតាំងនឹករំពឹងពីខាងដើមទៅទៀតនឹករំពឹងយ៉ាងនេះបាន ១រយចប់ ឬ ១ពាន់ចប់ក៏បាន។

៣.នឹងនឹករំពឹងតែ១បទ១ ដូចរំពឹងថា អរហំ១ ឬថា សម្មាសម្ពុទ្ធោ១ ។ល។ ពុទ្ធោ១ ឬថា ភគវា១ ដូច្នេះក៏បាន នឹករំពឹងយ៉ាងនេះក្នុង១បទ១ ទោះបាន១រយចប់ក្តី ១ ពាន់ចប់ក៏បាន តាមពេញចិត្តរបស់ខ្លួន, ត្រូវនឹករំពឹងដោយដឹងសេចក្តីផង ដូចមានបែបប្រែក្នុងត្រៃប្រណាមខាងដើមនោះស្រាប់ហើយ ។

ឯទីសេនាសនៈដែលឧបាសក ឧបាសិកា នឹងអង្គុយចំរើននោះគប្បីរកទីឱ្យស្ងាត់ ទាំងពេលសោត ក៏ត្រូវរកឱ្យស្ងាត់ចាកសូរស័ព្ទសំឡេងទាំងពួង កុំឱ្យលាន់ឮគឹកកង ដើម្បីនឹងធ្វើឱ្យអារម្មណ៍តាំងនៅនឹងល្អ ។

កាលបើ ឧបាសក ឧបាសិកា បានតាំងភាវនារំពឹងដល់ពុទ្ធគុណដូច្នេះហើយក៏នឹងអាចឱ្យកើតបានតែត្រឹមបីតិ ៥ យ៉ាង :

១. ខុទ្ទកា បីតិ សេចក្តីត្រេកអរព្រឺរោមព្រឺស្បែក,

២. ខណិកា បីតិ សេចក្តីត្រេកអរប្រាកដដូចជាផ្លេកបន្ទោរ,

៣. ឱក្កន្តិកា បីតិ សេចក្តីត្រេកអរមានអាការប្រាកដ ដូចជារលកទឹកបោកខ្ទប់មកត្រូវ,

៤. ឧព្វេង្គា បីតិ សេចក្តីត្រេកអរខ្លាំង អាចញ៉ាំងកាយឱ្យអណ្តែតឡើង,

៥. ផរណា បីតិ សេចក្តីត្រេកអរធ្វើ ឱ្យត្រជាក់ជ្រួតជ្រាបទូទៅក្នុងកាយ ។

បីតិទាំង ៥ យ៉ាងនេះ ត្រង់បីតិណាមួយ រមែងកើតឡើងដោយអំនាចភាវនារំពឹងដល់ពុទ្ធគុណដែលជាមូលកម្មដ្ឋាន ហើយនឹងបានផលានិសង្សអាចឱ្យសំរេចតែត្រឹមឧបចារជ្ឈានប៉ុណ្ណោះ មិនអាចនឹងឱ្យសំរេចដល់អប្បនាឈាន គឺបឋមជ្ឈាននោះបានឡើយ ព្រោះពុទ្ធគុណនេះជាគុណជ្រាលជ្រៅអនេកអនន្តពន់ពេកណាស់ អ្នកដែលអាចចំរើននោះមិនអាច និងពិចារណាឱ្យយល់សព្វគ្រប់ទៅបាន ។

**(ចប់ភាវេតព្វកិច្ចដោយសង្ខេបតែប៉ុណ្ណោះ)**

# អកុសលកម្មបថ

គន្លង ឬ ផ្លូវនៃអំពើជាអកុសល ហៅថាអកុសលកម្មបថ មាន ១០ យ៉ាងគឺ កាយកម្ម អំពើដែលសំរេចដោយកាយ មាន ៣ យ៉ាង, វចីកម្ម អំពើដែលសំរេចដោយវាចា មាន ៤ យ៉ាង, មនោកម្ម អំពើដែលសំរេច ដោយចិត្ត មាន ៣ យ៉ាង, រួមត្រូវជា ១០ យ៉ាង ។

## កាយកម្ម ៣ យ៉ាង

១-បាណាតិបាតា កិរិយាសម្លាប់សត្វដោយកាយរបស់ខ្លួន ឬ ប្រើឱ្យគេសម្លាប់ដោយវាចា ។

២-អទិន្នាទានំ កិរិយាលួចលាក់ឆក់ដណ្តើមទ្រព្យគេដោយកាយរបស់ខ្លួន ឬប្រើឱ្យគេលួចលាក់ឆក់ដណ្តើមដោយវាចា ។

៣-កាមេសុ មិច្ឆាចារោ កិរិយាប្រព្រឹត្តិខុសក្នុងកាមទាំងឡាយ គឺធ្វើនូវមេថុនសេវនៈនឹងស្ត្រីដែលមានគេហួងហែងរក្សា ។

## វចីកម្ម ៤ យ៉ាង

១-មុសាវាទា កិរិយាពោលនូវពាក្យកុហក ។

២-បិសុណាវាចា កិរិយាពោលនូវពាក្យញុះញង់បំបែកបំបាក់អ្នកដទៃ ។

៣-ផរុសវាចា កិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោក ជេរប្រទេចអ្នកដទៃជាដើម ។

៤-សម្ផប្បលាបោ កិរិយាពោលនូវពាក្យរោយរាយឥតប្រយោជន៍ ។

## មនោកម្ម ៣ យ៉ាង

១-អភិជ្ឈា ចិត្តសំលឹងរំពៃចំពោះទ្រព្យសម្បត្តិអ្នកដទៃ ដោយគិតបម្រុងនឹងឱ្យបានមកជាទ្រព្យរបស់ខ្លួន ។

២-ព្យាបាទោ ចិត្តចងគំនុំគុំគួនគិតប៉ងនឹងឱ្យអ្នកដទៃដល់នូវសេចក្ដីវិនាស ។

៣-មិច្ឆាទិដ្ឋិ គំនិតយល់ខុសហើយប្រកាន់ឡើងថាជាត្រូវ ។

## អង្គនៃអកុសលកម្មបទ

អង្គនៃ បាណាតិបាត ,អទិន្នាទាន, កាមេសុមិច្ឆាចារ និងមុសាវាទ មុសាវាទ ដូចបានពោលមកក្នុងនិច្ចសីលខាងដើមរួចហើយ ។

## បិសុណាវាចា មានអង្គ ៤

១-ភិន្និតព្វោ បរោ អ្នកដទៃដែលមានរូប គឺខ្លួនគប្បីញុះញង់បំបែក ។

២-ភេទនបុរេក្ខារតា គិតនឹងញុះញង់បំបែកអ្នកដទៃ ។

៣-តជ្ជោ វាយាមោ ព្យាយាមនឹងញុះញង់បំបែកអ្នកដទៃនោះ ។

៤-តស្ស តទត្ថវិជាននំ ញ៉ាំងអ្នកនោះឱ្យដឹងច្បាស់នូវដំណើរដែលខ្លួនញុះញង់បំបែកនោះ ។

## ផរុសវាចា មានអង្គ ៣

១-អក្កោសិតព្វោ បរោ អ្នកដទៃដែលមានរូប គឺខ្លួនគប្បីជេរប្រទេច ។

២-កុប្បិតចិត្តំ ចិត្តខឹងរន្ធត់ ។

៣-អក្កោសនា បានជេរប្រទេចគេ ។

## សម្ផប្បលាបៈ មាន អង្គ ២

១-ភារតយុទ្ធសិតាហរណាទិនិរត្ថកថា ពាក្យឥតប្រយោជន៍មានរឿងចម្បាំងនៃមហាភាគរៈ និង រឿងរាពណ៍លួចនាំនាងសិតាយកទៅជាដើម ។

២-តថារូបីកថាកថនំ   បានពោលនូវពាក្យឥតប្រយោជន៍ មានសភាពដូច្នោះ ។

## អភិជ្ឈា មាន អង្គ ២

១-បរភណ្ឌំ   ទ្រព្យជារបស់អ្នកដទៃ ។

២-អត្តនោ  បរិណាមនំ   គិតចង់បង្អោនទ្រព្យរបស់អ្នកដទៃនោះឱ្យបានមកជាទ្រព្យរបស់ខ្លួនដោយកលឧបាយផ្សេងៗ ។

## ព្យាបាទ មាន អង្គ ២

១-បរិសត្តោ   អ្នកដទៃក្រៅពីខ្លួន ។

២-តស្ស  តំ  តំ  វិនាសចិន្តា   គិតគុំគួនប្រុងនឹងឱ្យអ្នកនោះដល់នូវសេចក្តីវិនាសដោយហេតុនោះ ៗ ។

## មិច្ឆាទិដ្ឋិ មាន អង្គ ២

១-វត្ថុនោ ច  គហិតាការវិបរិតតា     ចិត្តប្រែប្រួលដោយអាការខុសអំពីព្រះរតនត្រ័យជាដើម ។

២-យថា ច នំ  គណ្ហាតិ  តថាភាវេន តស្សូបបដ្ឋានំ គំនិតដែលយល់ខុសនោះ  ឃើញខុសយ៉ាងណា ក៏ប្រកាន់សេចក្តីខុសនោះថាជាត្រូវវិញ ។

អកុសលកម្មបទទាំង ១០ ប្រការ   ដូចបានពោលមកហើយនេះ ទោះត្រង់បទណាក្តី   បើលុះតែព្រមដោយអង្គនោះៗ  ទើបត្រូវទោសដល់អ្នកដែលប្រព្រឹត្តខុស,  អ្នកនោះនឹងបាននូវសេចក្តីទុក្ខ សេចក្តីវិនាសក្នុងលោកនេះ  និង បរលោកនាយ, បើទុកជាមិនទាន់ឱ្យផលឃើញច្បាស់ក្នុងលោកនេះ   លុះដល់ទៅក្នុងបរលោកនាយ  ក៏គង់នឹងឱ្យផលដល់អ្នកនោះពុំខានឡើយ,  បើមិនទាន់ព្រមដោយអង្គនោះៗ  គឺថាបើនៅខ្វះអង្គណាមួយនោះ  ក៏មិនទាន់បានឈ្មោះថា  មានទោសក្នុងអកុសលកម្មបទដល់អ្នកដែលប្រព្រឹត្តនោះឡើយ ។

**អកុសលកម្មបថ ១០ ប្រការ ព្រមទាំងអង្គ**

**ចប់ដោយសង្ខេបតែប៉ុណ្ណេះ**

# កុសលកម្មបថ

គន្លងឬផ្លូវនៃអំពើជាកុសល ហៅថា កុសលកម្មបថ មាន ១០ យ៉ាងគឺ កាយកម្ម អំពើដែលសម្រេចដោយកាយ មាន ៣ យ៉ាង, វចីកម្ម អំពើដែលសម្រេចដោយវាចាមាន ៤ យ៉ាង , មនោកម្ម អំពើដែលសម្រេចដោយចិត្ត មាន ៣ យ៉ាង, រួមត្រូវជា ១០ យ៉ាង ។

## កាយកម្មមាន ៣ យ៉ាង

១-បាណាតិបាតា វេរមណី ចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លងគឺសម្លាប់សត្វ ។

២-អទិន្នាទានា វេរមណី ចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឱ្យដោយកាយ ឬ ដោយវាចា ។

៣-កាមេសុ មិច្ឆាចារា វេរមណី ចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តិខុសក្នុងកាមទាំងឡាយ ។

## វចីកម្មមាន ៤ យ៉ាង

១-មុសាវាទា វេរមណី ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

២-បិសុណាយ វាចាយ វេរមណី ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យញុះញង់បំបែកបំបាក់អ្នកដទៃ ។

៣-ផរុសាយ វាចាយ វេរមណី ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យអាក្រក់មានពាក្យទ្រគោះបោះបោក ជេរប្រទេចអ្នកដទៃជាដើម ។

៤-សម្ផប្បលាបា វេរមណី ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យរោយរាយឥតប្រយោជន៍ ។

## មនោកម្មមាន ៣ យ៉ាង

១-អនភិជ្ឈា មិនមានចិត្តគិតសម្លឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបម្រុងនឹងឱ្យបានមកជាទ្រព្យរបស់ខ្លួនឡើយ ។

២-អព្យាបាទោ មិនមានចិត្តចងគំនុំគុំគួនគិតប៉ងនឹងឱ្យអ្នកដទៃដល់នូវសេចក្តីវិនាសឡើយ ។

៣-សម្មាទិដ្ឋិ គំនិតយល់ឃើញត្រូវពិត ដោយប្រកាន់ឡើងថាត្រូវមែន ។

អ្នកឯណាបានប្រព្រឹត្តត្រូវតាមកុសលកម្មបទទាំង ១០ ប្រការដូចបានពោលមកហើយនេះ, អ្នកនោះនឹងបានសេចក្តីសុខ សេចក្តីចំរើនក្នុងលោកទាំងពីរ គឺក្នុងលោកនេះ និង ក្នុងបរលោកជាប្រាកដ ។

**កុសលកម្មបថ ១០ ប្រការ**

**ចប់ដោយសង្ខេបតែប៉ុណ្ណេះ**

## ធម្មទេសនាយាចនគាថា

*ពាក្យសូមអារាធនាលោកអ្នកសម្ដែងធម៌*

ព្រហ្មា ច លោកាធិបតី សហម្បតី
កតញ្ជលី អន្ធិវរំ អាយាចថ ។
សន្តីធ សត្តាប្បរជក្ខជាតិកា
ទេសេតុ ធម្មំ អនុកម្បិមំ បជំ ។
សទ្ធម្មភេរី វិនយញ្ច កាយំ
សុត្តញ្ច ពន្ធំ អភិធម្មចម្មំ ។
អាកោដយន្តោ ចតុសច្ចទណ្ឌំ
បញ្ចោធ នេយ្យេ បរិសាយ មជ្ឈេ ។

ឯវំ សហម្បតី ព្រហ្មា ភគវន្តំ អាយាចថ តុណ្ហីភាវេន តំ ពុទ្ធោ ការុញ្ញេនាធិវាសយ តម្ហា វុដ្ឋាយ បាទេន មិគទាយំ តតោ គតោ បញ្ចវគ្គិយានំ នេយ្យេ អមំ បាយេសិ ធម្មតោ តតោ បភូតិ សម្ពុទ្ធោ អន្វនា ធម្មទេសនំ មាយវស្សានិ ទេសេសិ សត្តានំ អត្ថសិទ្ធកំ ។ តេន សាធុ អយ្យោ ភន្តេ ទេសេតុ ធម្មទេសនំ សព្វាយិធ បរិសាយ អនុកម្បម្បិ កាតវេ ។

គ្រានោះសហម្បតី- ព្រហ្មជាឥស្សូលោកា
ចូលគល់ព្រះសាស្ដា លើកហត្ថាសិរោរាប ។
ហើយពោលពាក្យទូលថា សូមករុណាស្ដេចទ្រង់ជ្រាប
ដ្បិតសត្វអន់ទន់ទាប ទុព្វលភាពបាបក្រៃក្រាស់ ។
ទន្ទឹងព្រះធម៌ថ្លៃ ជានិស្ស័យបច្ច័យច្បាស់
ឥឡូវទ្រង់បានត្រាស់ ត្រេកអរណាស់ពុំកន្តើយ ។
សត្វខ្លះក្រាស់ដោយកាម មិនយល់តាមត្រៃលក្ខណ៍ឡើយ
ឥឡូវយល់ខ្លះហើយ ដោយអំណាចព្រះមានបុណ្យ ។
បើបានស្ដាប់ទេសនា បញ្ញាក្លាខ្លាំងលើសមុន
សូមព្រះដ៏មានបុណ្យ ទ្រង់និមន្តត្រាស់ទេសនា ។
ប្រោសសត្វបំបាត់សោក ទាំងរាគរោគរូបតណ្ហា
ងងឹតប្រែជ្រះថ្លា កើតបញ្ញាភិយ្យោយល់ ។
ត្រៃលោកគោកត្រៃលក្ខណ៍ សង្សារចក្រវិលមិនដល់

អរិជ្ជាកប្បសគល់ ជាបច្ច័យនៃសង្ខារ ។
នាំសត្វឱ្យសោកសៅ លិចលង់នៅក្នុងសង្សារ
បញ្ចមារមោហន្ធការ រឹតរុំហ៊ុមជុំជាប់នៅ ។
ហេតុនេះសូមព្រះអង្គ ប្រោសស្រោចស្រង់ដាក់សំពៅ
ចម្លងសត្វឆ្ពោះទៅ ដាក់ត្រើយត្រាណនិព្វាននាយ ។
ដូចកល់ប្រទីបធំ សាយត្រសុំភ្លឺព្រោងព្រាយ
បំភ្លឺសត្វទាំងឡាយ ឱ្យសប្បាយក្សាន្តភិរម្យ ។
ព្រះសទ្ធម្មជាស្គរជ័យ ព្រះវិន័យជារាងធំ
ព្រះសូត្រជាខ្សែរុំ ព្រះអភិធម្មជាស្បែកដាស ។
អរិយសច្ចជាអន្លូង សម្រាប់ទូងឱ្យឮច្បាស់
សត្វលោកងោកងុយណាស់ ឮស្គរដាសក្រោកឡើងបាន ។
បរិស័ទ ៤ ជំពូក ដូចផ្កាឈូកក្នុងជលដ្ឋាន
ខ្លះដុះចាំសូរ្យឆាន រះនឹងរីកដោយរស្មី ។
ព្រះធម៌ជាសូរ្យសែង រះឡើងចែងចាំងរស្មី
បំភ្លឺលោកទាំង បី ឱ្យយល់ផ្លូវឋានសុខា ។
សហម្បតីព្រហ្ម ឱនបង្គំអារាធនា
សម្ដេចព្រះភគវា ដោយគាថាយ៉ាងនេះឯង ។

ព្រះពុទ្ធទ្រង់អនុកូល ព្រមទទួលនឹងសម្ដែង
ដោយតុណ្ហីភាពថ្លែង តាមភារៈគុណករុណា ។
ទើបក្រោកចាកទីនោះ ភក្ត្រាឆ្ពោះព្រៃមិគទា
យាងចេញចរលីលា ពីទីនោះដោយព្រះបាទ ។
ញ៉ាំងសត្វចូលពុទ្ធចក្រ មានបញ្ចវគ្គិយ៍ជាអាទិ៍
ឱ្យផឹកអម្រឹតជាតិ រសនិព្វានតាមធម្មតា ។
ចាប់ដើមពីនោះឯង ទ្រង់សម្ដែងធម៌ទេសនា
ធ្វើពុទ្ធក្រឹត្យា អស់វស្សាសែសិបប្រាំ ។
ពុំថយពុំបន្ធូរ ប្រយោជន៍យូរអង្វែងឆ្នាំ
សម្រេចបុញ្ញកម្ម ដល់សព្វសត្វទាំងភពត្រ័យ ។
ហេតុនោះឥឡូវនេះ យើងខ្ញុំនេះសាទរក្រៃ
បពិត្រព្រះគុណថ្លៃ សូមនិមន្តប្រោសទេសនា ។
អនុគ្រោះពួកបរិស័ទ ដែលជាប់ខាត់ដោយមោហា
ឱ្យកើតមានបញ្ញា ប្រាកដនាទីនេះឯងហោង ។

## ពាក្យពោលសរសើរលោកអ្នកសម្តែងធម៌

បពិត្រព្រះគុណចេះឆ្លាតឆ្លៀស ធម៌ណាចង្អៀតចេះកែខៃ
វែកញែកឱ្យច្បាស់អស់សង្ស័យ បញ្ញាទន់ខ្ចីគង់ស្ដាប់បាន ។
ពិរោះសាច់ធម៌ដ៏ប្លែកៗ ពិរោះពន់ពេកគ្រប់សន្ដាន
ទោះបីអ្នកល្ងង់គង់ភ្ញាក់ប្រាណ ដោយបានរសធម៌ផ្អែមប្រៀបគ្មាន ។
កាលណោះសម្ដេចព្រះភគវា ទេសនាធម្មាប្រោសប្រទាន
ព្រះធម៌នាំសត្វទៅនិព្វាន រាប់ម៉ឺនសែនលានស្ទើរគ្មានសល់ ។
កាលណោះសម័យព្រះភគវា ទេសនាធម្មាប្រទានផ្ទាល់
ព្រះអង្គប្រោសសត្វសព្វសកល លុះបានមគ្គផលច្រើនណាស់ណា ។
ផុតពីសម្ដេចព្រះភគវន្ត កន្លងរាប់ពាន់ឆ្នាំហើយណា
នៅតែសាវកព្រះភគវា ទេសនាធម្មាពិរោះក្រៃ ។
មិនគឺសាវ័កអង្គឯណា គឺព្រះករុណាទេសថ្មីៗ
បញ្ចប់ឯវិ សង្ខេបខ្លី ខ្ញុំកូណាតាយាយស្ដាយណាស់ណា ។
មិនទាន់អស់ចិត្តនឹងរសធម៌ នឹងឃាត់អង្វរមិនហានថា
ឃើញនឿយព្រះកាយព្រះករុណ សូមសាធុការចប់សេចក្ដី ។
ហត្ថាខ្ញុំទាំងគូផ្គងប្រណោម លើកឡើងបង្គំគុណកែវបី
ព្រះពុទ្ធព្រះធម៌ព្រះសង្ឃថ្លៃ សូមបានសេរីដូចប្រាថ្នា ។



ខ្ញុំសូមខមាទោសទាំងឡាយ ក្រែងឆ្គងដោយកាយ ឬ វាចា
នៅមានគ្រោតគ្រាតក្នុងធម៌ណា ដូចមានគាថាសូត្រក្រោយហោង ។

## ពុទ្ធជយមង្គលគាថា

១-ពាហុំ សហស្សមភិនិម្មិតសាវុធន្តំ
គ្រីមេខលំ ឧទិតឃោរសសេនមារំ
ទានាទិធម្មវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទលោកាចារ្យ ផ្ចាញ់ក្រុងមារចិត្តមោហន្ធ
និម្មិតដៃមួយពាន់ កាន់សាស្ត្រាវុធនានា ។
ជិះគ្រីមេខលជាតិ កោញ្ចនាទខ្ទរពសុធា
ព្រមដោយមារសេនា ពន្លឺកលន់កងសព្ទ័ស៊ាន ។
ដោយធម្មពិធី ទានបារមីជាប្រធាន
ក្រុងមារចាញ់ទ្រង់ញាណ ប្រណមកាយថ្វាយវន្ទា ។
វិជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា ព្រះឈ្នះមារគ្រានោះហោង ។

២-មារាតិរេកមភិយុជ្ឈិត   សព្វរត្តឹ
ឃោរម្បនាឡវកមក្ខមថទ្ធយក្ខំ
ខន្តី   សុទន្តវិធិនា  ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទពិននាយក   ផ្ចាញ់អាឡវកយក្សឃោរឃៅ
រឹងរូសមិនតាំងនៅ   ក្នុងខន្តីគុណសត្យា ។
រហូតអស់រាត្រី   ព្រះជិនស្រីទ្រង់យុទ្ធនា
ក្រៃលែងក្រុងមារា   ក្នុងបឋមសម្ពោធិ ។
ដោយព្រះពិធីញាណ   ទ្រង់ទូន្មានដោយខន្តី
ញ៉ាំងចិត្តអសុរី   ឱ្យបង់ព្យសន៍ចុះវន្ទា ។
រឺជយមង្គល   ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា   ព្រះឈ្នះអាឡវកយក្សហោង ។

៣-នាឡាគីរី  គជវរំ   អតិមត្តភូតំ
ទាវគ្គិចក្កមសនីវ   សុទារុណន្តំ
មេត្តម្ពុសេកវិធិនា  ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទពិនជិនស្រី   ផ្ចាញ់ដំរីឈ្មោះនាឡា
គីរីវរគជា   ដ៏ហានក្លាចុះព្រេងព្រេច ។
សាហាវឆេវឆេះក្រៃ   ដូចភ្លើងឆេះព្រៃកំទេច
មុតដូចចក្រក្រុតពេជ្រ   ខ្លាំងដូចកាំអសនី ។
ដោយព្រះពិធីស្រប់   ស្រោចទឹកអប់គឺបារមី
មេត្តាព្រះជិនស្រី   ញ៉ាំងដំរីឱ្យជ្រះថ្លា ។
រឺជយមង្គល   ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា   ព្រះឈ្នះនាឡាគីរី ។

៤-ឧក្ខិត្តខគ្គមតិហត្ថសុទារុណន្តំ
ធាវន្តិយោជនបថង្គុលិមាលវន្តំ
ឥទ្ធី ភិសង្ខតមនោ ជិតវា មុនិន្ទោ
តន្តេ ជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទពិនលោកត្រៃ   មានព្រះទ័យធ្វើបាដិហារ្យ
ផ្ចាញ់ចោរអង្គុលិមាល៍   មានកម្រងគឺម្រាមដៃ ។
នៃមនុស្សដែលគាត់កាត់   មកដោតចាក់ជាមាល័យ
អង់អាចកំណាចក្រៃ   ដ៏មានដៃស្ទាត់ប្រហារ ។
កាន់ដាវងាត្រវី   ដេញព្រះមុនីសាស្តាចារ្យ

ចម្ងាយផ្លូវកន្តារ    កណ្តាលព្រៃបីយោជនា ។
វិជយមង្គល    ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា    ព្រះឈ្នះអង្គុលីមាល៍ ។

៥-កត្វាន កដ្ឋមុទរំ    ឥវ គព្ភិនីយា
ចិញ្ចាយ ទុដ្ឋវចនំ    ជនកាយមជ្ឈេ
សន្តេន សោមវិធិនា    ជិតវា មុនិន្ទោ
តន្តេជសា ភវតុ    តេ ជយមង្គលានិ ។

ព្រះមុនិន្ទមានព្រះភាគ    ផ្ចាញ់ទ្រូស្តពាក្យនាងចិញ្ចា
អំពើធ្វើដូចជា    ស្ត្រីមានគភ៌ចាស់ចើសពោះ ។
យកឈើធ្វើជាកូន    ព័ន្ធពោះខ្លួនពោលទ្រគោះ
ព្រះពុទ្ធឈ្នះកាលនោះ    ដោយសមាចារពិធី ។
រម្ងាប់ពាក្យចណ្ឌាល    នាកណ្តាលជនប្រុសស្រី
ចិញ្ចាចាញ់បារមី    គឺសច្ចំពាក្យសត្យា ។
វិជយមង្គល    ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា    ព្រះសាស្តាឈ្នះចិញ្ចា ។

៦-សច្ចំ វិហាយ    មតិសច្ចកវាទកេតុំ
វាទាភិរោបិតមនំ    អតិអន្ធភូតំ
បញ្ញាបទីបជលិតោ    ជិតវា មុនិន្ទោ
តន្តេជសា ភវតុ    តេជ យមង្គលានិ ។

ព្រះមុនិន្ទពិនអ្នកប្រាជ្ញ    រុងរឿងស្វាចដោយបញ្ញា
ផ្ចាញ់សច្ចកៈជា    និគ្រន្ថក្រៅពុទ្ធវិន័យ ។
អធ្យាល័យលះបង់    ពាក្យសត្យត្រង់តាមគាប់ចៃ
សរសើរខ្លួនឯងក្រៃ    លើកកំពស់ដូចដងទង់ ។
បង្កើតមួរងងឹត    ដោយពោលឥតពាក្យទៀងត្រង់
ព្រះទ្រង់កំចាត់បង់    ដោយប្រទីបគឺបញ្ញា ។
វិជយមង្គល    ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា    ឈ្នះសច្ចកៈនិគ្រន្ថ ។

៧-នន្ទោបនន្ទភុជគំ    វិពុធំ មហិទ្ធឹ
បុត្តេនថេរភុជគេន    ទមាបយន្តោ
ឥទ្ធូបទេសវិធិនា    ជិតវា មុនិន្ទោ
ភន្តេជសា ភវតុ    តេ ជយមង្គលានិ ។

ព្រះមុនិន្ទពិនទ្រង់ញាណ ញុំាងមោគ្គល្លានមានអំណាច
ឱ្យប្លែងជានាគរាជ ទៅទូន្មានព្យុះភុជង្គ ។
ឈ្មោះនន្ទោបនន្ទ ចិត្តមោហន្ធរឿងឫទ្ធិរុង្គ
ទិដ្ឋិកាចទ្រនង់ ទ្រង់ផ្ចាញ់ដោយពិធីឈាន ។
គឺឱ្យឧបទេស ឫទ្ធិវិសេសដល់មោគ្គល្លាន
ឫទ្ធិនាគអន្តរធាន ឱនចុះចាញ់ព្រះចេស្តា ។
វិជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា ព្រះភគវាឈ្នះនាគហោង ។

៨- ទុគ្គាហទិដ្ឋិភុជគេន សុទដ្ឋហត្ថំ
ព្រហ្មំ វិសុទ្ធិ ជុតិមិទ្ធិពកាភិធានំ
ញាណាគទេន វិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ ។

ព្រះមុនិន្ទពិនគោតម ផ្ចាញ់មហាព្រហ្មឈ្មោះពកា
សំគាល់ថា អាត្មា រុងរឿងដោយគុណបរិសុទ្ធ ។
ដៃកាន់អសិរពិស គឺចិត្តទ្រឹស្តដ៏មុះមុត
កាន់ខុសផ្លូវសម្ពុទ្ធ មិនលើកលាកលះបង់ប្រាណ ។
ទ្រង់ឈ្នះដោយពិធី ឱសថវិសេសសម្រាន្ត
ផ្សំត្រូវគាប់សន្តាន គឺព្រះញាណប្រោសទេសនា ។
វិជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា ឈ្នះព្រហ្មាឥតមានហ្មង ។

៩- ឯតាបិ ពុទ្ធជយមង្គល អដ្ឋគាថា
យោ វាចនោ ទិនទិនេ សរតេ មតន្ទី
ហិត្វានេវិវិធានិ ចុបទ្ទវានី មោក្ខំ
សុខំ អធិកនេយ្យ នរោ សបញ្ញោ ។

យោ នរោ ជនឯណា កបបញ្ញាប្រាសក្តីខ្ជិល
ឧស្សាហ៍សាងទានសីល សូត្ររំលឹកព្រះធម៌ថ្លៃ ។
គាថាប្រាំបីបទ នេះកំណត់ឈ្មោះពុទ្ធជ័យ
ខំសូត្រសព្វៗថ្ងៃ កើតមង្គលជានិរន្តរ៍ ។
សោ នរោ វិជននោះ បានរំដោះរោគអាសន្ន
ឧបទ្រពអនេកលន់ មានប្រការផ្សេងៗផង ។
នឹងដល់ធម៌ក្សេមក្សាន្ត គឺនិព្វានសុខកន្លង
លែងទុក្ខទាំងបួនកង ដោយពុទ្ធជ័យមង្គលនេះ ។

# បរាភវសូត្របទ បថ្យាវត

( ទេវតាទូលសួរព្រះសាស្តាថា )

បរាភវន្តំ បុរិសំ មយំ បុច្ឆាម គោតមំ
ភវន្តំ បុដ្ឋុមាគម្ម កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយមកសូមទូលសួរ នូវហេតុដែលគួរចំរើនវិនាស
ប្រុសស្រីក្នុងលោកសន្និវាស ដែលនឹងវិនាសសាបសូន្យចាកគុណ ។
ឆ្លោះព្រះគោតមព្រះអង្គមានបុណ្យ មេត្តានិមន្តសំដែងឱ្យទាន
ធម្មជាតិដូចម្តេចដែលជាប្រធាន នាំឱ្យសត្វមានសេចក្តីវិនាស ។

សុវិជានោ ភវំ ហោតិ សុវិជានោ បរាភវោ
ធម្មកាមោ ភវំ ហោតិ ធម្មទេស្សី បរាភវោ

អ្នកដែលចំរើនតថាគតស្គាល់ងាយ អ្នកដែលអន្តរាយតថាគតស្គាល់ពិត
អ្នកប្រាថ្នាធម៌ល្អិតល្អក្នុងចិត្ត ហើយខំប្រព្រឹត្តនឹងបានចំរើន
អ្នកដែលទ្រុស្តធម៌ស្អប់ធម៌ឥតកើន ឥតកើតចំរើនវិនាសទៅមុខ ។

ឥតិហេតំ វិជានាម បឋមោ សោ បរាភវោ
ទុតិយំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះទី ១ ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែងឱ្យទាន
វិនាសទី ២ អ្វីជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។

អសន្តស្ស បិយា ហោតិ សន្តេន កុរុតេ បិយំ
អសតំ ធម្មំ រោចេតិ តំ បរាភវតោ មុខំ ។

អ្នកដែលស្រឡាញ់ពេញចិត្តស្នេហា តែនឹងមនុស្សណាអសប្បុរស
តែងមិនស្រឡាញ់ពេញចិត្តទាំងអស់ នឹងអ្នកសប្បុរសមកធ្វើជាមិត្រ ។
សេចក្តីស្រឡាញ់ពេញចិត្តជំនិត ហើយទៅគប់មិត្តអសប្បុរស
គាប់ចិត្តក្នុងធម៌ឬមួយរបស់ ហេតុនោះទាំងអស់នាំឱ្យវិនាស ។

ឥតិហេតំ វិជានាម ទុតិយោ សោ បរាភវោ
តតិយំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះទី ២ ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែងឱ្យទាន
វិនាសទី ៣ អ្វីជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។

និទ្ទាសីលី សភាសីលី អនុដ្ឋាតា ច យោ នរោ
អលសោ កោធបញ្ញាណោ តំ បរាភវតោ មុខំ ។

អ្នកដេកច្រើនមួយ និយាយច្រើនមួយ    នឹងអ្នកឥតព្រួយឥតគិតប្រឹងប្រែង
អ្នកខ្ជិលច្រអូសមិនមានខ្នះខ្នែង    ខឹងច្រើនសំដែងឱ្យគេឃើញបាន ។
ហេតុធមិទាំងនោះមិនជាកល្យាណ    នាំឱ្យខកខានខាតខូចប្រយោជន៍
មានជាប្រធានតិចច្រើនដោយហោច    នាំបង់ប្រយោជន៍ហើយឱ្យវិនាស ។

ឥតិហេតំ វិជានាម    តតិយោ សោ បរាភវោ
ចតុន្ថំ ភគវា ព្រូហិ    កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង    វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ    វិនាសនោះឈ្មោះទី ៣ ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត    សូមទ្រង់និមន្តសំដែងឱ្យទាន
វិនាសទី ៤ អ្វីជាប្រធាន    នាំសត្វឱ្យមានសេចក្តីវិនាស ។

យោ មាតរំ វា បិតរំ វា    ជិណ្ណកំ គតយោព្វនំ
បហុសន្តោន ន ភរតិ    តំ បរាភវតោ មុខំ ។

នរជនណាមានទ្រព្យធនធាន    ហើយខ្លួនមិនបានចិញ្ចឹមរក្សា
មាតាបិតាដែលចាស់ជរា    ហេតុនោះទៅជានាំឱ្យវិនាស ។

ឥតិហេតំ វិជានាម    ចតុត្ថោ សោ បរាភវោ
បញ្ចមំ ភគវា ព្រូហិ    កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង    វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ    វិនាសនោះឈ្មោះទី ៤ ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត    សូមទ្រង់និមន្តសំដែងឱ្យទាន
វិនាសទី ៥ អ្វីជាប្រធាន    នាំសត្វឱ្យមានសេចក្តីវិនាស ។

យោ សមណំ ព្រាហ្មណំ    វា អញ្ញំ វាបិ វនិព្វកំ
មុសាវាទេន វញ្ចេតិ    តំ បរាភវតោ មុខំ ។

ជនបញ្ឆោតព្រាហ្មណ៍ឬពួកសមណៈ    ពួកស្មូមឬអ្នកដទៃ ៗ
ដោយមុសាវាទឃ្លាតពាក្យប្រពៃ    នោះប្រធាននៃក្តីវិនាស ។

ឥតិហេតំ វិជានាម    បញ្ចមោ សោ បរាភវោ
ឆដ្ឋមំ ភគវា ព្រូហិ    កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង    វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ    វិនាសនោះឈ្មោះទី ៥ ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត    សូមទ្រង់និមន្តសំដែងឱ្យទាន
វិនាសទី ៦ អ្វីជាប្រធាន    នាំសត្វឱ្យមានសេចក្តីវិនាស ។

បហុតវិត្តោ បុរិសោ    សហិរញ្ញោ សភោជនោ
ឯកោ ភុញ្ជតិ សាទូនិ    តំ បរាភវតោ មុខំ ។

បុរសអ្នកមានទ្រព្យធនធានច្រើន មាសប្រាក់ចំរើននឹងគ្រឿងអាហារ

លបលាក់របស់ដែលឆ្ងាញ់ពិសា ស៊ីម្នាក់ឯងជាប្រធានវិនាស ។

ឥតិហេតំ វិជានាម ឆដ្ឋមោ សោ បរាភវោ

សត្តមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនេះឯងព្រោះហេតុដូច្នោះ

ក្តីវិនាសនេះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះទី ៦ ទាន់ហន់ ។

បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែងឱ្យទាន

វិនាសទី ៧ អ្វីជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។

ជាតិត្ថទ្ធោ ធនត្ថទ្ធោ គោត្តត្ថទ្ធោ ច យោ នរោ

សញ្ញាតឹ អតិមញ្ញេតិ តំ បរាភវតោ មុខំ ។

អ្នកដែលប្រកាន់ជាតិទ្រព្យត្រកូល ហើយមិនប្រមូលសាច់ញាតិសន្តាន

មើលងាយញាតិខ្លួនដោយអាងខ្លួនមាន នោះជាប្រធានសេចក្តីវិនាស ។

ឥតិហេតំ វិជានាម សត្តមោ សោ បរាភវោ

អដ្ឋមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនេះឯងព្រោះហេតុដូច្នោះ

ក្តីវិនាសនេះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះទី ៧ ទាន់ហន់ ។

បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែងឱ្យទាន

វិនាសទី ៨ អ្វីជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។

ឥត្ថីធុត្តោ សុរាធុត្តោ អក្ខធុត្តោ ច យោ នរោ

លទ្ធំ លទ្ធំ វិនាសេតិ តំ បរាភវតោ មុខំ ។

ជនអ្នកប្រព្រឹត្តល្បែង ៣ ប្រការ ល្បែងស្រីល្បែងស្រាល្បែងភ្នាល់ទាំងឡាយ

ធ្វើទ្រព្យខ្លួនមានឱ្យអន្តរាយ ការល្បែងទាំងឡាយនោះនាំវិនាស ។

ឥតិហេតំ វិជានាម អដ្ឋមោ សោ បរាភវោ

នវមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនេះឯងព្រោះហេតុដូច្នោះ

ក្តីវិនាសនេះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះទី ៨ ទាន់ហន់ ។

បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែងឱ្យទាន

វិនាសទី ៩ អ្វីជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។

សេហិ ទារេហិ អសន្តុដ្ឋោ វេសិយាសុ បទុស្សតិ

ទុស្សតិ បរទារេសុ តំ បរាភវតោ មុខំ ។

ប្រុសមិនត្រេកអរនឹងប្រពន្ធខ្លួន ហើយទៅជាប់ជួននឹងស្រីពេស្យា

ទ្រុស្តនឹងប្រពន្ធកូនជននានា ហេតុនោះទៅជានាំឱ្យវិនាស ។

ឥតិហេតំ វិជានាម នវមោ សោ បរាភវោ

ទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះទី ៩ ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែងឱ្យទាន
វិនាសទី ១០ អ្វីជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។

អតីត យោព្វនោ បោសោ អានេតិ តិម្ពរុត្ថនី
តស្សា ឥស្សា ន សុបតិ តំ បរាភវតោ មុខំ ។

បុរសមានវ័យដែលចាស់ហួសពេក ហើយមានតម្រេកដោយក្តីតណ្ហា
នាំយកស្រីក្មេងមកធ្វើភរិយា ហេតុនោះទៅជានាំឱ្យវិនាស ។

ឥតិហេតំ វិជានាម ទសមោ សោ បរាភវោ
ឯកាទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនេះឯងព្រោះហេតុដូច្នេះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះទី ១០ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែងឱ្យទាន
វិនាសទី ១១ អ្វីជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។

ឥត្ថី សោណ្ឌី វិកិរណី បុរិសំ វាបិ តាទិសំ
ឥស្សរិយស្មឹ ឋបេតិ តំ បរាភវតោ មុខំ ។

បុរសតាំងស្រីអ្នកលេងខ្ជះខ្ជាយ ឬស្រីទាំងឡាយតាំងបុរសនោះ
ដែលជាអ្នកលេងខ្ជះខ្ជាយដូច្នោះ អំពើទាំងនោះនាំឱ្យវិនាស ។

ឥតិហេតំ វិជានាម ឯកាទសមោ សោ បរាភវោ
ទ្វាទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនេះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះទី ១១ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសំដែងឱ្យទាន
វិនាសទី ១២ អ្វីជាប្រធាន នាំសត្វឱ្យមានសេចក្តីវិនាស ។

អប្បភោគោ មហាតណ្ហោ ខត្តិយេ ជាយតេ កុលេ
សោ ច រជ្ជំ បត្ថយតិ តំ បរាភវតោ មុខំ ។

ជនណាកើតក្នុងត្រកូលជាក្សត្រ អ្នកខ្សត់សម្បត្តិហើយប្រាថ្នាធំ
ចង់បានជាស្តេចសោយរាជ្យស្តុកស្តម្ភ ហេតុនោះនឹងនាំឱ្យដល់វិនាស ។

ឯតេ បរាភវេ លោកេ បណ្ឌិតោ សមវេក្ខិយ
អរិយោទស្សនសម្បន្នោ ស លោកំ ភជតេ សិវំ

ជនជាបណ្ឌិតគំនិតប្រសើរ បានឃើញដំណើរនៃហេតុវិនាស
ដល់សត្វក្នុងលោកសន្និវាស គេចពីវិនាសគប់រកចំរើន ។

# មង្គលសូត្រ

ឯវម្មេ សុតំ ( សូត្រនេះឈ្មោះមង្គលសូត្រ ) គឺខ្ញុំ (ឈ្មោះអានន្ទ) បានស្តាប់ហើយយ៉ាងនេះថា :

ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ សម័យមួយព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។

អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។

លំដាប់នោះឯង ទេវតា១អង្គ កាលដែលវេលារាត្រីបឋមយាមកន្លងទៅហើយមានរស្មីដ៏ល្អមញ្ញាំងវត្តជេតពនជុំវិញទាំងអស់ អោយភ្លឺស្វាងហើយព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងទីណាក៏ចូលទៅក្នុងទីនោះលុះចូលទៅដល់ហើយ ទើបថ្វាយបង្គំចំពោះព្រះដ៏មានព្រះភាគ ហើយឈរនៅក្នុង ទីដ៏សមគួរ ។

ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ គាថាយ អជ្ឈភាសិ កាលទេវតានោះឈរនៅក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះដ៏មានព្រះភាគ ដោយពាក្យជាគាថា ( យ៉ាងនេះ ) ថា:

ពហូ ទេវា មនុស្សា ច មង្គលានិ អចិន្តយុំ
អាកង្ខមានា សោត្ថានំ ព្រូហិ មង្គលមុត្តមំ ។

ទេវតា និង មនុស្សទាំងឡាយជាច្រើន ប្រាថ្នានៅសេរីសួស្តីបានគិតរកនូវមង្គលទាំងឡាយ សូមព្រះអង្គ ទ្រង់ព្រះមេត្តាសំដែងប្រាប់នូវមង្គលដ៏ឧត្តម ( ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងតបពាក្យទេវតានោះ ដោយពុទ្ធភាសិតជាគាថាយ៉ាងនេះថា )

អសេវនា ច ពលានំ បណ្ឌិតានញ្ច សេវនា
បូជា ច បូជនីយានំ ឯតម្មង្គលមុត្តមំ ។

កិរិយាមិនសេពគប់នូវបុគ្គលពាលទាំងឡាយ ១ កិរិយាសេពគប់នូវបុគ្គលជា បណ្ឌិតទាំងឡាយ ១ កិរិយាបូជាដល់បុគ្គលដែលគួរបូជាទាំងឡាយ ១ ទាំង ៣ នេះជាមង្គលដ៏ឧត្តម ។

បដិរូបទេសវាសោ ច បុព្វេ ច កតបុញ្ញតា
អត្តសម្មាបណីធិ ច ឯតម្មង្គលមុត្តមំ ។

កិរិយានៅក្នុងប្រទេសដ៏សមគួរ ១ ភាវៈនៃបុគ្គលបានធ្វើបុណ្យទុកហើយក្នុងកាលមុន ១ កិរិយាដំកល់ខ្លួនដោយប្រពៃ ១ ទាំង ៣នេះជាមង្គលដ៏ឧត្តម ។

ពាហុសច្ចញ្ច សិប្បញ្ច វិនយោ ច សុសិក្ខិតោ
សុភាសិតា ច យា វាចា ឯតម្មង្គលមុត្តមំ ។

ភាវៈនៃបុគ្គលបានស្តាប់បានរៀន ហើយដោយច្រើន ១ សិល្បសាស្ត្រគឺ សេចក្តីឆ្លៀវឆ្លាសក្នុងហត្ថកម្មរបស់អ្នកបួស និង គ្រហស្ថ ១ វិន័យដែលបុគ្គលសិក្សាដោយប្រពៃ ១ វាចាដែលបុគ្គលពោលត្រឹមត្រូវ១ ទាំង ៤ នេះជាមង្គលដ៏ឧត្តម ។

មាតាបិតុឧបដ្ឋានំ បុត្តទារស្ស សង្គហោ
អនាកុលា ច កម្មន្តា ឯតម្មង្គលមុត្តមំ ។

កិរិយាបំរើនូវមាតា ១ កិរិយាបំរើនូវបិតា ១ សេចក្តីសង្គ្រោះដល់បុត្រ និងភរិយា ១ ការងារទាំងឡាយដែលមិនច្របូកច្របល់ ១ ទាំង ៤ នេះជាមង្គលដ៏ឧត្តម ។

ទានញ្ច ធម្មចរិយា ច ញាតកានញ្ច សង្គហោ
អនវជ្ជានិ កម្មានិ ឯតម្មង្គលមុត្តមំ ។

កិរិយាបរិច្ចាគទាន ១ កិរិយាប្រព្រឹត្តិនូវធម៌ ១ សេចក្តីសង្គ្រោះដល់ញាតិទាំងឡាយ ១ ការងារទាំងឡាយដែលមិនមានទោស ១ ទាំង ៤ នេះជាមង្គលដ៏ឧត្តម ។

អារតី វិរតី បាបា មជ្ជបានា ច សញ្ញមោ
អប្បមាទោ ច ធម្មេសុ ឯតម្មង្គលមុត្តមំ ។

កិរិយាមិនត្រេកអរក្នុងបាប និង កិរិយាវៀរចាកបាប ១ សេចក្តីសង្រួម ចាកកិរិយាផឹកនូវទឹកស្រវឹង ១ សេចក្តីមិនប្រមាទក្នុងធម៌ទាំងឡាយ ១ ទាំង ៣ នេះជាមង្គលដ៏ឧត្តម ។

គារវោ ច និវាតោ ច សន្តុដ្ឋី ច កតញ្ញុតា
កាលេន ធម្មស្សវនំ ឯតម្មង្គលមុត្តមំ ។

សេចក្តីគោរពចំពោះបុគ្គលដែលគួរគោរព ១ កិរិយាប្រព្រឹត្តិបន្ទាបនូវខ្លួន សេចក្តីត្រេកអរចំពោះរបស់ដែលមាន ១ ភាវៈនៃបុគ្គលអ្នកដឹងនូវឧបការៈ ដែលអ្នកដទៃធ្វើហើយដល់ខ្លួន កិរិយាស្តាប់នូវធម៌តាមកាល ១ ទាំង ៥ ជាមង្គលដ៏ឧត្តម ។

ខន្តិ ច សោវចស្សតា សមណានញ្ច ទស្សនំ
កាលេន ធម្មសាកច្ឆា ឯតម្មង្គលមុត្តមំ ។

សេចក្ដីអត់ធន់ ១ ភាវនៃបុគ្គលដែលគេប្រដៅ បានដោយងាយ១ កិរិយាបានឃើញបានជួបនូវសមណទាំងឡាយ ១ ធម្មសាកច្ឆា គឺ កិរិយាសន្ទនាទៅវិញទៅមកនូវធម៌តាមកាល ១ ទាំង ៤ នេះជា មង្គលដ៏ឧត្តម ។

តបោ ច ព្រហ្មចរិយញ្ច អរិយសច្ចានិ ទស្សនំ
និព្វានសច្ឆិកិរិយា ច ឯតម្មង្គលមុត្តមំ ។

សេចក្ដីព្យាយាមដុតនូវបាបធម៌ ១ កិរិយាប្រព្រឹត្តិនូវធម៌ដ៏ប្រសើរ១ កិរិយាឃើញនូវអរិយសច្ចទាំងឡាយ ១ កិរិយាធ្វើអោយជាក់ច្បាស់នូវ ព្រះនិព្វាន ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

ផុដ្ឋស្ស លោកធម្មេហិ ចិត្តំ យស្ស ន កម្បតិ
អសោកំ វិរជំ ខេមំ ឯតម្មង្គលមុត្តំ ។

ចិត្តនៃបុគ្គលឯណា ដែលលោកធម៌ទាំងឡាយពាល់ត្រូវហើយ មិន រំភើបញាប់ញ័រ ១ មិនមានសេចក្ដីសោក ១ មានធូលីគឺរាគៈទៅប្រាស ហើយ ១ ជាចិត្តក្សេមក្សាន្ត ១ ទាំង ៤ នេះជាមង្គលដ៏ឧត្តម ។

ឯតាទិសានិ កត្វាន សព្វត្ថមបរាជិតា សព្វត្ថ
សោត្ថិំ គច្ឆន្តិ តន្តេសំ មង្គលមុត្តមន្តិ ។

ទេវតា និងមនុស្សទាំងឡាយ ធ្វើនូវមង្គលទាំងឡាយប្រាកដដូច្នេះ ហើយជាអ្នកមិនចាលចាញ់ក្នុងទីទាំងពួង តែងដល់នូវសេរីសួស្ដីក្នុងទីទាំងពួង ( ម្នាលទេវតា អ្នកចូរប្រកាន់ជឿថា) មង្គលទាំង៣៨ ប្រការ មានកិរិយាមិនសេពគប់ នូវបុគ្គលពាលជាដើមនោះ របស់ ទេវតា និង មនុស្សទាំងអម្បាលណោះ ជាមង្គលដ៏ឧត្តម ។

## <u>ពុទ្ធភាសិត</u>

*បុគ្គលណា ជាអ្នកខ្ជិលច្រអូស មានសេចក្ដីព្យាយាមមិនល្អ គប្បីរស់នៅដល់ទៅ ១០០ ឆ្នាំ ការរស់នៅមួយថ្ងៃរបស់អ្នកមានសេចក្ដីព្យាយាម ខ្ជាប់ខ្ជួន ប្រសើរជាងការរស់របស់បុគ្គលដែលរស់នៅ ១០០ ឆ្នាំនោះ ។*

## ឱវាទបាដិមោក្ខ សង្ខេប

## ឱកាស ខ្ញុំសូមគោរព

យោ បន[(១)] ធម្មានុធម្មប្បដិបន្នោ វិហរតិ សាមីចិ

បដិបន្នោ អនុធម្មចារី សោ តថាគតំ សក្ករោតិ

គរុករោតិ មានេតិ បូជេតិ បរមាយ បូជាយ ដិបត្តិបូជាយ

អ្នកឯណាមួយជាអ្នកប្រតិបត្តិនូវធម៌ ដ៏សមគួរដល់ធម៌ជាអ្នកប្រតិបត្តិដោយត្រឹមត្រូវ ជាអ្នកប្រព្រឹត្តតាមធម៌ជាប្រក្រតី អ្នកនោះឈ្មោះថាធ្វើសក្ការៈ ធ្វើសេចក្តីគោរព រាប់អានបូជា នូវព្រះតថាគតដោយបដិបត្តិបូជា ជាបូជាដ៏ឧត្តម ។

សព្វបាបស្ស អករណំ កុសលស្សូបសម្បទា

សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំ

កិរិយាមិនធ្វើបាបទាំងពួង កិរិយាបំពេញកុសល កិរិយាធ្វើចិត្តរបស់ខ្លួនឱ្យផូរផង់ ទាំងនេះជាពាក្យប្រៀនប្រដៅនៃ ព្រះពុទ្ធទាំងឡាយ ។

ខន្តី បរមំ តបោ តីតិក្ខា និព្វានំ បរមំ វទន្តិ ពុទ្ធា ន ហិ

បព្វជិតោ បរូបឃាតី សមណោ ហោតិ បរំ វិហេឋយន្តោ

អំណត់ គឺសេចក្តីអត់ធន់ ជាតបធម៌ដ៏ឧត្តម ព្រះពុទ្ធទាំងឡាយទ្រង់ត្រាស់ថា ព្រះនិព្វានជាគុណជាតដ៏ឧត្តម អ្នកបួសដែលបៀតបៀនសត្វដទៃ សម្លាប់សត្វដទៃមិនមែនជាបព្វជិត មិនមែនជាសមណៈឡើយ ។

អនូបវាទោ អនូបឃាតោ បាតិមោក្ខេ ច សំវរោ

មត្តញ្ញុតា ច ភត្តស្មឹ បន្តញ្ច សយនាសនំ

អធិចិត្តេ ច អាយោគោ ឯតំ ពុទ្ធាន សាសនំ

កិរិយាមិនតិះដៀល(អ្នកដទៃ)១ កិរិយាមិនបៀតបៀន(អ្នកដទៃ)១ កិរិយាសង្រួមក្នុងបាតិមោក្ខ ១ ភាវដឹងប្រមាណក្នុងភត្តាហារ ១ ទីដេកនិងទីអង្គុយ ដ៏ស្ងាត់ ១ កិរិយាបំពេញព្យាយាម ក្នុងអធិចិត្ត ១ទាំងនេះជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ។

សីលសមាធិគុណានំ ខន្តិ បធានការណំ

សព្វេបិ កុសលា ធម្មា ខន្ត្យាយេវ វឌ្ឍន្តិ តេ

សេចក្តីអត់ធន់ ជាហេតុ ជាទីតាំងនៃគុណ គឺសីល និងសមាធិ ទាំងឡាយ ធម៌ទាំងឡាយជាកុសល ទាំងអស់នោះតែងចំរើនដោយសេចក្តីអត់ធន់មែនពិត ។

កេវលានំបិ បាបានំ ខន្តិ មូលំ និកន្តតិ

គរហកលហាទីនំ មូលំ ខណតិ ខន្តិកោ

(១) ច្បាប់ភាណវារៈខ្លះថា **យោ បន ភិក្ខុ** ច្បាប់ខ្លះថា មានត្រឹមតែប៉ុណ្ណោះ ។

សេចក្តីអត់ធន់ តែងកាត់បង់បាននូវឫសនៃបាបទាំងឡាយទាំងអស់ បុគ្គលអ្នកអត់ធន់ឈ្មោះថាជីករំលើងនូវឫសនៃទោសទាំងឡាយ មាន ពាក្យតិះដៀល នឹងការឈ្លោះប្រកែកជាដើម ។

ខន្តិ ធីរស្ស លង្ការោ ខន្តិ តបោ តបស្សិនោ

ខន្តិ ពលំ វ យតីនំ ខន្តិ ហិតសុខាវហា

សេចក្តីអត់ធន់ ជាគ្រឿងអលង្ការរបស់អ្នកប្រាជ្ញ សេចក្តីអត់ធន់ ជាគ្រឿងដុតបង់នូវបាបរបស់អ្នក ដែលមានតបធម៌ សេចក្តីអត់ធន់ជា កំលាំងរបស់អ្នកប្រព្រឹត្តធម៌ សេចក្តីអត់ធន់ជាគុណជាតិនាំ មកនូវ ប្រយោជន៍ និងសេចក្តីសុខ ។

ខន្តិកោ មេត្តវា លាភី យសស្សី សុខសីលវា

បិយោ ទេវមនុស្សានំ មនាបោ ហោតិ ខន្តិកោ

អ្នកអត់ធន់ ជាអ្នកមានមិត្រសំឡាញ់ ជាអ្នកមានលាភ ជាអ្នក មានយស ជាអ្នកមានសេចក្តីសុខជាប្រក្រតី អ្នកអត់ធន់រមែងជាទីស្រឡាញ់ ជាទីគាប់ចិត្តនៃទេវតា និង មនុស្សទាំងឡាយ ។

អត្តនោបិ បរេសញ្ច អត្ថាវហោវ ខន្តិកោ

សគ្គមោក្ខគមំ មគ្គំ អារុឡ្ហោ ហោតិ ខន្តិកោ

អ្នកអត់ធន់ជាអ្នកនាំមកនូវប្រយោជន៍ដល់ខ្លួនឯងផង ដល់ជនទាំងឡាយ ឯទៀតផង អ្នកអត់ធន់ ជាអ្នកឡើងកាន់ផ្លូវជាទៅឋានសួគ៌និងព្រះនិព្វាន ។

សត្ថុនោ វចនោវាទំ ករោតិយេវ ខន្តិកោ

បរមាយ ច បូជាយ ជិនំ បូជេតិ ខន្តិកោ

អ្នកអត់ធន់ឈ្មោះថាធ្វើតាម នូវព្រះពុទ្ធដីកាជាឱវាទនៃព្រះសាស្តា មែនពិតអ្នកអត់ធន់ ឈ្មោះថាបូជានូវព្រះវិជិតមារ ដោយការបូជាដ៏ឧត្តម ។

ទុល្លភញ្ច មនុស្សត្តំ ពុទ្ធុប្បាទោ ច ទុល្លភោ

ទុល្លភា ខណសម្បត្តិ សទ្ធម្មោ បរមទុល្លភោ

ភាវៈកើតជាមនុស្ស គឺសត្វទាំងឡាយបានដោយកម្រ កិរិយាត្រាស់ ជាព្រះពុទ្ធ គឺសត្វទាំងឡាយបានដោយកម្រ កិរិយាដល់ព្រម ដោយខណៈ គឺបានកើតជួប នឹងព្រះពុទ្ធ ឬនឹងព្រះពុទ្ធសាសនា គឺសត្វទាំងឡាយបាន ដោយកម្រ ធម៌របស់សប្បុរស គឺសត្វទាំងឡាយបានដោយកម្រក្រៃលែង ។

សុខោ ពុទ្ធានមុប្បាទោ សុខា សទ្ធម្មទេសនា

សុខា សង្ឃស្ស សាមគ្គី សមគ្គានំ តបោ សុខោ

កិរិយាបានត្រាស់នៃព្រះពុទ្ធទាំងឡាយ នាំមកនូវសេចក្តីសុខកិរិយា សំដែងនូវធម៌របស់សប្បុរសនាំមកនូវសេចក្តីសុខ សេចក្តីព្រមព្រៀងគ្នា

របស់សង្ឃឬពួកក្រុម នាំមកនូវសេចក្តីសុខ សេចក្តីព្យាយាមរបស់អ្នកដែលព្រមព្រៀងគ្នាទាំងឡាយនាំមកនូវសេចក្តីសុខ ។

សុខោ វិវេកោ តុដ្ឋស្ស     សុតធម្មស្ស បស្សតោ
អព្យាបជ្ឈំ សុខំ លោកេ     បាណភូតេសុ សញ្ញមោ

សេចក្តីស្ងប់ស្ងាត់ របស់អ្នកដែលត្រេកអរ (ក្នុងទីស្ងាត់) ជាអ្នក មានធម៌បានស្តាប់ហើយ ពិចារណាឃើញ (នូវធម៌) នាំមកនូវសេចក្តីសុខកិរិយាមិនបៀតបៀន គឺកិរិយាសង្រួមចំពោះសត្វទាំងឡាយនាំមកនូវសេចក្តីសុខក្នុងលោក ។

សុខា វិរាគតា លោកេ     កាមានំ សមតិក្កមោ
អស្មិមានស្ស វិនយោ     ឯតំ វេ បរមំ សុខំ

ភាវៈប្រាសចាករាគៈ គឺកិរិយាកន្លងនូវកាមទាំងឡាយ នាំមកនូវសេចក្តីសុខក្នុងលោក កិរិយាធ្វើអោយវិនាសនូវអស្មិមានៈនេះឯងនាំមកនូវសេចក្តីសុខដ៏ឧត្តម ។

កិច្ឆោ មនុស្សបដិលាភោ     កិច្ឆំ មច្ចាន ជីវិតំ
កិច្ឆំ សទ្ធម្មស្សវនំ     កិច្ឆោ ពុទ្ធានមុប្បាទោ

កិរិយាត្រឡប់បានអត្តភាពជាមនុស្សជាការលំបាក សេចក្តីរស់នៅរបស់សត្វទាំងឡាយជាការលំបាក កិរិយាស្តាប់នូវព្រះសទ្ធម្មជាការ លំបាក កិរិយាបានត្រាស់នៃព្រះពុទ្ធទាំងឡាយជាការលំបាក ។

សត្ថុនោ សទ្ធម្មំ សុត្វា     សព្វស្មឹ ជិនសាសនេ
កប្បានិ សតសហស្សានិ     ទុគ្គតឹ សោ ន គច្ឆតិ

បុគ្គលឯណាបានស្តាប់នូវព្រះសទ្ធម្មរបស់ព្រះសាស្តា ( ដែលរាប់បញ្ចូល) ក្នុងពាក្យប្រៀនប្រដៅនៃព្រះវិជិតមារទាំងពួង បុគ្គលនោះរមែងមិនទៅកាន់ទុគ្គតិអស់សែនកប្ប ។

បុព្វណ្ហេ បិណ្ឌបាតញ្ច     សាយណ្ហេ ធម្មទេសនំ
បទោសេ ភិក្ខុឱវាទំ     អឌ្ឍរត្តេ ទេវបញ្ហនំ
បច្ចូសេវ គតេ កាលេ     ភព្វាភព្វេ វិលោកនំ
ឯតេ បញ្ចវិធេ កិច្ចេ     វិសោធេតិ មុនិបុង្គវោតិ

ព្រះសម្មាសម្ពុទ្ធជាច្បងជាងអស់អ្នកប្រាជ្ញ ទ្រង់ជំរះនូវពុទ្ធកិច្ចទាំងឡាយ ៥ ប្រការនេះគឺក្នុងពេលព្រឹក ទ្រង់ស្តេចទៅបិណ្ឌបាត ១ ក្នុងពេលល្ងាច ទ្រង់សំដែងធម៌ទេសនា ១ ក្នុងពេលព្រលប់ ទ្រង់ប្រទានឱវាទ ដល់ពួកភិក្ខុ ១ ក្នុងពេលអាធ្រាត្រ ទ្រង់ដោះប្រស្នានៃទេវតា ១ ក្នុងពេលជិតភ្លឺ ទ្រង់ប្រមើលនូវសត្វលោកដែលគួរត្រាស់ដឹងនឹងមិនគួរត្រាស់ដឹង ១។

កុក្កុដេ គព្ភវាសោ ច    សោណេ    ចុទរនិក្ខមិ
ឧសភេ រាជសម្បត្តិ    សសេ បព្វជិតោ ជិនោ

ព្រះវិជិតមារ ទ្រង់យាងចុះមកអាស្រ័យ នៅក្នុងព្រះគភ៌ (នៃព្រះវរមាតា) ក្នុងឆ្នាំរកា ទ្រង់ប្រសូតចាកព្រះគភ៌ក្នុងឆ្នាំ ច ទ្រង់សោយរាជសម្បត្តិក្នុងឆ្នាំឆ្លូវ ទ្រង់ព្រះផ្នួសក្នុងឆ្នាំថោះ ។

កុក្កុដេ សព្វញ្ញុ ពុទ្ធោ    តត្ថ    ចក្កំ    បវត្តយិ
និព្វានគមនំ សប្បេ    សហស្សំ បញ្ច មូសិកេ

ទ្រង់ត្រាស់ដឹងជាព្រះសព្វញ្ញុពុទ្ធក្នុងឆ្នាំរកា ទ្រង់សំដែងនូវព្រះធម្មចក្រក្នុងឆ្នាំនោះ ទ្រង់យាងចូលកាន់ព្រះនិព្វានក្នុងឆ្នាំម្សាញ់ ព្រះពុទ្ធសាសនានឹងគ្រប់ ៥.000 ក្នុងឆ្នាំជូត ។

ឱក្កន្តោ ច គរុវារស្មឹ    សុក្រវារេ ច និក្ខមិ
សម្ពុទ្ធោ ពុធវារស្មឹ    អង្គារេ បរិនិព្វុតោ

ទ្រង់យាងចុះកាន់ព្រះគភ៌ (នៃព្រះវរមាតា) ក្នុងថ្ងៃព្រហស្បតិ៍ ប្រសូតក្នុងថ្ងៃសុក្រ បានត្រាស់ជាព្រះសម្ពុទ្ធក្នុងថ្ងៃពុធ បរិនិព្វានក្នុងថ្ងៃអង្គារ ។

អាសាឡ្ហបុណ្ណមោក្កន្តោ    វិសាខយេវ និក្ខមិ
វិសាខបុណ្ណមី សម្ពុទ្ធោ    វិសាខេ បរិនិព្វុតា

ព្រះអង្គយាងចុះកាន់ព្រះគភ៌ (នៃព្រះវរមាតា) ក្នុងថ្ងៃពេញបូណ៌មីខែអាសាធប្រសូតក្នុងថ្ងៃពេញបូណ៌មីខែវិសាខ បានត្រាស់ជាព្រះសម្ពុទ្ធ ក្នុងថ្ងៃពេញបូណមី

និព្វុតេ លោកនាថម្ហិ    សម្ពុទ្ធេ អគ្គបុគ្គលេ
បដិមា ពោធិរុក្ខា ច    ថូបា ច ជិនធាតុយោ
ចតុរាសីតិសហស្ស    ធម្មក្ខន្ធា សុទេសិតា
អគ្គប្បវត្តនដ្ឋានេ    ឋបិតា ហោន្តិ បាណិនំ

កាលព្រះសម្ពុទ្ធ ជាអគ្គបុគ្គល ជាទីពឹងនៃសត្វលោក បរិនិព្វានទៅហើយព្រះបដិមាផង ពោធិព្រឹក្សផង ព្រះសថូបផងព្រះជិនធាតុផង ព្រះធម៌ ៨ ហ្មឺន ៤ ពាន់ធម្មក្ខន្ធ ដែលព្រះអង្គទ្រង់សំដែងហើយដោយប្រពៃផង ជាវត្ថុគឺព្រះសម្មាសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក ក្នុងស្ថានដ៏ប្រព្រឹត្តទៅដើម្បីជាបុញ្ញក្ខេត្ត ដ៏ប្រសើររបស់សត្វទាំងឡាយ ។

ឥតិ សម្មាសម្ពុទ្ធេន    ទេសិតំ ឱវាទំ ចិត្តេ
ឋបេត្វា សម្មាសម្ពុទ្ធេន    វុត្តប្បការេ បដិបត្តិបូជាយ

បូជំ  ករោន្តេន          លោកិយលោកុត្តរសម្បត្តិសិទ្ធំ

កាតព្វំ  ឧកាស          អារាធនំ    ករោមិ ។

បុគ្គលគួរតំកល់នូវឱវាទ   ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងហើយ ទុកក្នុងចិត្តហើយធ្វើការបូជា   ដោយបដិបត្តិបូជា ដោយនូវប្រការដែលព្រះសម្មាសម្ពុទ្ធត្រាស់សំដែងហើយ  គួរធ្វើអោយសំរេចនូវសម្បត្តិជាលោកិយ និង លោកុត្តរ ខ្ញុំសូមគោរពអារាធនាទុកដោយប្រការដូច្នេះ ។

ឧកាស សិរីសក្យមុនីសព្វញ្ញុពុទ្ធស្ស ពលវប្បច្ចូស

សមយេ កុសិនារាយ     យមកសាលានមន្តរេ

អមុម្ហិ សប្បសំវច្ឆរេ គិម្ហ  ឧតុម្ហិ  វិសាខមាសេ

សុក្កបក្ខេ បណ្ណរសិយា    តិថិយំ កុម្ភវារេ ភុម្មយាមេ

អនុរាធនក្ខត្តទិវសេ     បរិនិព្វានំ អហោសិ

អនុបាទិសេសាយ        និព្វានធាតុយា   ។

សូមគោរព សម្តេចព្រះសិរីសក្យមុនីសព្វញ្ញុពុទ្ធជាម្ចាស់ ទ្រង់ បរិនិព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុ ក្នុងចន្លោះសាលព្រឹក្សទាំងមូលគួរជិតក្រុងកុសិនារា  ក្នុងបច្ចូសសម័យដ៏មានកំលាំង  ក្នុងថ្ងៃនៃនក្ខប្ញក្ស ឈ្មោះអនុរាធាក្នុងថ្ងៃអង្គារ  យាមអង្គារជាតិថីពេញបូណ៌មីខាងខ្នើតខែពិសាខក្នុងគិម្ហរដូវ ឆ្នាំម្សាញ់ឯណោះហោង ។

( តពីនេះទៅត្រូវបកសករាជប្រាប់ថ្ងៃ ខែ ឆ្នាំដែលកន្លងហើយនឹងបច្ចុប្បន្ន និង អនាគត ដរាបដល់ចប់)

# បច្ឆិមពុទ្ធវចនៈ

យោ វោ អានន្ទ   មយា   ធម្មោ

ច វិនយោ ច   ទេសិតោ បញ្ញត្តោ

ម្នាលអានន្ទ សភាវណា គឺព្រះធមិក្តី ព្រះវិន័យក្តី ដែលតថាគតបានសំដែងហើយ បានបញ្ញត្តហើយដល់អ្នកទាំងឡាយ ។

សោ   វោ  មមច្ចយេន   សត្ថា

សភាគឺព្រះធមិ និង ព្រះវិន័យនោះ លុះលំណើះឥតអំពីតថាគតទៅហើយ នឹងបានជាគ្រូប្រៀនប្រដៅនូវអ្នកទាំងឡាយ ។

អហំ ឯកកោវ បរិនិព្វាយិស្សាមិ

តថាគតជាព្រះពុទ្ធមួយអង្គឯងពិត នឹងបរិនិព្វានទៅ ។

អហញ្ច បនិទានិ ឯកកោវ  ឱវទាមិ អនុសាសេមិ

តែថាឥឡូវនេះ   តថាគតជាព្រះពុទ្ធមួយអង្គឯងពិត  តែងទូន្មានប្រៀនប្រដៅនូវអ្នកទាំងឡាយ ។

## មយិ បរិនិព្វុតេ

កាលបើតថាគតបរិនិព្វានទៅហើយ

ឥមានិ ចតុរាសីតិធម្មក្ខន្ធសហស្សានិ

តុម្ហេ ឱវទិស្សន្តិ អនុសាសិស្សន្តិ

ព្រះធម្មក្ខន្ធ ប្រាំបីហ្មឺន បួនពាន់នេះ នឹងទូន្មានប្រៀនប្រដៅនូវទាំងឡាយជាខាងក្រោយ ។

យោ កោចិ អានន្ទ ភិក្ខុ វា ភិក្ខុនី វា

ឧបាសកោ វា ឧបាសិកា វា ធម្មានុធម្មប្បដិបន្នោ

វិហរតិ សាមីចិ បដិបន្នោ អនុធម្មចារី

ម្នាលអានន្ទ បុគ្គលឯណាមួយ គឺភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ជាអ្នកប្រតិបត្តិធម៌វិន័យតាមសមគួរដល់ធម៌វិន័យ ជាអ្នកប្រតិបត្តិដោយសេចក្តីគោរពកោតក្រែងដល់ធម៌វិន័យ ប្រព្រឹត្តតាមធម៌វិន័យ ប្រព្រឹត្តតាមធម៌វិន័យជាប្រក្រតី ។

សោ តថាគតំ សក្ករោតិ គរុករោតិ មានេតិ

បូជេតិ មរមាយ បូជាយ បដិបត្តិបូជាយ

បុគ្គលទាំងអស់នោះ បានឈ្មោះថាធ្វើសក្ការៈ នឹងតថាគត ធ្វើនូវសេចក្តីគោរពតថាគតរាប់អាននូវតថាគត បូជានូវតថាគត ដោយបដិបត្តិបូជា បូជាយ៉ាងក្រៃលែង ។

ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ ភិក្ខវេ ខយវយធម្មា

សង្ខារា អប្បមាទេន សម្បាទេថាតិ ឥទម្បច្ឆិមពុទ្ធ វចនំ

ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះតថាគត នឹងផ្តាំនូវអ្នកទាំងឡាយអោយបានដឹងគ្រប់គ្នា នៃភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មានកិរិយាអស់ទៅ នឹងសាបសូន្យទៅជាធម្មតា។ អ្នករាល់គ្នា ចូរញុំាង ប្រយោជន៍អោយដល់ព្រមដោយអប្បមាទៈ គឺមានការបណ្តែតបណ្តោយក្នុងធម៌វិន័យពាក្យប្រៀនប្រដៅ មានប្រមាណប៉ុណ្ណេះជាដើមនេះ ឈ្មោះថាបច្ឆិមពុទ្ធ-វចនៈ ជាពាក្យផ្តាំពៅបំផុតរបស់ព្រះពុទ្ធជាម្ចាស់នៃយើង ។

ឧភិន្នមន្តរេ យំ វុត្តំ ឯតំ មជ្ឈិមពុទ្ធវចនំ

ពាក្យប្រដៅណា ដែលទ្រង់ត្រាស់ពោលជាចន្លោះនៃបឋមពុទ្ធវចនៈ និងបច្ឆិមពុទ្ធវចនៈ ទាំងពីរនេះពាក្យប្រដៅនោះ ឈ្មោះថាមជ្ឈិមពុទ្ធវចនៈ គឺពាក្យប្រដៅជាកណ្តាល របស់ព្រះពុទ្ធជាបរមគ្រូ( នៃយើង) ។

**(ចប់បច្ឆិមពុទ្ធវចនៈ)**

## សំវេជនីធម៌

អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ
ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ ។

ប្រែបទពាក្យ ៧

ឱសត្វសង្ខារទាំងឡាយអើយ មែនពិតណាស់ហើយមិនទៀងទាត់
កើតហើយតែងតែវិនាសព្រាត់ បង់បាត់ទៅវិញជាធម្មតា ។
លុះតែរំលត់សង្ខារនោះ ទើបបានសុខស្មោះពេកណាស់ណា
ហេតុនេះបរិស័ទពុទ្ធសាសនា គួរពិចារណាគ្រប់ៗប្រាណ ។
ឱ្យយល់ច្បាស់នូវដំណើរការ របស់សង្ខារទាំងប៉ុន្មាន
ដើម្បីជាហេតុអោយខ្លួនបាន ធ្វើទាន និងសីលភាវនាហោង ។

អចិរំ វត យំ កាយោ បថវឹ អធិសេស្សតិ
ឆុទ្ធោ អបេតវិញ្ញាណោ និរត្ថំវ កលិង្គរំ ។

ប្រែបទពាក្យ ៧

ឱកាយនៃមនុស្សសត្វគ្រប់ប្រាណ រស់នៅមិនបានប៉ុន្មានឡើយ
កាលបើវិញ្ញាណចេញបាត់ហើយ តែងដេកកល់កើយលើប្រឋពី ។
គេតែងកប់ចោលក្នុងពសុធា ឬដុតបូជាឆេះខ្មេចខ្ទី
ទៅជាចំណីព្រះអគ្គី ដូចឧសពេញទីឥតផលសោះ ។
(ហេតុនោះទើបព្រះចមភពត្រៃ ទ្រង់មានព្រះទ័យអនុគ្រោះ
សំដែងព្រះធម៌ពិរោះ បណ្តុះចិត្តពុទ្ធបរិស័ទផង ។
ឱ្យដុះសតិ និង បញ្ញា ចេះពិចារណាត្រិះរិះត្រង់
ត្រៃលក្ខណញាណល្អកន្លង ដើម្បីបានឆ្លងអវិជ្ជា ។
ហើយបានកសាងការថ្កើងថ្កល់ កុសលទានសីល និង ភាវនា
គ្រាន់ជាទីពឹងពួនគ្រប់គ្នា ក្នុងជាតិនេះណាជាតិមុខហោង) ។

សព្វេ សត្តា មរិស្សន្តិ មរណន្តំ ហិ ជីវិតំ
យថាកម្មំ គមិស្សន្តិ បុញ្ញបាបផលូបគា
និរយំ បាបកម្មន្តា បុញ្ញកម្មា ច សុគតឹ ។
តស្មា ករេយ្យ កល្យាណំ និចយំ សម្បរាយិកំ
បុញ្ញានិ បរលោកស្មឹ បតិដ្ឋា ហោន្តិ បាណិនំ ។

ប្រែបទពាក្យ ៧

ពួកសត្វទាំងពួងតែងស្លាប់ពិត ព្រោះជាជីវិតតែងតែមាន
សេចក្តីស្លាប់នៅចុងគ្រប់ប្រាណ ចៀសគេចពុំបានដល់មួយឡើយ ។
សត្វដែលស្លាប់ទៅជាដរាប តែងយកផលបាបបុណ្យធ្វើហើយ

តាមយថាកម្មពុំផុតឡើយ    ដែលធ្វើបាបហើយទៅនរក ។
ចំណែកខាងបុណ្យដែលធ្វើត្រូវ    តែងទៅឋានសួគ៌ជាខាងមុខ
កើតក្នុងទេវលោកឥតមានទុក្ខ    ជាសុខសម្រាណពុំមានហ្មង ។
(ព្រោះហេតុនេះឯងជនគ្រប់គ្នា    ដែលមានសទ្ធាគិតប៉ុនប៉ង
ចង់បានក្តីសុខគួរត្រិះត្រង    ធ្វើបុណ្យទានផងជាប្រញាប់ ។
គ្រាន់ជាទីពឹងពុំនាក់ខ្លួន    ឱ្យបានមាំមួនត្រូវតាមច្បាប់
ដែលព្រះពុទ្ធអង្គទ្រង់បញ្ញត្ត    តាមដោយសណ្តាប់ប្រពៃណី ។
ព្រះពុទ្ធអំពីបុរាណនាយ    ព្រោះបុណ្យទាំងឡាយតែងជាទី
ពឹងពួននៃសត្វទាំងភពបី    នៅនាលោកិយនិងលោកនាយ) ។

អាយុ ឧស្មា ច វិញ្ញាណំ    យទា កាយំ ជហន្តិមំ
អបវិដ្ឋោ តទា សេតិ    និរត្ថំវ កលិង្គរំ ។

ប្រែ បទពាក្យ ៧

អាយុភ្លើងធាតុឬវិញ្ញាណ    បើបានលះបង់កាយកាលណា
កាយនេះមិនគួរទុករក្សា    នៅលើគេហាយើងនេះបាន ។
គេតែងតែនាំយកទៅបោះ    ចោលលើដីស្មោះឬកប់ប្រាណ
ដូចអង្កត់ឧសជាពុំខាន    រកប្រយោជន៍គ្មានដល់តិចសោះ ។
(ហេតុនេះយើងជាពុទ្ធបរិស័ទ    គួរគិតប្រយ័ត្នទុកដោយស្មោះ
ពីក្មេងៗទៅកុំបង់បោះ    ចំពោះសីល ទាន និង ភាវនា ។
កុំគិតតែក្តីសប្បាយពេក    គួរតែក្រឡេកមើលវេលា
កុំចាំជីវិតដាច់ខ្យល់មរណា    ទើបភ្ញាររកបុណ្យពុំងាយឡើយ) ។

យថា ទណ្ឌេន គោបាលោ    គាវោ បាជេតិ គោចរំ
ឯវំ ជរា ច មច្ចុ ច    អាយុំ បាជេន្តិ បាណិនំ ។

ប្រែ បទពាក្យ ៧

អស់ពួកគង្វាលគោទាំងឡាយ    គេវាយគេដេញដោយរំពាត់
កៀងគោគេទៅតាមកំណត់    ដល់ទីសន្ធតនោះយ៉ាងណា ។
ជរាគឺក្តីចាស់ទ្រុឌទ្រោម    តែងចោមកៀងសត្វរាល់រូបា
ទៅកាន់មរណជាធម្មតា    ពុំមានសត្វណាចៀសបានឡើយ ។
(ហេតុនេះគួរយើងរាល់រូបកាយ    ខ្វល់ខ្វាយរកបុណ្យជាកោះត្រើយ
ពីក្មេងៗទៅទុកអោយហើយ    កុំបង្អង់ឡើយក្រែងខកការ ។
ព្រោះបុណ្យដែលសត្វធ្វើនោះឯង    រមែងជាគុណមានខ្លឹមសារ
ឱ្យផលជាសុខយ៉ាងអស្ចារ្យ    គួរតាមកិច្ចការដែលធ្វើហោង) ។

# ប្រស្នាត្រៃគុណ

## ពុទ្ធគុណបញ្ញា

### ការចោទ-ឆ្លើយក្នុងគុណព្រះពុទ្ធ

**ស.**ពាក្យថា **ពុទ្ធគុណ** ប្រែថាដូចម្តេច ? បានដល់អ្វី ? មានប៉ុន្មានប្រការ ? ចូរអធិប្បាយ !

**ឆ.** ពាក្យថា **ពុទ្ធគុណ** ប្រែថា គុណរបស់ព្រះពុទ្ធ ។ គុណរបស់ព្រះពុទ្ធ ឬ ព្រះពុទ្ធទ្រង់មានគុណនេះ បើរាប់ដោយខ្លីមកមាន ៣ ប្រការគឺ :

**១-បញ្ញាគុណ** គុណគឺប្រាជ្ញា ។ បញ្ញាគុណនេះសំដៅយកប្រាជ្ញាសម្មាសម្ពោធិញ្ញាណ ដែលជាសតិ ពុទ្ធិ ចំណេះចេះដឹងដ៏ប្លែកហើយមានប្រសិទ្ធិភាពយ៉ាងខ្លាំង ។ ព្រះពុទ្ធជាបុគ្គលដែលមានបញ្ញាមួយដ៏ខ្ពស់លើសលប់ លើអ្នកប្រាជ្ញឬសាស្តាចារ្យនានាក្នុងលោក ត្រង់ព្រះអង្គ ទ្រង់មានសម្មាសម្ពោធិញ្ញាណនេះឯង ។ ប្រាជ្ញាដ៏ច្រើនលើសលុបនេះកើតមកពីការសន្សំរបស់ព្រះអង្គ អស់ច្រើន កប្បកល្ប ហើយជាពិសេសគឺព្រះអង្គជ្រាបនូវហេតុផលមានប្រយោជន៍ ឥតប្រយោជន៍ ពីអតីតកាល,បច្ចុប្បន្នកាល និង អនាគតកាល ដោយជាក់ច្បាស់ថែមទៀត ។ ការជ្រាបហេតុផលដ៏ច្បាស់លាស់នេះហើយ ហៅថា បញ្ញាគុណ គឺព្រះពុទ្ធទ្រង់ ប្រកបដោយគុណ គឺប្រាជ្ញា ។

**២-វិសុទ្ធិគុណ** គុណគឺសេចក្តីស្អាតបរិសុទ្ធ ។ វិសុទ្ធគុណ នេះមិនមែនជាការស្អាត ដោយការប្រព្រឹត្តិធ្វើធម្មតានោះឡើយ គឺសេចក្តីស្អាតបរិសុទ្ធ។ ដែលជាគុណជាតិដ៏ថ្លាល្វេងជ្រះស្រឡះគ្មានមន្ទិលកិលេសតណ្ហានោះឯង ។ កាយ វិចា ចិត្ត របស់ព្រះពុទ្ធជាវត្ថុស្អាតថ្លាឥតជាប់ទាក់ទងដោយគ្រឿងសៅហ្មងអ្វីឡើយ ស្អាតទាំងវិចីបយោគ ទាំងកាយ-បយោគ ។

**៣-ករុណាគុណ** គុណគឺសេចក្តីអាណិតអាសូរ ។ ករុណាគុណនេះជាព្រះធមិ ១ ដ៏សំខាន់របស់ព្រះពុទ្ធជាម្ចាស់របស់ព្រះអង្គទ្រង់មានព្រះទ័យអាណិតអាសូរ ចំពោះសត្វលោកក្នុងត្រៃភព ដែលកំពុងទទួលទុក្ខលំបាកដោយសារកិលេស តណ្ហា កំពុងដុតរោល រាល់ពេលវេលា ។ ព្រះពុទ្ធជាម្ចាស់ កាលបានត្រាស់ដឹងធមិ ដោយព្រះអង្គឯងហើយទ្រង់ក៏យកធមិនោះទៅពន្យល់ទូន្មានចំពោះសត្វលោកទៀត ។ ការទៅប្រោសសត្វសព្វទិសទីនោះ មិនមែនដើម្បីបានកម្រៃផលណាមួយសំរាប់ព្រះអង្គសោះឡើយ ប៉ុន្តែព្រះអង្គធ្វើ ព្រោះតែទ្រង់មានព្រះទ័យអាណិតអាសូរចំពោះសព្វសត្វហ្នឹងឯង ។

គុណទាំង ៣ យ៉ាងនេះ តែងមានចំពោះព្រះពុទ្ធគ្រប់ព្រះអង្គហើយ ជាកំពូលនៃគុណឯទៀតៗ ទាំងអស់ ។

**ស.** ព្រះពុទ្ធជាបុគ្គលអស្ចារ្យ មានឫទ្ធី អំណាចណាស់ ។ បើដូច្នោះតើព្រះអង្គមានបាដិហារ្យប៉ុន្មានយ៉ាង ? អ្វីខ្លះ ? ចូររាប់ហើយ អធិប្បាយ !

**ច.បាដិហារ្យ** គឺការសំដែងភាពអស្ចារ្យរបស់ ព្រះសម្ពុទ្ធមានច្រើនប្រការណាស់ ប៉ុន្តែបើបំព្រួញមកមានតែ ៣ ប្រការប៉ុណ្ណោះ គឺ :

**១-ឥទ្ធិប្បាដិហារ្យ** អំណាចអស្ចារ្យដោយឫទ្ធិ ពោលគឺព្រះអង្គជាបុគ្គលមានឫទ្ធិ អាចសំដែងថ្លែងឫទ្ធិនេះយ៉ាងណាក៏បាន ទោះជ្រែកដី-ទឹក ហោះហើរធ្វើឱ្យកើតជាអ្វីក៏បាន ឧទាហរណ៍ដូចជាព្រះអង្គធ្វើយមកប្បាដិហារ្យ ផ្ចាញ់ពួកនិគ្រន្ថ ដោយបណ្ដោយឱ្យទទឹក. ទភ្លើងហូរចេញការណ៏ទាំងសងខាងព្រះអង្គ ឬ ធ្វើបាដិហារ្យចំនួន១៥០០ បែបផ្ចាញពួកជដិលជាបងប្អូន ៣ នាក់ នៅក្បែរគយាសីស ប្រទេសជាដើម ។

**២-អាទេសនាបាដិហារ្យ** អំណាចអស្ចារ្យដោយការស្គាល់ ចិត្តមនុស្សសត្វ បានសេចក្ដីថា ព្រះពុទ្ធជាម្ចាស់ទ្រង់អាចស្គាល់ហើយអាចទាយទឹកចិត្តមនុស្សសត្វ បានយ៉ាងច្បាស់ពិតប្រាកដ ។

**៣-អនុសាសនបាដិហារ្យ** អំណាចអស្ចារ្យក្នុងការសំដែងធម៌ប្រោសសត្វ ពោលគឺព្រះអង្គជាសាស្ដាចារ្យមួយអង្គដ៏ប៉ិនប្រសប់ក្នុងការសំដែងធម៌អាចធ្វើអោយអ្នកស្ដាប់ទទួលយកពាក្យប្រៀនប្រដៅនោះទៅប្រតិបត្តិដោយសេចក្ដីរីករាយ គ្មានការបង្ខិតបង្ខំពីព្រះអង្គឬជនណាឡើយ ។

**ស-** ដើម្បីរំលឹកគុណព្រះពុទ្ធ ពួកបរិស័ទតែងសូត្រ **ឥតិបិសោ ភគវា អរហំ** រហូតដល់ **ភគវាតិ** ។ បើដូច្នេះតើពាក្យថា **អរហំ ភគវា**” នេះតើជាអ្វីរបស់ព្រះពុទ្ធ ? មានប៉ុន្មាន? ចូររាប់ !

**ច-** ពាក្យថា **អរហំ ភគវា** ជាព្រះនាមរបស់ព្រះពុទ្ធ ហ្នឹងឯង. ពះនាមនេះមាន ១០ យ៉ាងគឺ អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថាទេវតាមនុស្សានំ ពុទ្ធោ ភគវា ។

**ស-** នាមទាំង ១០ នេះ អ្នកណាថ្វាយដល់ព្រះអង្គ ?ឬព្រះអង្គ ទ្រង់ដាក់ដោយព្រះអង្គឯង ? ដោយហេតុអ្វី ?

**ច-** ពួកមនុស្សនិងទេវតា បានថ្វាយដល់ព្រះអង្គពុំមែនព្រះអង្គដាក់ដោយព្រះអង្គឯងឡើយ ។ ការថ្វាយព្រះនាមនេះ គឺធ្វើសមស្របតាមគុណសម្បត្តិ របស់ព្រះអង្គដែលព្រះអង្គមាន ។

**ស-** ព្រះនាមថា **អរហំ** គឺមានន័យសេចក្ដីយ៉ាងណាខ្លះ ? ចូរអធិប្បាយពន្យល់ !

**ច-** ព្រះពុទ្ធអង្គទ្រង់មានព្រះនាមថា **អរហំ** មានន័យថាព្រះ អង្គទ្រង់

ជាបុគ្គលឆ្ងាយចាកពួកសឹកសត្រូវ ពោលគឺកិលេសព្រមទាំងវាសនា គឺ កាយបយោគ និង វចីបយោគ ។ ពាក្យថាកិលេសដែលជាសឹកសត្រូវនេះ មានច្រើនប្រការណាស់ មាន រាគៈ ទោសៈ មោហៈ កាមៈ ទិដ្ឋិ អវិជ្ជា ជាដើម ។ កិលេសមានរាគៈជាដើមនេះជាសត្រូវមារ ជាគ្រឿងរារាំងចិត្ត ជាគ្រឿងធ្វើអោយចិត្តឃ្លេងឃ្លោងញាប់ញ័ររំភើបទៅតាមអារម្មណ៍ផ្សេងៗដែលកើតឡើង ។

ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលមានព្រះទ័យ គឺចិត្តដ៏ល្អបរិសុទ្ធ ស្អាត. គ្មានកិលេសណាមួយ ត្រាំនៅក្នុងព្រះទ័យសោះឡើយ ។

មិនតែប៉ុណ្ណោះ ព្រះពុទ្ធអង្គទ្រង់គ្មានកាយបយោគ និង វចីបយោគទៀតផង ។ ពាក្យថាកាយបយោគ គឺជាអំពើល្អអាក្រក់តាមផ្លូវកាយ. ព្រះសារីបុត្តជាអគ្គសាវ័កស្តាំ ក៏នៅជាប់នៅដោយ កាយបយោគដែរ ដូចជាការហក់លោតជាដើម ។ ព្រះមហាកច្ចាយនៈជាព្រះអរហន្តដែរ ប៉ុន្តែនៅជាប់ដោយវចីបយោគ ពោលពាក្យច្រើនមិនសូវមានប្រយោជន៍ ។

ចំណែកខាងព្រះសម្មាសម្ពុទ្ធវិញ ទ្រង់គ្មានទាំងកិលេសតណ្ហាគ្មានទាំងកាយបយោគ និង វចីបយោគ ។

ម្យ៉ាងវិញទៀត ពាក្យថា **អរហំ** នេះនឹងអាចប្រែថា គួរក៏បានគឺ ព្រះពុទ្ធ ជាអរិយបុគ្គល គួរជាទីបូជានៃមនុស្ស និង ទេវតាសត្វធាតុផ្សេងៗ។

**ស**~ ចុះពាក្យថា **សម្មាសម្ពុទ្ធោ** ប្រែដូចម្តេច ? ចូរអធិប្បាយពន្យល់ !

**ច**~ព្រះនាមថា **សម្មាសម្ពុទ្ធោ** ប្រែថាព្រះពុទ្ធជាអ្នកត្រាស់ដឹងដោយប្រពៃដោយព្រះអង្គឯងផង ។

ពាក្យថាត្រាស់ដឹងនេះ បើនិយាយ ឱ្យខ្លីងាយស្តាប់បានទៅថារកឃើញនូវចំណេះវិជ្ជា ឬគ្រឿងប្រដាប់ថ្មីមួយ ដែលមិនទាន់មានអ្នកណារកឃើញនៅឡើយ ឧទាហរណ៍ដូចជាគ្រូពេទ្យធំៗបានរកឃើញ ថ្នាំសំរាប់ចាក់ការពារជម្ងឺអាសន្នរោគ អុតធំតូច ឬលោកបាស្ទ័រ បានរកឃើញថ្នាំសំរាប់ការពារឆ្កែឆ្កួតជាដើម ។ ការរកឃើញចំណេះអវិជ្ជា ជាវត្ថុថ្មីដឹង ប៉ុន្តែការត្រាស់ដឹងទាំងអស់នេះ ជាការត្រាស់ដឹងមួយដ៏តូច បំផុតប៉ុណ្ណោះ ឯព្រះពុទ្ធវិញទ្រង់ត្រាស់ដឹងនូវធម៌ និង ហេតុផលទាំងពួងដោយគ្មានសល់ចន្លោះអ្វីបន្តិចឡើយ ជាពិសេសគឺទ្រង់ត្រាស់ដឹងអរិយសច្ច គឺ ទុក្ខសច្ចៈ សមុទយសច្ចៈ និរោធសច្ចៈ និង មគ្គសច្ចៈ ។

ព្រះពុទ្ធត្រង់ត្រាស់ដឹង យល់ស្គាល់នូវហេតុផលទាំងពួងនេះមិនមែនដោយស្មានៗ នោះឡើយ គឺជាការត្រាស់ដឹង ដោយពិតៗ ច្បាស់ៗ ហើយគ្មានគ្រូបាចារ្យណា ដឹកនាំពន្យល់ព្រះអង្គឡើយ គឺទ្រង់រកឃើញ ដោយសេចក្តីព្យាយាម ផ្ទាល់ព្រះអង្គតែម្តង ។

អាស្រ័យដូច្នេះហើយ បានជាគេថ្វាយព្រះនាមព្រះអង្គថាព្រះសម្មាសម្ពុទ្ធោ ប្រែថា លោកអ្នកត្រាស់ដឹងនូវធមិទាំងពួងដោយប្រពៃដោយព្រះអង្គឯង ។

**ស**~ចុះព្រះនាមថា **វិជ្ជាចរណសម្បន្នោ** ប្រែថាដូម្តេច ?

**ឆ**~ព្រះនាមថា វិជ្ជាចរណសម្បន្នោ ប្រែថា ព្រះអង្គបរិបូរណ៌ ដោយវិជ្ជា ៣ និងវិជ្ជា ៨ និង ចរណៈ ១៥ ។

**ស**~វិជ្ជា ៣ របស់ព្រះពុទ្ធនោះគឺអ្វីខ្លះ ? ចូរអធិប្បាយពន្យល់!

**ឆ**~វិជ្ជា ៣ របស់ព្រះពុទ្ធនោះ មិនមែនជាវិជ្ជាធម្មតា ដែលមនុស្សធម្មតាធ្លាប់ចេះដឹងនោះឡើយ គឺវិជ្ជាជាន់ខ្ពស់ ឬ ជាអរិយវិជ្ជា ។

## វិជ្ជាទាំង ៣ នោះគឺៈ

**១~បុព្វេនិវាសានុស្សតិវិជ្ជា** ព្រះពុទ្ធទ្រង់មានចំណេះចេះដឹងខាងការរលឹកឃើញនូវអតីតជាតិកំណើតរបស់ព្រះអង្គ និងសត្វដទៃក្រៅពីព្រះអង្គ ដែលធ្លាប់កើតក្នុងកំណើត. ម្តាយ. ឪពុក.គោត្រ ត្រកូល.ភេទពណ៌សំបុរមានជីវភាពប្រព្រឹត្តទោសយ៉ាងណា១. បរិភោគចំណីអាហារនឹងធ្វើសកម្មភាពល្អអាក្រក់បែបណា១ ដោយគ្មានទើសទាក់សោះ ។ ការរលឹកឃើញនេះ គឺឃើញដឹងយល់តាំងពីជាតិទី ១ ទី ២ រហូតដល់អនេកជាតិ អសង្ខេយ្យជាតិ អសង្ខេយ្យកប្បទៀតផង ។

**២~ចុតូបបាតវិជ្ជា** ព្រះអង្គទ្រង់មានចំណេះ ខាងការជ្រាបនូវការស្លាប់ និង ការកើតរបស់មនុស្សសត្វ អ្នកនេះ នឹងស្លាប់ពេលនេះហើយកើតពេលនោះ ស្លាប់ព្រោះអ្វី មានកំណើតយ៉ាងណា សត្វខ្លះស្លាប់ទៅនឹងបានទៅកើតទីណា១ជាដើម ។

**៣~អាសវក្ខយវិជ្ជា** ព្រះអង្គទ្រង់មានចំណេះចេះដឹងខាងការដុះកើតនៃអាសវក្កិលេស និង មធ្យោបាយធ្វើអោយរលត់អាសវក្កិលេសពោលគឺទ្រង់ជ្រាបដោយពុទ្ធញ្ញាណថា នេះជាទុក្ខ នេះជាហេតុនាំអោយកើតទុក្ខ នេះនាំអោយរលត់ទុក្ខ នេះជាមធ្យោបាយ ឬ ជាផ្លូវនាំអោយរលត់ទុក្ខជាដើម ។

**ស**~ចុះវិជ្ជា ៨ នោះគឺអ្វីខ្លះ ? ចូររាប់ហើយធ្វើអធិប្បាយ !

**ឆ**~វិជ្ជា ៨ គឺរាប់វិជ្ជា ៣ ដែលបានអធិប្បាយរួចមកហើយផង និងបន្ថែមវិជ្ជា ៥ ទៀតផង :

**១~វិបស្សនាវិជ្ជា** ចំណេះវិជ្ជាខាងប្រាជ្ញា ដែលអាចពិចារណាឃើញជាក់ច្បាស់នូវនាម បានដល់អរូបក្ខន្ធ ៤ គឺ វេទនា សញ្ញា សង្ខារ និង វិញ្ញាណ ព្រមទាំងរូប២៨ ដែលតែងធ្លាក់ចុះក្នុងអំណាចនៃត្រៃលក្ខណ៍ គឺអនិច្ចំ មិនទៀង ទុក្ខំ ជាទុក្ខ អនត្តា មិនមែនជារបស់ខ្លួន វិបស្សនាវិជ្ជានេះ ទ្រង់បានរកឃើញមុនវិជ្ជាទាំង ៧ ទៅទៀត ។

**២-មនោមយិទ្ធិវិជ្ជា** ចំណេះចេះប្លែងឫទ្ធិ ដោយចេះធ្វើចិត្តដែលគ្មានរូបរាងឱ្យកើតមានជារូបរាងឡើង ។

**៣-ឥទ្ធិវិធិវិជ្ជា** ចំណេះចេះដឹងខាងធ្វើ ឬបង្កើតមនុស្ស សត្វ ឬអ្វី១ផ្សេងទៀត ដែលច្រើនអោយតិចចុះ ឬ តិចឱ្យច្រើនឡើងឬក៏ធ្វើរបស់នេះឱ្យទៅជារបស់នោះជាដើម ។

**៤-ទិព្វសោតវិជ្ជា** ចំណេះចេះដឹងខាងការ ចេះស្តាប់សំឡេងបានគ្រប់យ៉ាង ទោះសម្លេងមនុស្ស សត្វ ឬ ទេវតានៅក្នុងទីជិតទីឆ្ងាយយ៉ាងណាក៏ដោយ ក៏អាចស្តាប់បាន ស្តាប់ឮទាំងអស់ ។

**៥-ចេតោបរិញ្ញាវិជ្ជា** ចំណេះចេះដឹងក្នុងការកំណត់ ដឹងចិត្តអ្នកដទៃបានដោយច្បាស់លាស់ថា អ្នកនេះមានចិត្តល្អ អ្នកនោះមានចិត្តអាក្រក់ អ្នកនេះមានចិត្តស្មុគស្មាញសាំញ៉ាំ អ្នកនោះមានចិត្តស្លូតបូតរាបសារជាដើម ។

វិជ្ជាទាំងអស់នេះ ឈ្មោះថាវិជ្ជា ៨ ប្រការ ដែលព្រះពុទ្ធទ្រង់មាន ។

**ស-** ចុះ **ចរណៈ** ប្រែថា ដូចម្តេច មានប៉ុន្មានប្រការ ? ចូរអធិប្បាយ !

**ច-**ចរណៈ ប្រែថា ការប្រព្រឹត្តិ កិច្ចវត្តដែលព្រះអង្គតែងប្រព្រឹត្ត ចរណៈនេះមាន ១៥ គឺ :

**១-សីលសំវរ** ការប្រព្រឹត្តិសង្រួមក្នុងសីល បានដល់ការប្រព្រឹត្តិសង្រួមតាមបាដិមោក្ខសំវរសីល យ៉ាងត្រឹមត្រូវ ។

**២-ឥន្ទ្រិយសំវរ** ការប្រព្រឹត្តិសង្រួមក្នុងឥន្ទ្រិយសំវរៈសីល ពោលគឺការប្រព្រឹត្តិសង្រួម ភ្នែក ត្រចៀក ច្រមុះ អណ្តាត និង ចិត្ត មិនឱ្យបាបធម៌ចូលមកលុកលុយបាន ។

**៣-ភោជនមត្តញ្ញុតា** ព្រះអង្គទ្រង់ជាអ្នកដឹងប្រមាណក្នុងការសោយភោជនាហារ ។

**៤-ជាគរិយានុយោគ** ព្រះអង្គទ្រង់ជាអ្នកមានការភ្ញាក់ រលឹកជានិច្ច គឺទ្រង់ប្រាសចាកថីនមិទ្ធ ។

**៥-សទ្ធា** ទ្រង់មានព្រះទ័យជ្រះថ្លាបរិសុទ្ធ ប្រាសចាកអំពីបាបគ្រប់យ៉ាង ។

**៦-ហិរិ** ព្រះអង្គមានព្រះទ័យខ្មាស់អំពីបាបទុច្ចរិតគ្រប់យ៉ាង ។

**៧-ឱត្តប្ប** ព្រះអង្គមានព្រះទ័យខ្លាចក្រែងនឹង អំពើបាបគ្រប់យ៉ាង ។

**៨-ពាហុសច្ច** ព្រះអង្គទ្រង់ជាពហុស្សូត គឺទ្រង់ចេះដឹងច្រើន ( លើសជន ដទៃ១ទាំងអស់ ) ។

**៩-វិរិយ** ព្រះអង្គទ្រង់មានសេចក្តីព្យាយាមជាប់ជានិច្ចក្នុងកិច្ចការជាកុសលល្អ ។

**១០-សតិ** ព្រះអង្គទ្រង់មានស្មារតីតំកល់មាំ ក្នុងកុសលធម៌ជានិច្ច ។

**១១-បញ្ញា** ព្រះអង្គមានប្រាជ្ញាយល់ឃើញត្រូវ ។

**១២-បឋមជ្ឈាន** ទ្រង់មានបឋមឈាន លះនីវរណៈ ៥ គឺ

**ក-កាមច្ឆន្ទ** ចំណង់ក្នុងកាម

**ខ-ព្យាបាទ** គុំគួនអ្នកដទៃ

**គ-ថីនមិទ្ធ** ការងោកងុយ

**ឃ-ឧទ្ធច្ចកុក្កុច្ច** ចិត្តរាយមាយ

**ង-វិចិកិច្ឆា** សន្ទេះសង្ស័យប្រកបដោយអង្គ ៥ គឺ

**ក-វិត្តក** ការត្រិះរិះ

**ខ-វិចារ** ការពិចារណា

**គ-បីតិ** ការឆ្អែតចិត្ត ការឆ្អែតកាយ

**ឃ-សុខ** ភាពនៅជាសុខ

**ង-ឯកគ្គតា** ភាពមានអារម្មណ៍មូលតែមួយ ។

**១៣-ទុតិយជ្ឈាន** លះវិតក្កៈ និង វិចារៈ ប្រកបដោយបិតិ សុខ ឯកគ្គតា ។

**១៤-តតិយជ្ឈាន** លះបីតិ ប្រកបដោយសុខ និង ឯកគ្គតា ។

**១៥-ចតុត្ថជ្ឈាន** លះសុខ ប្រកបដោយ ឯកគ្គតា ។

ចរណៈទាំង ១៥ នេះ ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រកបព្រម យ៉ាងគ្រប់គ្រាន់ ។

**ស-សុគតោ** ប្រែថា ដូចម្តេច ?

**ឆ-**ប្រែថា ព្រះអង្គទ្រង់មានដំណើរល្អ យាងទៅកាន់អមតមហានិព្វាន។

**ស-**ចុះដំណើរល្អនោះ មានសេចក្តីអធិប្បាយដូចម្តេច ?

**ឆ-**ពាក្យថា សុគតោ ដែលប្រែថា ព្រះអង្គមានដំណើរល្អនោះបានសេចក្តីថាដំណើរជាមនុស្សភាព និងជាបុរសភាពរបស់ព្រះសមណគោតមក៏មានទម្រង់ល្អ គួរឱ្យមនុស្សម្នាមហាជន ចាប់ចិត្តណាស់ផងឯដំណើរល្អ ដែលជាន័យទូលំទូលាយវិញពោលគឺព្រះពុទ្ធដំណើរ ដែលគ្មានលាយឡំដោយកិលេសតណ្ហាគ្រប់យ៉ាង ដំណើរដែលទ្រង់យាងទៅហើយមិនត្រឡប់មកចាប់យកកំណើតបដិសន្ធិក្នុងភពណាទៀតឡើយ ទ្រង់យាងទៅកាន់ឋានដ៏ល្អតែ ១ គឺបរមសុខនោះឯង ។

**ស-**ចុះព្រះនាមថា **លោកវិទូ** មានន័យនិងសេចក្តីអធិប្បាយ ថាដូម្តេច ?

**ឆ-**ព្រះនាមថា លោកវិទូ មានន័យថា ព្រះពុទ្ធជាបុគ្គលអ្នកជ្រាបនៅបញ្ហារបស់លោក។ ពាក្យថាព្រះអង្គជ្រាបនូវបញ្ហាលោកនេះ គឺជ្រាបនូវៈ

**ក-មនុស្សលោក** ព្រះអង្គជ្រាបនូវបញ្ហាផ្សេងៗក្នុងមនុស្សលោកនេះទាំងអស់ ។ សង្គមមនុស្សលោក ចលនា ចិត្តគំនិតសកម្មភាព

ជីវភាព ប្រទេសនិងលក្ខណៈនៃសង្គមមនុស្ស ព្រមទាំងការប្រព្រឹត្តិល្អ អាក្រក់ផ្សេងៗរបស់មនុស្ស និង សង្គមមនុស្សលោកនេះឯង ។

ម្យ៉ាងទៀត ព្រះអង្គទ្រង់ជ្រាបនូវបញ្ហាចំរើន និង វិនាសបញ្ហាកើត នៃមនុស្សលោកនេះទៀតផង ។

**ខ~សត្តលោក** លោកជាលំនៅរបស់សត្វ ទាំងមនុស្សទេវតា និង សត្វតិរច្ឆាន ។ ក្នុងទីនេះសំដៅយកសត្វតិរច្ឆាន ដែលរស់នៅក្នុងមនុស្ស លោកនេះឯង ។ ព្រះពុទ្ធជាម្ចាស់ទ្រង់ជ្រាបនូវ ចិត្ត អធ្យាស្រ័យ ចំណង់ របស់ពួកសត្វគ្រប់ប្រភេទដោយច្បាស់លាស់ ហើយថែមទាំងជ្រាបនូវ អំពើល្អ អាក្រក់ទាំងអតីត បច្ចុប្បន្ន និងអនាគតរបស់ពួកសត្វទាំងនោះ ទៀតផង ។

**គ~ទេវលោក** ព្រះអង្គទ្រង់ជ្រាបនូវបញ្ហារបស់ទេវលោកជាលំនៅ ឬជាកំណើតរបស់ទេវតាទាំង ៦ ជាន់ ដោយជាក់ច្បាស់ បាន សេចក្តីថា ព្រះអង្គទ្រង់ជ្រាបនូវបញ្ហានៃពួកទេវៈ ដែលបានកើតនៅក្នុងទេវលោក នោះ ដោយច្បាស់ប្រាកដ ។ មិនតែប៉ុណ្ណោះសោត ទ្រង់ជ្រាប ទាំងព្រហ្ម លោកគ្រប់ទាំងអស់ថែមទៀត ។

អាស្រ័យហេតុនេះហើយ ទើបព្រះអង្គមាននាមថា លោកវិទូ ពោលគឺព្រះអង្គជ្រាបនូវលោកដែលជារូប និង អរូប (នាម)ដោយគ្មាន សល់ចន្លោះត្រង់ណាឡើយ ។ ដទៃពីនេះ ព្រះអង្គទ្រង់ជ្រាបនូវបញ្ហា គ្រប់យ៉ាង របស់លោក នៅក្នុងលោកធាតុឯទៀតៗ ក្រៅពីនេះ ដោយ សព្វគ្រប់ទៀតផង ។

**ស~**ព្រះនាមថា **អនុត្តរោ** តើប្រែថា ដូម្តេច ? ចូរអធិប្បាយ អោយល្មមស្តាប់បាន !

**ច~**អនុត្តរោ ប្រែថា ព្រះអង្គជាបុគ្គលប្រសើរដោយសិលាទិគុណរក បុគ្គលណាមួយស្មើគ្មាន បានសេចក្តីដោយខ្លីថា គុណធម៌ទាំងឡាយ មាន សីលធម៌ជាដើម ជាកុសលធម៌ដែលមនុស្សទេវតា ទាំងអស់ តែងមាន តែងធ្វើ តែងប្រព្រឹត្ត ក៏នៅតែមិនប្រសើរស្មើព្រះអង្គឡើយ គឺព្រះពុទ្ធ ទ្រង់មានគុណទាំងនោះប្រសើរលើសពីមនុស្សទេវតា ទាំងអស់ទៅទៀត ។

លក្ខណៈដែលប្រសើរលើស ខាងផ្នែកខាងគុណសម្បទបែបនេះ ហើយទើបព្រះអង្គមានព្រះនាមថា អនុត្តរោ ។

**ស~**ចុះព្រះនាមថា **បុរិសទម្មសារថិ**មានសេចក្តីអធិប្បាយដូម្តេច ?

**ច~**ព្រះនាមថា បុរិសទម្មសារថិ ប្រែថាព្រះអង្គជាអ្នកដឹកនាំទូន្មាន នូវបុគ្គលដែលមានឧបនិស្ស័យ គួរនឹងទូន្មានបានមានសេចក្តីអធិប្បាយថា ដើម្បី នឹងប្រោសសត្វលោក ព្រះពុទ្ធជាម្ចាស់ពុំមែនចេះតែយាងទៅប្រោស ដឹកនាំ ពន្យល់គ្រប់តែមនុស្សសត្វនោះទេ គឺព្រះអង្គតែងប្រមើល

ឧបនិស្ស័យព្រេងសំណាងរបស់សត្វលោកនោះៗ ជាមុនសិន ទើបព្រះអង្គយាងទៅដឹកនាំពន្យល់ខាងក្រោយ ព្រោះព្រះអង្គទ្រង់ទុកលោកសន្និវាសនេះជាស្រះ ១ យ៉ាងធំ ដែលពោរពេញទៅដោយដើមឈូកយ៉ាងច្រើន។ សត្វលោកដែលនៅក្នុងលោកសន្និវាស ប្រៀបបាននឹងផ្កាឈូកច្រើនប្រភេទគឺ :

**ក-** សត្វខ្លះមាននិស្ស័យចាស់ក្លា កាលស្តាប់បានព្រះឱវាទរបស់ព្រះអង្គតែមួយដង ក៏នឹងបានត្រាស់ដឹង តាមសេចក្តីដែលបានស្តាប់យល់ចូលចិត្តដោយងាយហើយអាចប្រតិបត្តិតាមឱវាទនោះ សមតាមបំណងរបស់ព្រះអង្គ ដូចជាពួកបញ្ចវគ្គិយភិក្ខុ ពួកយសកុលបុត្រ ដែលព្រះអង្គបានប្រោសជាដំបូងនៅពេលដែលទ្រង់ត្រាស់ ហើយថ្មីៗជាដើមពួកសត្វនេះប្រៀបបាននឹងផ្កាឈូក ដែលដុះផុតពីទឹក ហើយមានទំហំធំ បរិបូណ៌រង់ចាំតែមានពន្លឺថ្ងៃ នឹងអាលរីកឡើងភ្លាម ។

**ខ-**សត្វខ្លះមាននិស្ស័យចាស់ល្មម កាលបានស្តាប់ធម៌ម្តងពីរដងបីដងហើយ កាលត្រូវពន្លឺថ្ងៃ ៣-៤ ដងក៏អាចរីកស្គុះស្គាយបាន ។

**គ-**សត្វខ្លះមាននិស្ស័យនៅខ្ចីនៅឡើយ ទោះស្តាប់ធម៌ ៣-៤ ដងក៏មិនទាន់បានចូលចិត្ត ឬ ត្រាស់ដឹងធម៌តាមព្រះអង្គបានឡើយ ។ សត្វពួកនេះប្រៀបបាននឹង ផ្កាឈូកដែលនៅក្នុងទឹក ឬ ទើបដែលនឹងប៉ិចចេញពីភក់ មិនទាន់ច្បាស់ថា នឹងអាចលូតលាស់ផុតពីទឹកបានឬយ៉ាងណាឡើយ ជួនកាលបានជាចំណីត្រី អណ្តើកក៏សឹងមាន ។

ព្រះពុទ្ធទ្រង់ប្រោសមនុស្សសត្វទៅតាមលំដាប់នៃនិស្ស័យ ដែលចាស់ក្លា ឬនៅខ្ចីបែបនេះឯង ពុំបានប្រោសទៅតាមលំដាប់ យសសក្តិ ទ្រព្យសម្បត្តិ ឬ ពូជត្រកូលឡើយ ឧទាហរណ៍ ដូចព្រះអង្គប្រោសទុគ្គតបុរសម្នាក់ ទោះបុរសនោះក្រីក្រយ៉ាងណាក៏ដោយ ក៏ព្រះអង្គយាងទៅប្រោសរហូតទល់បណ្តាលអោយឱ្យភ្លៀងរត្ន័ ៧ ប្រការ ធ្លាក់ចុះមកក្នុងភូមិបុរសនោះតាមប្រាថ្នា ។ មានព្រាហ្មណ៍ម្នាក់ទៀតក៏មាននិស្ស័យលក្ខណៈគួរព្រះអង្គប្រោសដែរព្រះអង្គក៏យាងទៅប្រោស ដោយការនិមន្តទៅបិណ្ឌបាត្រនៅមុខផ្ទះព្រាហ្មណ៍នោះអស់ពេល ១៥ ដង ព្រាហ្មណ៍គ្រាន់តែទូលព្រះអង្គថា គ្មានចង្ហាន់ទេលុះលើកទី ១៦ ព្រាហ្មណ៍នេះ ក៏និយាយថា "ព្រះសមណគោតមនេះ យាងមកញឹកៗញយៗ ណាស់ គួរអញថ្វាយភត្តម្តងចុះ " ។ ព្រះពុទ្ធជាម្ចាស់ ដោយជ្រាបថា ព្រាហ្មណ៍នេះមាននិស្ស័យចាស់ក្លា តែជាអ្នកប្រកាន់មាំមិនដែលនិយាយអ្វីនឹងព្រះអង្គសោះហើយទើបតែថ្ងៃនេះបាននិយាយថា ព្រះសមណគោតមយាងមក ញឹកញយៗទ្រង់ក៏ប្រារព្ធនូវពាក្យជាគាថា ញឹកៗ ញយៗ នេះមកសម្តែងជាគាថា ប្រកបដោយឧទាហរណ៍ ១៦ បែប មានពាក្យថា :

-មកញឹក១ ទៅវិញក៏ញឹក១

-ធ្វើស្រែញឹក១ បានផលក៏ញឹក១

-បរិភោគញឹក១ ឆ្អែតក៏ញឹក១

-កើតញឹក១ ស្លាប់ក៏ញឹក១

-ធ្វើបុណ្យញឹក១ បានបុណ្យក៏ញឹក១ ប៉ុណ្ណេះជាដើមព្រាហ្មណ៍ក៏បានស្តាប់ហើយកើតចិត្តជ្រះថ្លា បាននាំគ្នាចូលកាន់ព្រះពុទ្ធសាសនាចាប់ពីពេលនោះមក ។ ត្រង់នេះហើយដែលជាគ្រឿងបញ្ជាក់ថាព្រះអង្គជាអ្នកទូន្មាននូវបុគ្គលដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន ។

**ស.**សត្វលោកទាំងអស់ សុទ្ធតែមាននិស្ស័យត្រូវនឹងព្រះពុទ្ធជាម្ចាស់ប្រោសដឹងនាំបានតែម្យ៉ាង ឬមានជនដទៃប្រោសដឹកនាំបានដែរបើបានតើជនពួកណា ? មានប៉ុន្មានយ៉ាង ? ចូរអធិប្បាយ !

**ច.**សត្វទាំងអស់ មិនមែនសុទ្ធតែព្រះពុទ្ធដឹកនាំបានទេ មានជនដទៃដឹកនាំបានក៏មាន បើនិយាយអោយខ្លីមក សត្វទាំងអស់ចែកចេញជា ៣ ពួក គឺ :

**១.ពុទ្ធវេនេយ្យ** សត្វខ្លះមាននិស្ស័យលក្ខណៈ ជាមួយព្រះពុទ្ធតែម្យ៉ាងទាល់តែព្រះពុទ្ធទ្រង់យាងទៅប្រោសដោយ ព្រះអង្គឯង ទើបបាន ដូចជាបញ្ចវគ្គិយភិក្ខុ ភទ្ទវគ្គិយកុមារ ព្រះបាទពិម្ពិសារ ព្រះញាតិវង្សនៅក្រុងកបិលព័ស្តុជាដើម ។

**២.សាវកវេនេយ្យ** សត្វខ្លះត្រូវបានពួកសាវ័កដឹកនាំទើបចុះចូលក្នុងធម្មវិន័យ ដូចជាអគ្គិហុត្តព្រាហ្មណ៍. នាគរាជឈ្មោះនន្ទោនន្ទដែលត្រូវបានព្រះមោគ្គល្លានប្រោសជាដើម ។

**៣.ធាតុវេនេយ្យ** ពួកសត្វខ្លះ កាលព្រះពុទ្ធទ្រង់បរិនិព្វានទៅ គ្រាន់តែបានឃើញព្រះធាតុឬព្រះស្តូប ព្រះចេតិយ ដំកល់ព្រះសារីរិកធាតុ ក៏កើតចិត្តសង្វេគកើតចិត្តជ្រះថ្លា ក្នុងព្រះពុទ្ធសាសនាឡើង ។

ដូច្នេះ សត្វខ្លះ ព្រះពុទ្ធទ្រង់យាងទៅប្រោសដោយព្រះអង្គឯង សត្វខ្លះទ្រង់សាវ័កធំ១ ដូចជាព្រះសារីបុត្ត មោគ្គលាន ព្រះអានន្ទ កស្សបជាដើម ទៅប្រោសដើម្បីជៀសវាងការលំបាកផ្សេង១ ។

**ស.**ចុះព្រះនាមថា **សត្ថាទេវមនុស្សានំ** មានន័យដូចម្តេច ? ចូរអធិប្បាយពន្យល់ !

**ច.**ព្រះនាមថា សត្ថាទេវមនុស្សានំ មានន័យថា ព្រះពុទ្ធទ្រង់ជាគ្រូយ៉ាងចម្បងលើសគ្រូឯទៀតឯទៀត១ ឬមានន័យ មួយទៀតថាព្រះអង្គជាសាស្តាចារ្យរបស់ទេពតា និងមនុស្សទាំងឡាយ ការថ្វាយព្រះនាមថាព្រះអង្គជាគ្រូ ជាសាស្តាចារ្យរបស់មនុស្សនិងទេពតានេះព្រោះថានៅក្នុងលោកនេះជាពិសេស គឺប្រទេសឥណ្ឌាក្នុងសម័យមុននឹងក្នុងសម័យពុទ្ធ-

កាល មានពួកមនុស្សបានទៅតាំងធមិ តាំងខ្លួនជាមេលទ្ធិសាសនាជាច្រើន តួយ៉ាងដូចក្នុងផែនដីមគធៈ មាន ឧទកតាបស អាឡារតាបស នទីកស្សប គយាកស្សប សញ្ជ័យ ជាដើម សុទ្ធតែជាសាស្តាចារ្យយ៉ាងសំខាន់ មានមនុស្សរាប់លាននាក់គោរពរាប់អាន នឹងប្រតិបត្តិតាមពាក្យប្រៀនប្រដៅរបស់តាបសជដិលទាំងនោះគ្រប់គ្នា ។

លុះព្រះពុទ្ធជាម្ចាស់ទ្រង់បានត្រាស់ឡើង ព្រះអង្គបានយកធមិមាន អរិយសច្ចធមិជាដើម ទៅសំដែងយ៉ាងល្អិតល្អន់ឱ្យមនុស្សជាគ្រូ និងសិស្សទាំងនោះ ស្តាប់ ពួកគ្រូ និងសិស្សសាវ័កទាំងនោះ ក៏បានស្តាប់បានយល់សេចក្តីហើយពិចារណាឃើញថា ពុទ្ធឱវាទពិតជាមានជំរៅ មានតម្លៃល្អិតល្អន់ ប្រតិបត្តិដើម្បីបានសំរេចមគ្គផល ស្វែងរកផ្លូវបរមសុខឃើញយ៉ាងពិតប្រាកដ ។ ម្លោះហើយពួកគ្រូសំខាន់ៗ និងសាវ័កសិស្សគណក្នុងលិទ្ធិផ្សេងៗ ទាំងនោះ ក៏ចូលមកកាន់ ព្រះពុទ្ធសាសនា តាំងនៅក្នុងការប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់តទៅ ។

មិនតែប៉ុណ្ណោះសូម្បីពួកទេវតា ព្រះឥន្ទ ព្រះព្រហ្ម ដែលមានបុណ្យបារមីឫទ្ធិអំណាចច្រើន ក៏បានស្តាប់ព្រះឱវាទពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ដែរ ។ គឺដោយហេតុនេះហើយបានជាពួកទេវតានិងមនុស្សបានថ្វាយព្រះនាមដល់ព្រះអង្គថា ទ្រង់ជាសាស្តាចារ្យរបស់ទេវតានិងមនុស្សទាំងឡាយ គឺព្រះអង្គជាបរមសាស្តាចារ្យ គ្មានសាស្តាចារ្យណាប្រៀបផ្ទឹមស្មើ នឹងព្រះអង្គឡើយ ។

**ស**~ចូរចង្អុលបង្ហាញថា ព្រះពុទ្ធទ្រង់បានប្រៀនប្រដៅយ៉ាងណាខ្លះចំពោះមនុស្ស និង ទេវតាទាំងឡាយ ?

**ច**~ការប្រៀបប្រដៅរបស់ព្រះពុទ្ធទៅលើមនុស្សនិងទេវតាទាំងឡាយនោះមានច្រើនប្រការណាស់ ប៉ុន្តែបើរួមឱ្យខ្លីចុះមក ព្រះអង្គទ្រង់តែងប្រដៅប្រយោជន៍ ៣ យ៉ាងជាគោលសំខាន់ជាងគេ ។

**ស**~ប្រយោជន៍ ៣ យ៉ាងនោះ គឺអ្វីខ្លះ ? ចូររាប់ហើយអធិប្បាយពន្យល់ !

**១~ទិដ្ឋធម្មិកត្ថៈ** ប្រយោជន៍ក្នុងបច្ចុប្បន្ន ដែលជាគ្រឿងញ៉ាំងសេចក្តីប្រាថ្នាគ្រប់យ៉ាង ក្នុងពេលដែលកំពុងរស់រានមានជីវិតនេះឱ្យសំរេច ។ ប្រយោជន៍ក្នុងបច្ចុប្បន្ននេះ មានចែកចេញជា ៤ យ៉ាងទៅទៀត គឺ :

**ក~ឧដ្ឋានសម្បទា** ការដល់ព្រមដោយការប្រឹងប្រែងខ្នះខ្នែងប្រកបការងារ សំរាប់ចិញ្ចឹមជីវិតក្នុងបច្ចុប្បន្ន ហើយការងារនោះត្រូវប្រកបដោយ សុចរិតយុត្តិធមិគ្រប់បែបទៀតផង ។

**ខ~អារក្ខសម្បទា** ការដល់ព្រមដោយការថែទាំរក្សានូវទ្រព្យដែល

ខ្លួនបានរកបានហើយ មិនចាយវាយខ្ជះខ្ជាយផ្តេសផ្តាសតាមចំណង់ចិត្ត រវើរវាយណាមួយ ។

**គ-កល្យាណមិត្តតា** សេពគប់នឹងមិត្តភក្តិល្អជៀសវាងបាបមិត្ត។

**ឃ-សមជីវិតា** ចិញ្ចឹមជីវិតដោយទ្រព្យ ដែលខ្លួនបានរកបាន ហើយនោះឱ្យបានត្រឹមត្រូវ ពោលគឺត្រូវចេះលៃលកចែកទ្រព្យ ដែលខ្លួនបានរកបានមកហើយនោះឱ្យបានត្រឹមត្រូវ ចេះលៃលកចែកទ្រព្យដែលខ្លួនបានរកបានហើយ ជា ៥ ចំណែក :

មួយចំណែក ត្រូវរកប់ទុកជាកំណប់ព្រែងគឺការធ្វើបុណ្យទានជាមួយស្មូមយាចក សមណព្រាហ្មណ៍ ។

មួយចំណែកត្រូវសងបំណុលចាស់ គឺសងមាតាបិតាដែលជាអ្នកមានគុណូបការៈលើខ្លួន ។

មួយចំណែកត្រូវបុលបំណុលថ្មី គឺចិញ្ចឹមកូនក្រុមគ្រួសារ ។

មួយចំណែក ត្រូវបោះទៅក្នុងជ្រោះជ្រៅ គឺចិញ្ចឹមខ្លួន នឹងធ្វើដើមទុនប្រកបរបរចិញ្ចឹមជីវិត ។

នឹងមួយចំណែកទៀត ត្រូវទុកជារបស់សំអប់ គឺទុកប្រចាំការក្នុងគ្រួសារ ក្រែងមានជំងឺអាសន្ន គ្រោះថ្នាក់ឬពេលឈឺថ្កាត់គ្មានធ្វើការអ្វីកើត។

**២-សម្បរាយិកត្ថ** ប្រយោជន៍ក្នុងលោកខាងមុខ ដែលជាគ្រឿងសាងផ្លូវល្អ ដើរទៅកាន់ទីដៅដ៏សំខាន់ គឺបរមសុខក្នុងបរលោក ប្រយោជន៍ក្នុងលោកខាងមុខនេះ ចែកចេញជា ៤ យ៉ាងដែរ គឺ :

**ក-សទ្ធាសម្បទា** ការដល់ព្រមដោយជំនឿ បានសេចក្តីថាបុគ្គលត្រូវមានជំនឿត្រូវ គឺការត្រិះរិះពិចារណាយល់ផ្លូវត្រូវ ក្នុងគុណព្រះរតនត្រ័យ និងជំនឿកម្មផល ដែលជាអំពើព្រមទាំងចំហាយរបស់អំពើ ដែលបុគ្គលធ្វើគ្រប់បែបយ៉ាង ។

**ខ-សីលសម្បទា** ការដល់ព្រមដោយសីល គឺជាអ្នករក្សា សមាទានសីល៥ សីល៨ ជាប់ក្នុងខ្លួនជានិច្ច ។

**គ-ចាគសម្បទា** ការដល់ព្រមដោយការចំណាយទ្រព្យដែលខ្លួនរកបានឱ្យជាទាន ដល់ស្មូមយាចកសមណព្រាហ្មណ៍ ។

**ឃ-បញ្ញាសម្បទា** ការដល់ព្រមដោយប្រាជ្ញា ពិចារណារកត្រូវខុស ល្អអាក្រក់ ។

សម្បរាយិកត្ថ គឺប្រយោជន៍ សម្រាប់បរលោកទាំង ៤ ប្រការនេះ អាចនាំអ្នកដែលប្រតិបត្តិ ឱ្យបានសំរេចបរមសុខយ៉ាងពិតប្រាកដ ។

**៣-បរមត្ថ** ប្រយោជន៍ដ៏ឧត្តម គឺសច្ចធម៌ទាំង ៤ ប្រការ :

**ក-ទុក្ខសច្ច** សេចក្តីពិតក្នុងកងទុក្ខទាំង ១២ មានជាតិទុក្ខជាដើម។

**ខ-សមុទយសច្ច** សេចក្តីពិតក្នុងហេតុដែលនាំឱ្យកើតទុក្ខដែលមាន

កងកិលេសជាមេបណ្តាលឡើង ។

**គ-និរោធសច្ច** សេចក្តីពិតក្នុងផ្លូវសំរាប់រំលត់ទុក្ខ គឺព្រះនិព្វាន ជាបរមសុខ ។

**ឃ-មគ្គសច្ច** សេចក្តីពិតក្នុងផ្លូវសំរាប់រំលត់ទុក្ខ គឺផ្លូវមានអង្គ ៨ ប្រការ (អដ្ឋង្គិកមគ្គ) ។

បរមត្ថនេះ ជាប្រយោជន៏ មួយមានទីបំផុត មានចុងចប់ ហើយជា ប្រយោជន៏ ដែលមានជំរៅខ្លឹមសារយ៉ាងល្អក្រៃលែងដែលមានតែព្រះពុទ្ធ ជាបរមសាស្តាមួយព្រះអង្គប៉ុណ្ណោះ ដែលទ្រង់យល់ជ្រាប់ច្បាស់ហើយ បានសំដែងពន្យល់ ដោយមានហេតុជាគោលអាងថែមទៀត ។

**ស-**ពាក្យថា ព្រះអង្គជាសាស្តាចារ្យរបស់ទេវតានិងមនុស្សទាំងឡាយ នេះហាក់ដូចជាគ្មានចង្អុលបង្ហាញថា ព្រះអង្គអាចប្រោសដឹកនាំពួកសត្វ តិរច្ឆានបានសោះ បើដូច្នោះ តើព្រះអង្គជាសាស្តាចារ្យលើពួកសត្វ តិរច្ឆានបានដែរ ឬមិនបាន ?

**ឆ-**ព្រះពុទ្ធអង្គ ពុំគ្រាន់តែជាសាស្តាចារ្យរបស់មនុស្ស និង ទេវតា ប៉ុណ្ណោះទេ គឺថែមទាំងជាសាស្តាចារ្យលើពពួកសត្វតិរច្ឆានទៀតផងបាន សេចក្តីថា ព្រះអង្គទ្រង់ទេសនាប្រៀនប្រដៅមនុស្សទេវតានិងសត្វតិរច្ឆាន ទោះមានជាតិសាសន៏កំណើតផ្សេងៗគ្នា ស្ថិតនៅក្នុងក្រុមទីទៃពីគ្នា យ៉ាងណា ក៏អាចស្តាប់បានដូចគ្នា ។ ការស្តាប់បាននូវភាសាតែមួយនៃ មនុស្សទេពតា ឬសត្វតិរច្ឆាន ដែលមានជាតិសាសន៏ កំណើតផ្សេងគ្នានេះ គឺដោយបារមី ១០ ដែលព្រះអង្គបានបំពេញចំនួន ១ អសង្ខេយ្យ កម្រៃ ១សែនកប្បនេះឯង ។ ពួកសត្វកាលបានស្តាប់ព្រះបរមពុទ្ធោវាទ ហើយ ក៏មានឧបនិស្ស័យចាស់ក្លាឡើងហើយកាលសត្វនោះរំលាយខន្ធទៅ ក៏ទៅ បានក្នុងកំណើតខ្ពស់ជាមនុស្ស ឬ ទេវតា ហើយអាចបន្តនិស្ស័យឱ្យខ្ពស់ ៗ តទៅក្នុងជាតិបន្តបន្ទាប់គ្នាជាខាងក្រោយ ដូចជាខ្ពស់នាគរាជឈ្មោះ ឧរកបត្ត ឬ មណ្ឌុកទេវតាបុត្រឬក៏ដំរីបាលិលេយ្យជាដើម ។ គឺដោយហេតុ នេះហើយទើបលោកពោលថា ព្រះអង្គជាសាស្តាចារ្យលើពពួកសត្វ តិរច្ឆានថែមទៀត ។ បើនិយាយដោយខ្លឹមកថា ព្រះពុទ្ធជាសាស្តាចារ្យ លើពពួកសត្វលោកទាំងអស់ក្នុងត្រៃភពនេះឯង ដូច្នេះព្រះនាមថា *សត្ថាទេវមនុស្សានំ* មានន័យទូទៅថា ព្រះអង្គជាសាស្តាចារ្យ លើអ្វីៗ ទាំងអស់ក្នុងត្រៃភពនេះឯង ។

**ស-**ចុះព្រះនាមថា **ពុទ្ធោ** តើមានសេចក្តីអធិប្បាយបកស្រាយ យ៉ាងណាទៅទៀត ។

**ឆ-**ព្រះនាមថា ពុទ្ធោ នេះ ត្រូវអ្នកផងទូទៅ បានស្គាល់ច្បាស់លាស់ ជាងគេហើយព្រះនាមនេះ បើបកស្រាយឱ្យខ្លីងាយស្តាប់មកថា ព្រះអង្គ

ជាអ្នកត្រាស់ដឹងនូវអរិយសច្ចធម៌ ៤ ប្រការ ដោយព្រះអង្គឯងហើយ ញុំាងឱ្យអ្នកដទៃត្រាស់ដឹងផង ។

**ស~**ពាក្យថា ព្រះអង្គទ្រង់ត្រាស់ដឹងនូវសច្ចធម៌ ៤ ប្រការគឺ ទុក្ខសច្ចៈ សមុទយសច្ចៈ និរោធច្ចៈ និងមគ្គសច្ចៈ នោះបានសេចក្ដីថា ព្រះអង្គទ្រង់សាងបារមីទាំង ១០ ក្នុងវេលា ១ អសង្ខេយ្យកម្រៃ មួយសែនកប្ប ហើយនៅទីបំផុតទ្រង់ចេញសាងព្រះផ្នួសធ្វើទុក្កកិរិយា បំពេញតបធម៌ ស្វែងរកមោក្ខធម៌អស់ពេល ៦ ឆ្នាំទៀត ទ្រង់ក៏បានសំរេចការត្រាស់ដឹង បានចេះដោយព្រះអង្គឯង គ្មានគ្រូអាចារ្យណាប្រដៅព្រះអង្គសោះឡើយ ។ ត្រាស់ដឹងនេះ គឺត្រាស់ដឹងនូវព្រះធម៌ទាំង ៨៤000 ព្រះធម្មក្ខន្ធ ដែលមានសច្ចធម៌ទាំង ៤ ប្រការនេះជាគោលធំ មានជម្រៅយ៉ាងជ្រៅឆ្ងាយ ហើយល្អិតល្អន់ទៀតផង យ៉ាងនេះឈ្មោះថា ព្រះអង្គទ្រង់ត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គឯង ។

ឯពាក្យថា ព្រះអង្គញុំាងអ្នកដទៃឱ្យត្រាស់ដឹងនោះ បានសេចក្ដីថាកាលព្រះអង្គទ្រង់ជ្រាបច្បាស់នូវធម៌នានា ជាពិសេស គឺអរិយសច្ចទាំង ៤យ៉ាងនេះហើយ ព្រះទ្រង់យកចំណេះចេះដឹងថ្មីនោះ ទៅប្រកាសផ្សាយពន្យល់បង្ហាញច្បាស់លាស់ ប្រាប់ដល់ពពួកសត្វលោកឱ្យយល់ជាក់លាក់ ហើយបានត្រាស់ដឹងតាមពាក្យប្រៀនប្រដៅនោះៗទៀត ។

ដោយហេតុនេះហើយទើបព្រះអង្គមានព្រះនាមថា ទ្រង់ញុំាងអ្នកដទៃឱ្យត្រាស់ដឹងផង ។

**ស~**ព្រះនាមថា **ពុទ្ធោ** តើមានន័យបែបណាក្រៅពីនោះទៀតទេ ?

**ច~** ព្រះនាមថា ពុទ្ធោ មានន័យខ្ពង់ខ្ពស់ត្រង់ថា ព្រះអង្គទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ហើយទ្រង់ញុំាងអ្នកដទៃឱ្យត្រាស់ដឹងផងនេះឯង ប៉ុន្តែព្រះនាមនេះក៏មានន័យផ្សេងៗ ទៀតជាច្រើនដែរ ដែលជាអាទិ៍ដូចជាព្រះនាមថា : ព្រះអង្គជាបុគ្គលកំពូលមនុស្សដែលត្រាស់ដឹងនូវកំលាំង ១០ ព្រមទាំងញាណដែលចាក់ធ្លុះសព្វហេតុការណ៍គ្មានបុគ្គលណាស្មើ ( ឯកោ អនុត្តរសម្មាសម្ពោធិ ) ។

ព្រះអង្គទ្រង់ ជាបុគ្គលឆ្ងាយចាកកិលេសជាគ្រឿងសៅហ្មង ១០ យ៉ាងគឺ លោភៈ ទោសៈ មោហៈ មានៈ ទិដ្ឋិៈ វិចិកិច្ឆៈ ថីនមិទ្ធៈ អហិរិកៈ និង អនោតប្បៈ ។

ព្រះអង្គទ្រង់ជាបុគ្គលគ្មានអាសវៈ ៣ ប្រការគឺ កាមាសវៈ ភវាសវៈ អវិជ្ជាសវៈ ( ខីណាសវសង្ខាទេន ពុទ្ធោ ) ។

ព្រះអង្គទ្រង់ជាបុគ្គលយាងទៅតាមផ្លូវតែ ១ គឺ អដ្ឋង្គិកមគ្គដើម្បីទៅកាន់ អមតមហានិព្វាន ( ឯយាយ មគ្គំ គតោ ) ។

ព្រះនាមទាំងនេះ គឺជាគុណសម្ប័ទដែលលេចចេញបង្ហាញឱ្យពួក

សាវ័កទាំងឡាយបានឃើញច្បាស់ ។

**ស.** ព្រះនាមជាទីបញ្ចប់ថា **ភគវា** តើមានន័យសេចក្តីអធិប្បាយយ៉ាងដូម្តេច ?

**ច.** ព្រះនាមថា ភគវា មានសេចក្តីថាព្រះអង្គលែងយាងទៅកាន់ត្រៃភព ពោលគឺព្រះអង្គលែងត្រលប់កើតទៀតហើយ ។ សេចក្តីអធិប្បាយថា ព្រះពុទ្ធជាម្ចាស់ ដែលពីមុននោះទ្រង់នូវជាព្រះពោធិសត្វនៅឡើយ ព្រះអង្គក៏តែងទ្រង់យោនយកកំណើតកើតជាមនុស្ស ជាសត្វដែលមានជីវិត ថ្លៃថ្លា ឬថោកទាបជាធម្មតា ប៉ុន្តែក្នុងកំណើតទាំងអស់នោះព្រះអង្គតែងសាងបារមី ១០ ប្រាថ្នាឱ្យអស់អាសវក្កិលេសហើយឱ្យបានត្រាស់ជាព្រះពុទ្ធជាដរាប ក្នុងព្រះជាតិជាទីបំផុតនេះព្រះអង្គទ្រង់បានសំរេចការត្រាស់ដឹង ហើយទ្រង់អស់អាសវក្កិលេសដូចព្រះទ័យប្រាថ្នាមែនព្រះទ្រង់យាងចូលបរិនិព្វាន ហៅថាអមតស្ថានភាពពោលគឺ ជាកន្លែងមិនស្លាប់នេះឯង ។ ដូច្នេះហើយបានជាព្រះអង្គព្រះនាមថា ភគវា ។

**ស.** ត្រៃភព គឺអ្វី ? ចូររាប់ហើយអធិប្បាយ !

**ច.** ត្រៃភព គឺលំនៅរបស់សត្វលោកទាំង ៣ កន្លែង គឺសត្វភពតិរច្ឆានភពមនុស្ស និង ភពទេវតា ។ ភពសត្វតិរច្ឆាន និងមនុស្សនៅជាមួយគ្នាហើយជាភពមានសុខ និងទុក្ខវេទនានឹងជាកន្លែងសាងបុណ្យបារមីផ្សេងៗ ភពទេវតា ជាកន្លែងសោយសេចក្តីសុខឬជាកន្លែងសំរាកកាយមួយពេលៗនៃបុគ្គលនៃអ្នកសាងសេចក្តីសុខបានច្រើន ។ ម្យ៉ាងទៀតភពមាន៣យ៉ាងផ្សេងទៀត គឺកាមភពលំនៅរបស់សត្វតិរច្ឆាន មនុស្សទាំងទេវតា ៦ជាន់ រូបភព លំនៅនៃពួកព្រហ្មមានរូប ២០ ជាន់ និងអរូបភពលំនៅ នៃព្រហ្មឥតរូប ៤ទៀត ។ ភពទាំង ៣ នេះ ព្រះពុទ្ធទ្រង់លែងយោន យកកំណើតឬនៅស្នាក់អាស្រ័យទៀតហើយ ។

**ស.** ពាក្យថា ភគវា មានន័យយ៉ាងណាទៀតដែរ ?

**ច.** មានន័យ ថាព្រះមានព្រះភាគក៏បាន ថាព្រះមានជោគក៏បាន ថាព្រះជាអ្នកបំបាក់បង់កិលេសក៏បាន ថាជាអ្នកចែកក៏បាន ។

**ស.** ក្នុងន័យនីមួយៗ នេះ តើមានសេចក្តីអធិប្បាយដូម្តេច ?

**ច.** ពាក្យថា ព្រះមានព្រះភាគបានសេចក្តីថា ព្រះពុទ្ធ មានចំណែកកុសលដ៏ខ្ពង់ខ្ពស់ថ្លៃថ្លារកបុគ្គលណាស្មើគ្មាន ។

ពាក្យថាព្រះនាមជោគ បានសេចក្តីថា ព្រះពុទ្ធជាបុគ្គលមានជោគជាំគ្រោះល្អ ពោលគឺទ្រង់ឈ្នះពួកសាស្តាចារ្យឯទៀតៗ មានពួក កស្សបៈនៅដែនមគធៈ ជាដើម ឱ្យចុះចូលមកក្នុងព្រះសាសនាព្រះអង្គហើយក្នុងរយៈកាលដែលព្រះអង្គទ្រង់គង់ ព្រះជន្មនៅ ព្រះអង្គយាងទៅប្រកាសសាសនា ដឹកនាំពួកមនុស្សសត្វទេវតានៅទីណា ក៏តែងមានគេចុះចូល

ស្តាប់ព្រះឱវាទរបស់ព្រះអង្គជានិច្ច ។ គឺដោយហេតុនេះហើយទើបព្រះអង្គមានព្រះនាមថា ព្រះមានជោគ ។

ពាក្យថាព្រះអង្គ ជាអ្នកបំបាត់បង់មានន័យថា ព្រះអង្គទ្រង់បំបាត់បង់កងកិលេសតូចធំទាំងអស់ មិនអោយសេសសល់ឡើយ ពោលគឺព្រះ-អង្គគ្មាន លោភៈ ទោសៈ មោហៈផង កំចាត់អោយអស់រលីងនូវមារទាំងឡាយផង ។

**ស**~ពាក្យថា **មារ** មានន័យយ៉ាងណា ? មានប៉ុន្មានយ៉ាង ?អ្វីខ្លះ?

**ច**~ពាក្យថា មារ ប្រែថា សត្រូវជាគ្រឿងសម្លាប់កុសលធម៌ ។ មានមារ ៥យ៉ាងគឺ :

**១~កិលេសមារ** សត្រូវគឺកិលេស ដែលតែងបៀតបៀនមនុស្សសត្វ ។ កិលេសមារនេះ មានចំនួន ១៥០០ ។

**២~ខន្ធមារ** សត្រូវគឺឧបាទានក្ខន្ធទាំង ៥ គឺ រូបូបាទានក្ខន្ធ ១ វេទនូបា-ទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ និង វិញ្ញាណូបាទានក្ខន្ធ ១ ។

**៣~អភិសង្ខារមារ** សត្រូវគឺអភិសង្ខារ បានដល់បុញ្ញាភិសង្ខារ និង អបុញ្ញាភិសង្ខារ គឺកុសលនិងអកុសលដែលតាក់តែងសត្វឱ្យល្អឱ្យអាក្រក់ ។

**៤~មច្ចុមារ** សត្រូវគឺសេចក្តីស្លាប់ ដែលតែងផ្តាច់ផ្តិលជីវិតសត្វទូទៅដោយឥតរើសមុខ ។

**៥~ទេវបុត្តមារ** សត្រូវគឺកិលេសដែលតែងចងសត្វទុកដោយខ្សែ រាគៈ ទោសៈ មោហៈ និង តណ្ហា ឱ្យអន្តរាយស្ថិតនៅក្នុងការតក់ស្លុតភ័យខ្លាច ។

ព្រះពុទ្ធទ្រង់ឈ្នះនូវកិលេសទាំង ៥ នេះដោយដាច់ខាត ។ ដូច្នេះព្រះនាមថា ភគវា នេះមានន័យច្រើនយ៉ាងដូចបានពណ៌នាមកហើយប៉ុន្តែន័យដែលទូលាយជាងគេគឺថា ព្រះអង្គបានលះបង់នូវត្រៃភពអស់ដោយការលែងត្រលប់មកកើតទៀតឡើយ ។

ការពណ៌នាអំពីបញ្ហាពុទ្ធគុណរួចមកហើយនេះ បញ្ជាក់ឱ្យឃើញថាព្រះពុទ្ធអង្គជាបុគ្គលមានព្រះគុណសម្ប័ទគ្រប់យ៉ាងស្អាតស្អំ គ្មានលាយដោយកិលេសជាគ្រឿងសៅហ្មងបន្តិចសោះឡើយ ។

**ចប់ប្រស្នាក្នុងព្រះពុទ្ធគុណ**

# ធម្មគុណបញ្ហា

## ការចោទ-ឆ្លើយក្នុងគុណព្រះធម៌

**ស.**ពាក្យថា **ធម្មគុណ** ប្រែថាដូចម្ដេច ? អ្វីទៅដែលហៅថាធម៌? ចូរអធិប្បាយពន្យល់ !

**ឆ.**ធម្មគុណ ប្រែថា គុណគឺព្រះធម៌ ។ ពាក្យថាព្រះធម៌នេះបានដល់គុណជាតិ ឬសភាវៈ ដែលទ្រទ្រង់សត្វមិនឱ្យធ្លាក់ចុះទៅក្នុងទីថោកទាប ឬសភាវៈ ដែលស្អាតបរិសុទ្ធគ្មានលាយឡំដោយគ្រឿងសៅហ្មង។

**ស.**ពាក្យថា ធម្មគុណនេះ អាចប្រែយ៉ាងណាទៅទៀតដែរឬទេ ? ហើយមានន័យយ៉ាងណា ?

**ឆ.** អាចប្រែបានថា គុណរបស់ព្រះធម៌ មានន័យថាព្រះធម៌នេះមានគុណគាប់ប្រសើររបស់ខ្លួន ឬ មានលក្ខណៈខ្លួនត្រង់ការរក្សាអ្នកប្រតិបត្តិតាម មិនឱ្យធ្លាក់ចុះទៅក្នុងទីថោកទាប ។ ដរាបណាដែលបុគ្គលរាល់រូបបានប្រតិបត្តិធ្វើតាមដោយត្រឹមត្រូវច្បាស់ ប្រាកដហើយ ដរាបនោះព្រះធម៌នេះ តែងជួយទ្រទ្រង់រក្សា អ្នកប្រតិបត្តិឱ្យបានខ្ពង់ខ្ពស់មានសតិបញ្ញាស្មារតីភ្លឺថ្លា យល់ផ្លូវត្រូវយល់ប្រយោជន៍គ្រប់យ៉ាងជានិច្ចសមដូចពុទ្ធភាសិតថា :

"**ធម្មោ ហវេ រក្ខតិ ធម្មចារឹ ធម្មោ សុចិណ្ណោ សុខមាវហាតិ** " ព្រះធម៌តែងរក្សាបុគ្គលអ្នកប្រតិបត្តិធម៌ ព្រះធម៌ដែលគេសន្សំដោយល្អហើយនឹងនាំមកនូវសេចក្ដីសុខ ។

**ស.**ចុះពាក្យថា **ស្វាក្ខាតោ ភគវតា ធម្មោ** ប្រែថាដូចម្ដេច ? មានន័យ និង សេចក្ដីអធិប្បាយដូចម្ដេច ? ទៅវិញ ?

**ឆ.**ស្វាក្ខាតោ ភគវតា ធម្មោ ប្រែថា ព្រះបរិយត្តិធម៌គឺព្រះត្រៃបិដកជាធម៌គឺព្រះដ៏មានព្រះភាគសំដែងហើយដោយល្អព្រមទាំងព្រះនព្វលោកុត្តរធម៌គឺមគ្គ ៤ ផល ។

ព្រះបរិយត្តិធម៌ បានដល់ព្រះត្រៃបិដកគឺព្រះវិន័យ ព្រះសូត្រនិងព្រះអភិធម្ម ដែលជាធម៌សំរាប់សិក្សាទន្ទេញឱ្យចាំមាត់ ។ ព្រះធម៌ដែលព្រះសម្ពុទ្ធទ្រង់សម្ដែងហើយ ដោយល្អ ឬយ៉ាងពិរោះនោះ មានលក្ខណៈបែបនេះគឺ :

**១-អាទិកល្យាណ** ពិរោះល្អខាងដើម ។

**២-មជ្ឈេកល្យាណ** ពិរោះល្អកណ្ដាល ។

**៣-បរិយោសានកល្យាណ** ពិរោះល្អខាងចុង ។ បើសំដែងគាថាតែមួយ ក៏មានលំអរទាំង ៣ នេះដែរ ។

បើទ្រង់ត្រាស់សំដែងសូត្រណា ដែលមានអនុសន្ធិ (តំណរឿង)

មួយដូចគ្នាសូត្រនោះមានលំអរ និង ពិរោះ ៣ គឺ

**ក~អាទិបទ** ពិរោះដោយនិទានរឿង ។

**ខ~មជ្ឈេបទ** ពិរោះដោយសេចក្តីអធិប្បាយ ។

**គ~បរិយោសានបទ** ពិរោះដោយនិគម វចនៈ គឺពាក្យប្រមូលផ្តុំថាឡើងវិញ ។

បើទ្រង់ត្រាស់សម្តែងសូត្រដែលមានអនុសទ្ធិទីទៃពីគ្នាក៏មាន :

**ក~អាទិបទ** ពិរោះឧប្បត្តិ និង សេចក្តីនិទានជារឿងរ៉ាវ ។

**ខ~មជ្ឈេបទ** ពិរោះដោយហេតុបច្ច័យ ជាគ្រឿងអាង (ឧទាហរណ៍) មានន័យសេចក្តីក្បោះក្បាយ ។

**គ~បរិយោសានបទ** ពីរោះល្អដោយព្រះបន្ទូលបន្ថែមផ្ទួនៗ ញ៉ាំងអ្នកស្តាប់ឱ្យចូលចិត្ត ហើយមានជំនឿជ្រះថ្លា ។

បើទ្រង់សម្តែងពាក្យប្រៀនប្រដៅ :

**ក~អាទិបទ** ពិរោះដោយសីល ។

**ខ~មជ្ឈេបទ** ពិរោះដោយសមថវិបស្សនារហូតដល់មគ្គផល ។

**គ~បរិយោសានបទ** ពិរោះដោយបរមសុខ គឺព្រះនិញ្វន ។

**ឃ~បរិយោសានបទ** ពិរោះដោយបរមសុខ គឺព្រះនិញ្វន ។

**ស.** បិដកទាំង ៣ បើរួមមកទៀត តើមានប៉ុន្មាន ? អ្វីខ្លះ ?

**ឆ.**បើរួមមកមាន ២ គឺ ធមិ ១ វិន័យ ១ ។

**ស.ធម៌** បានដល់បិដកណា? **វិន័យ** បានដល់បិដកណា ?

**ឆ.**ធមិបានដល់សុត្តន្តបិដក និង អភិធម្មបិដក ឯ វិន័យបានដល់វិន័យបិដកទាំងមូល ។

**ស.**សុត្តន្តបិដក គឺអ្វីខ្លះ ? ចូររាប់ !

**ឆ.** សុត្តន្តបិដក ចែកជានិកាយមាន ៥គឺ

**១~ទីឃនិកាយ** មានសូត្រ ៣៤ មានព្រហ្មជាលសូត្រជាដើម ។

**២~មជ្ឈិមនិកាយ** មានសូត្រ ២៥២ មានមូលបរិយាយសូត្រជាដើម ។

**៣~សំយុត្តនិកាយ** មានសូត្រ ៧៧៦២ មានឱឃតរណសូត្រជាដើម ។

**៤~អង្គុត្តនិកាយ** មានសូត្រ ៩៥៥៧ មានចិត្តបរិយាទានសូត្រជាដើម ។

**៥~ខុទ្ទនិកាយ** មាន ១៥ សូត្រ មានខុទ្ទកបាឋជាដើម ។

**ស.**ចុះអភិធម្មបិដក គឺអ្វីដែរ ចូររាប់ !

**ឆ.**អភិធម្មបិដកមាន ៧ គម្ពីរគឺ ធម្មសង្គណី ១ វិភង្គ១ ធាតុកថា ១ បុគ្គលប្បញ្ញត្តិ១ កថាវត្ថុ១ និង មហាបដ្ឋាន១ ។

រួមទាំងនិកាយ ៥(មាន១៧.៦២២) ក្នុងសុត្តន្តបិដកអភិធម្ម ៧ គម្ពីរ ក្នុងព្រះអភិធម្មបិដក ទាំងអស់នេះហៅថា ព្រះធម៌ ។

**ស.**ចុះ **បិដក** ប្រែថា ដូម្តេច ?

**ឆ.**បិដក ប្រែថា ភាជនៈ សំរាប់ទ្រទ្រង់ព្រះធម៌ និង វិន័យ ។

**ស.**បិដកទាំង ៣ បើចាត់តាំងជាទេសនា តើមានប៉ុន្មានយ៉ាង? អ្វីខ្លះ ? បិដកណាចាត់ចូលក្នុងទេសនាណា ?

**ឆ.**បើចាត់តាំងជាទេសនា មាន ៣ យ៉ាងគឺ :

**១-អាណាទេសនា** បានដល់វិន័យបិដកដែលជាបទអាជ្ញាដែលព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់បញ្ញត្តឡើង ។

**២-វោហារទេសនា** បានដល់សុត្តន្តបិដក ដែលព្រះពុទ្ធទ្រង់សម្តែងដោយវោហារយ៉ាងប៉ិនប្រសប់ ដើម្បីដឹកនាំសត្វលោកឱ្យចិត្តស៊ប់ក្នុងព្រះបរមពុទ្ធោវាទ ។

**៣-បរមត្ថទេសនា** បានដល់ព្រះអភិធម្មដកដែលព្រះពុទ្ធទ្រង់សំដែងយ៉ាងល្អិតល្អន់ជាទីបំផុត ។

**ស.**បិដកទាំង ៣ បើចែកទៅតាមសាសនា (ពាក្យប្រៀនប្រដៅ) មានប៉ុន្មាន ? អ្វីខ្លះ ? បិដកណាចាត់តាំងចូលក្នុងពួកណា ?

**ឆ.**បើចែកទៅតាមសាសនាមាន ៣យ៉ាងគឺ :

**១-យថាបរាធសាសនា** ពាក្យប្រដៅតាមកំហុសខុសឆ្គងរបស់សត្វលោកបានដល់វិន័យ ។

**២-យថានុលោមសាសនា** ពាក្យប្រៀនប្រដៅអនុលោម (យោគយល់ស្របតាម) គួរដល់អធ្យាស្រ័យរបស់សត្វបានដល់ព្រះសូត្រ ។

**៣-យថាធម្មសាសនា** ពាក្យប្រៀនប្រដៅដ៏សមគួរដល់ធម៌ជាន់ខ្ពស់ចំពោះសត្វដែលមានមានៈខ្លាំងបានដល់ព្រះអភិធម្ម ។

**ស.**ចុះបើចែកទៅតាមកថាវិញ តើមានអ្វីខ្លះ ? បិដកណារាប់ចូលក្នុងកថាណា ?

**ឆ.**បើពោលដោយ កថា ក៏មាន ៣ យ៉ាងដែរ គឺ :

**១-សំវរាសំវរកថា** ព្រះពុទ្ធដិកាសំដែងពីកាសង្រួម និងមិនសង្រួមបានដល់វិន័យបិដក ។

**២-ទិដ្ឋិវិនិវេឋនកថា** ព្រះពុទ្ធដិកាសំដែងពីការលះបង់ទិដ្ឋិបានដល់សុត្តន្តបិដក ។

**៣-នាមរូបបរិច្ឆេទកថា** ព្រះពុទ្ធដិកាសំដែងកំណត់ពី នាមនិងរូបដែលទំនាស់ នឹងកិលេស បានដល់អភិធម្មបិដក ។

**ស.**បើចែកទៅតាមសិក្ខា តើមានប៉ុន្មាន? អ្វីខ្លះ ? បិដកណាចាត់ចូលក្នុងសិក្ខាណា?

**ច.**បើចែកទៅតាមសិក្ខាក៏មាន ៣ យ៉ាងដែរគឺ :

**១-អធិសីលសិក្ខា** ការសិក្សាអំពីសីលជាន់ខ្ពស់ បានដល់វិន័យបិដក ។

**២-អធិចិត្តសិក្ខា** ការសិក្សារៀនយកអធិចិត្ត ចាត់ចូលក្នុងសុត្តន្តបិដក ។

**៣-អធិប្បញ្ញាសិក្ខា** ការសិក្សារៀនយកអធិប្បញ្ញា ចាត់ចូលក្នុងអភិធម្មបិដក ។

**ស.**បើចែកទៅតាម **បហានៈ** តើមានប៉ុន្មានដែរ ?អ្វីខ្លះ? បិដកណាចាត់ចូលក្នុង បហានៈ ណា ?

**ច.**បើចែកតាម បហានៈ ក៏មាន ៣ យ៉ាងដែរគឺ :

**១-វិតិក្កមប្បហានៈ** ការលះបង់នូវិតិក្កមកិលេស ជាសត្រូវនឹងសីលបានដល់ វិន័យបិដក ។

**២-បរិយុដ្ឋានប្បហានៈ** ការលះបង់បរិយុដ្ឋានកិលេសដែលជាសត្រូវដល់សមាធិបានដល់សុត្តន្តបិដក ។

**៣-អនុសយប្បហានៈ** ការលះបង់ អនុសយកិលេស (កិលេសនៅអាស្រ័យត្រាំក្នុងខន្ធសន្តាន) បានដល់អភិធម្មបិដក ។

ម្យ៉ាងទៀត :

**១-តទង្គប្បហានៈ** ការលះបង់កិលេសបានមួយពេលមួយស្របក់ បានដល់ វិន័យបិដក ។

**២-វិក្ខម្ភនប្បហានៈ** ការលះបង់កិលេសដោយសង្កត់សង្កិនញាំញីចាត់ជាសុត្តន្តបិដក ។

**៣-សមុច្ឆេទប្បហានៈ** ការលះបង់កិលេសដោយដាច់ស្រឡះចាត់ជា អភិធម្មបិដក ។

**ស.**ក្នុងបិដកទាំង ៣ បិដកនីមួយៗ មានជម្រៅប៉ុន្មាន ?អ្វីខ្លះ?ចូរាប់!

**ច.**បិដក នីមួយៗមានជម្រៅ ៤ គឺ :

**១-ធម្មគម្ភីរៈ** មានជម្រៅដោយបាលី ។

**២-អត្ថគម្ភីរៈ** មានជម្រៅដោយសេចក្តី ។

**៣-ទេសនាគម្ភីរៈ** មានជម្រៅដោយការសំដែង ។

**៤-បដិវេធគម្ភីរៈ** មានជម្រៅដោយការត្រាស់ដឹង ។

**ស.**ព្រះធម៌ទាំងអស់ តើមានប៉ុន្មានព្រះធម្មក្ខន្ធ ?

**ច.**មានចំនួន ៨៤.000 ព្រះធម្មក្ខន្ធ ។

**ស.**ចុះលោកុត្តរធម៌ គឺអ្វី ? មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

**ច.**ធម៌សំរាប់ស្រង់សត្វលោក ឬធម៌ជាកំពូលនៃលោក ហៅថាលោកកុត្តរធម៌មាន ១០ យ៉ាង ដែលចែកជាផ្នែកដូចតទៅ :

**១-សតិបដ្ឋាន ៤ គឺ :**

**ក-កាយានុបស្សនាសតិបដ្ឋាន** ការតាំងស្មារតី ដើម្បីពិចារណារូបរាងកាយ ។

**ខ-វេទនានុបស្សនាសតិបដ្ឋាន** ការតាំងស្មារតីដើម្បីពិចារណាវេទនា ។

**គ-ចិត្តានុបស្សនាសតិបដ្ឋាន** ការតាំងស្មារតី ដើម្បីពិចារណាចិត្ត ។

**ឃ-ធម្មានុបស្សនាសតិបដ្ឋាន** ការតាំងស្មារតី ដើម្បីពិចារណានូវធម៌ ។

**២-សម្មប្បធាន** សេចក្តីព្យាយាម ជាគ្រឿងតាំងទុកយ៉ាងស្មើ មាន ៤ យ៉ាងគឺ

ក-ព្យាយាមលះបាបធម៌ដែលកើតឡើងហើយ ។

ខ-ព្យាយាមធ្វើបាបធម៌ ដែលមិនទាន់កើតមានឡើង មិនឱ្យកើតឡើងបាន ។

គ-ព្យាយាមបង្កើតកុសលធម៌ ដែលគ្មានក្នុងខ្លួនឱ្យកើតមានឡើង ។

ឃ-ព្យាយាមរក្សាកុសលធម៌ ដែលកើតឡើងហើយ ឱ្យនៅគង់វង់ ។

**៣-ឥទ្ធិបាទ** ធម៌ជាគ្រឿងសំរេចអំណាច ៤ ប្រការគឺ

**ក-ឆន្ទិទ្ធិបាទ** សេចក្តីបំណងជាទីតាំងនៃ ឫទ្ធិអំណាច ។

**ខ-វិរិយិទ្ធិបាទ** សេចក្តីព្យាយាមដើម្បីសំរេចអំណាច ។

**គ-ចិត្តិទ្ធិបាទ** សេចក្តីត្រិះរិះសន្សំ ឬការពេញចិត្ត នឹងកិច្ចការនោះៗជាទីតាំងនៃឫទ្ធិអំណាច ។

**ឃ-វិមំសិទ្ធិបាទ** ការសាកល្បងធ្វើលមើល ជាទីតាំងនៃឫទ្ធិអំណាច ។

**៤-ឥន្ទ្រិយ** ភាពជាធំ ៥ ប្រការគឺ

**ក-សទ្ធិន្ទ្រិយ** ជំនឿ ជាធំ

**ខ-វិរិយិន្ទ្រិយ** សេចក្តីព្យាយាម ជាធំ

**គ-សតិន្ទ្រិយ** ស្មារតី ជាធំ

**ឃ-សមាធិន្ទ្រិយ** សមាធិ ជាធំ

**ង-បញ្ញិន្ទ្រិយ** ប្រាជ្ញា ជាធំ ។

**៥-ពល** ធម៌ជាកំលាំង ៥យ៉ាង

**ក-សទ្ធាពល** កម្លាំងគឺ សទ្ធា

**ខ-វិរិយពល** កម្លាំងគឺ ព្យាយាម

**គ-សតិពល** កម្លាំងគឺ ស្មារតី

**ឃ-សមាធិពល** កម្លាំងគឺ សមាធិ

**ខ.បញ្ញាពល** កម្លាំងគឺ ប្រាជ្ញា ។

**៦.ពោជ្ឈង្គៈ** អង្គនៃធម៌ជាគ្រឿងត្រាស់ដឹងមាន ៧ គឺ

**ក.សតិសម្ពោជ្ឈង្គៈ** អង្គនៃធម៌ជាគ្រឿងត្រាស់ដឹងគឺស្មារតី ។

**ខ.ធម្មវិនយសម្ពោជ្ឈង្គៈ** អង្គនៃធម៌ជាគ្រឿងត្រាស់ដឹងគឺប្រាជ្ញាពិចារណាធម៌ ហើយប្រតិបត្តិការដោយសេចក្តីយល់ត្រូវរបស់ខ្លួនដែលអាចជាមធ្យោបាយលះកិលេសបាន ។

**គ.វីរិយសម្ពោជ្ឈង្គៈ** អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង គឺសេចក្តីព្យាយាមតាមគន្លង សម្មប្បធានទាំង ៤ ។

**ឃ.បីតិសម្ពោជ្ឈង្គៈ** អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង គឺការឆ្អែតកាយ ឆ្អែតចិត្ត ។

**ង.បស្សទ្ធិសម្ពោជ្ឈង្គៈ** អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង គឺភាពនៃកាយ និងចិត្តស្ងប់ស្ងៀម មានរបៀបរៀបរយ ។

**ច.សមាធិសម្ពោជ្ឈង្គៈ** អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង គឺជាការតាំងចិត្តឱ្យនឹង ស្ងប់ស្ងៀម គ្មានខ្វល់ពីរឿងអ្វី ។

**ឆ.ឧបេក្ខាសម្ពោជ្ឈង្គៈ** អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង គឺភាពព្រងើយកន្តើយមិនសោមនស្ស មិនទោមនស្ស ចំពោះហេតុការណ៍ទាំងពួង ។

**៧.អដ្ឋង្គិកមគ្គ** ផ្លូវមានអង្គ ៨ប្រការគឺ :

**ក.សម្មាទិដ្ឋិ** ការយល់ឃើញត្រូវ

**ខ.សម្មាសង្កប្ប** គំនិតត្រិះរិះត្រូវ

**គ.សម្មាវាចា** សំដីនិយាយត្រូវ

**ឃ.សម្មាកម្មន្តោ** ការងារត្រូវ

**ង.សម្មាអាជីវោ** ការចិញ្ចឹមជីវិតត្រូវ

**ច.សម្មាវាយាមោ** សេចក្តីព្យាយាមត្រូវ

**ឆ.សម្មាសតិ** ការរលឹកត្រូវ

**ជ.សម្មាសមាធិ** ការតាំងចិត្តត្រូវ ។

**៨.អរិយមគ្គ ៤ គឺ :**

**ក.សោតាបត្តិមគ្គ**

**ខ.សកិទាគាមិមគ្គ**

**គ.អនាគាមិមគ្គ**

**ឃ.អរហត្តមគ្គ**

**៩.សាមញ្ញផល ៤ យ៉ាង គឺ**

**ក.សោតាបត្តិផល**

**ខ.សកិទាគាមិផល**

**គ-អនាគាមិផល**

**ឃ-អរហត្តផល**

**១០-**និព្វានមានតែមួយ គឺ បរមសុខ ព្រោះគ្មាន រាគៈ ទោសៈ និង មោហៈ នៅលាយឡំ ។

**ស-**ចុះពាក្យថា **សន្ទិដ្ឋិកោ** ប្រែថាដូចម្ដេច ? ចូរអធិប្បាយ!

**ច-**សន្ទិដ្ឋិកោ ប្រែថា ធម៌ដែលព្រះអរិយជនឃើញច្បាស់ដោយខ្លួន ។ សេចក្ដីថា ធម៌ ដែលព្រះអរិយបុគ្គលបានចេះដឹងស្គាល់ហើយនោះ មិនមែនដោយជឿតាម ស្ដាប់ ឬ និយាយតាមបុគ្គលណាម្នាក់ឡើយ គឺលោកបានឃើញ ដឹង ចេះ យល់ ជាក់ច្បាស់ដោយខ្លួនឯងតែម្ដង ។ ការចេះដឹង និង យល់ឃើញច្បាស់ខ្លួនឯង គឺដោយព្រះអរិយបុគ្គលនោះជាអ្នកគ្មានកិលេសគឺ រាគៈ ទោសៈ មោហៈ នៅប្រចាំក្នុងកាយក្នុងចិត្តសោះឡើយព្រះអរិយបុគ្គល ដែលបានត្រាស់ដឹងធម៌ទាំងពួងហើយគឺជាអ្នកមានការពិចារណាដោយល្អិតល្អន់ណាស់ ដោយហេតុនេះហើយ ទើបលោកហៅថា ព្រះអរិយបុគ្គលថា សន្ទិដ្ឋិកោ ដែលអាចប្រែបានម្យ៉ាងទៀតអ្នកបានឃើញច្បាស់ប្រាកដដោយខ្លួនឯង ។

**ស-**ចុះពាក្យថា **អកាលិកោ** ប្រែដូចម្ដេច ?មានសេចក្ដីអធិប្បាយយ៉ាងណា ?

**ច-**អកាលិកោ ប្រែថា ជាធម៌ឱ្យផលមិនរង់ចាំកាលឡើយ គឺថាកាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផលក៏កើតឡើងដែរ ។ សេចក្ដីថា កាលបុគ្គលបានប្រព្រឹត្តធម៌ដើម្បីសម្រេចមគ្គ កាលកាលបើបានសម្រេចមគ្គហើយ ជននោះក៏បានទទួលផលភ្លាម ឥតនៅរេរារង់ចាំថា ដល់ពេលនេះ ឬពេលនោះនឹងត្រូវបានទទួលផលឡើយ ។

**ស-**ចុះពាក្យថា **ឯហិបស្សិកោ** មានសេចក្ដីប្រែ និងអធិប្បាយដូចម្ដេចដែរ ?

**ច-**ឯហិបស្សិកោ ប្រែថា ធម៌គួរដល់ឯហិស្សវិធី បានសេចក្ដីថា កាលបើព្រះអរិយបុគ្គល បានចម្រេចផលហើយ ក៏អាចចង្អុលប្រាប់ធម៌ជាមាគ៌ាល្អ ត្រង់ ត្រឹមត្រូវ ដល់អ្នកដទៃបានព្រោះធម៌នេះ ជាគុណជាតិស្អាតបរិសុទ្ធ មិនត្រូវលាក់លៀម ឬនិយាយប្រាប់គ្នាដោយលួចលាក់ ខ្សឹបខ្សៀវឡើយ ត្រូវតែប្រាប់ដោយពេញមុខ ហើយដោយការពន្យល់បង្ហាញគ្នាបានច្បាស់លាស់ទៀតផង ។

**ស-**ពាក្យថា **ឱបនយិកោ** មានសេចក្ដីប្រែ និង អធិប្បាយដូចម្ដេចដែរ ?

**ច-**ឱបនយិកោ ប្រែថា ធម៌ដែលព្រះអរិយបុគ្គលគប្បីបង្អោនចូលទៅទុកក្នុង ខ្លួនដោយអំណាចនៃភាវនា បានសេចក្ដីថា ព្រះធម៌នេះព្រះអរិយបុគ្គលតែងចំរើន តាំងទុកក្នុងខ្លួនជាប់ជានិច្ច ទោះមានឧបសគ្គបែបណា

ក៏ព្រះអរិយបុគ្គលមិនអើពើ គឺ លោកមិនលះបង់ព្រះធម៌នេះចោលដល់ម្តងណាឡើយ ។

**ស.** ជាទីបញ្ចប់ពាក្យថា **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ប្រែថា យ៉ាងណា ? ចូរប្រែ និង ធ្វើអធិប្បាយពន្យល់ !

**ឆ.** ប្រែថាធម៌ដែលអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូជាដើម គប្បីឃើញច្បាស់ក្នុងចិត្ត នៃខ្លួន មានសេចក្តីអធិប្បាយពន្យល់ថាពួកព្រះអរិយ-បុគ្គលដែលបានសម្រេចធម៌ហើយ តែងតែឃើញច្បាស់ នូវធម៌នោះថា មគ្គផល និងនិព្វាន គឺ អញបានធ្វើ បានទទួល និងបានធ្វើអោយជាក់ច្បាស់ហើយ ដោយគ្មានការសង្ស័យ ។ ព្រះធម៌ជាលោកុត្តរនេះជាវិស័យរបស់អាត្មាអញអរិយជន មិនមែនវិស័យរបស់បុថុជ្ជនអ្នកមានកិលេសឡើយ ។

ព្រះធម៌ ដែលបានអធិប្បាយមកដោយសង្ខេបនេះ បានបញ្ជាក់អោយឃើញថាជា គុណជាតិល្អ ស្អាតបរិសុទ្ធណាស់ គ្មានលាយឡំដោយគ្រឿងសៅហ្មងឡើយ ពិសេសគឺ លោកុត្តរធម៌ជាធម៌ជាន់ខ្ពស់ជាគោល-ដៅនៃសាសនា ជាវិស័យនៃព្រះអរិយជន មានព្រះពុទ្ធជាម្ចាស់ជាដើម នោះផង ។

**(ចប់ប្រស្នាក្នុងធម្មគុណ)**

# សង្ឃគុណប្បញ្ហា

## ការចោទ-ឆ្លើយក្នុងគុណព្រះសង្ឃ

**ស.** ចូរអធិប្បាយពន្យល់អំពីពាក្យថា **សង្ឃគុណ** នេះដោយខ្លីហើយងាយស្តាប់មកមើល !

**ឆ.** ពាក្យថា សង្ឃគុណ ប្រែថាគុណរបស់ព្រះសង្ឃ បានសេចក្តីថាព្រះសង្ឃជាអ្នកមានគុណច្រើនប្រការគឺ ម្យ៉ាងលោកជាអ្នកមានកាយវាចាចិត្តស្អាតបរិសុទ្ធអាចបានជាស្រែបុណ្យនៃអ្នកសន្សំកុសលកម្មផ្សេងៗ ម្យ៉ាងទៀតលោកជាអ្នកទ្រទ្រង់ព្រះធម៌ ដោយផ្ទាល់ជាងពុទ្ធបរិស័ទឯទៀតៗ។ ត្រង់ចំណុចនេះហើយដែលថាព្រះសង្ឃជាអ្នកមានគុណ។

**ស.** សង្ឃមានប៉ុន្មានពួក ? មួយពួកៗមានសេចក្តីអធិប្បាយដូចម្តេច ?

**ឆ.** សង្ឃមាន ២ ពួកគឺ

**១.សម្មតិសង្ឃ** សង្ឃដែលកើតឡើងដោយការសន្មតិ ។

**២.អរិយសង្ឃ** បានដល់សង្ឃដែលគ្មានកិលេសតណ្ហា គឺព្រះអរិយ-បុគ្គលជាសាវ័កនៃព្រះសម្មាសម្ពុទ្ធ ។

ដែលហៅថា សម្មតិសង្ឃ បានដល់ភិក្ខុសង្ឃ ដែលសម្រេចញត្តិចតុត្ថ-កម្មវាចា ហើយរាប់ចាប់តាំងពី ៤ អង្គឡើងទៅ សង្ឃពួកនេះបានដល់សង្ឃសាវ័កជាបុថុជ្ជន ដូចជាព្រះសង្ឃសព្វថ្ងៃនេះជាដើម ។

អរិយសង្ឃ គឺអរិយបុគ្គល ដែលបានសម្រេចមគ្គផលរួចហើយបាន ដល់ព្រះសាវ័ក ដែលគ្មានកិលេសតណ្ហានៅក្នុងខន្ធសន្ដាននោះឯង។

**ស៎**ពាក្យថា **សុបដិបន្នោ** ប្រែថាដូចម្ដេច ? ចូរអធិប្បាយ ។

**ឆ៎**ពាក្យថា សុបដិបន្នោ ប្រែថា ជាការប្រតិបត្ដិដោយប្រពៃបាន សេចក្ដីថា លោកប្រតិបត្ដិតាមព្រះនព្វលោកុត្ដរធម៌ទាំង ៩ ប្រការ គឺមគ្គ ៤ ផល ៤ និងនិព្វាន ១ ឬ ប្រតិបត្ដិតាមដោយសម្មាបដិបទា ជាការ ប្រតិបត្ដិដោយការមិនវិលត្រឡប់ កាលបើលោកបានជាអរិយៈហើយ ក៏ មិនអាចត្រឡប់មក ប្រព្រឹត្ដអំពើអាក្រក់ដូចបុថុជ្ជនបានឡើយ ។ ការប្រតិបត្ដិប៉ុណ្ណេះជាដើម ហៅថា ការប្រតិបត្ដិដោយប្រពៃ។

**ស៎**ចុះ **ឧជុបដិបន្នោ** ជាការប្រតិបត្ដិយ៉ាងណាដែរ ?

**ឆ៎**ឧជុបដិបន្នោ គឺជាការប្រតិបត្ដិដោយត្រង់ បានសេចក្ដីថា ព្រះសង្ឃ ជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្ដិតាមមជ្ឈិមាបដិបទាដែល ជាការប្រតិបត្ដិយ៉ាងកណ្ដាល មិនប្រកបដោយផ្លូវរកសុខក្នុងកាមនឹង មិន ប្រព្រឹត្ដឱ្យលំបាកខ្លួនឡើយ ។ ព្រះសង្ឃជាសាវ័កនោះ លោកប្រតិបត្ដិ តាមមគ្គមានអង្គ ៨ ជាផ្លូវសម្រាប់ធ្វើដំណើរទៅរកព្រះនិព្វានតែម្យ៉ាង ។

**ស៎ញាយបដិបន្នោ** តើមានន័យយ៉ាងណាដែរ ?

**ឆ៎**ញាយបដិបន្នោ មានន័យថាប្រតិបត្ដិ ដើម្បីត្រាស់ដឹងនូវព្រះនិព្វាន គឺលោកប្រតិបត្ដិ ដើម្បីចាក់ធ្លុះនូវព្រះនិព្វានតែម្យ៉ាងប៉ុណ្ណោះ មិនមែន ដើម្បីប្រយោជន៍ណាមួយក្នុងបច្ចុប្បន្ន មានការកោតសរសើរពីជនដទៃ ឬដើម្បីលាភសក្ការៈឡើយ ។

**ស៎**ចុះ **សាមីចិបដិបន្នោ** តើជាការប្រតិបត្ដិរបៀបណា ? ចូរពន្យល់ !

**ឆ៎**ការប្រតិបត្ដិដ៏សមគួរដល់សាមីចិកម្ម គឺគួរដល់សីល សមាធិ និង បញ្ញា ។

**ស៎**ពាក្យថា ព្រះសង្ឃទាំងនោះ បើរាប់ជាគូរមាន ៤ គូ បើ រាប់រៀង មាន ៨ នោះ តើអ្វីខ្លះ ?

**ឆ៎**បើរាប់ជាគូរនៃបុរសបុគ្គលមាន ៤ គូរនោះគឺ :

១-សោតាបត្ដិមគ្គ គូនឹង សោតាបត្ដិផល

២-សកិទាគាមិមគ្គ គូនឹង សកិទាគាមិផល

៣-អនាគាមិមគ្គ គូនឹង អនាគាមិផល

៤-អរហត្ដមគ្គ គូនឹង អរហត្ដផល ។

បើរាប់រៀងទៅវិញ គឺរាប់ខាងផ្នែកមគ្គ ៤ និងផ្នែកផល ៤ រួមត្រូវ ជា ៨ ។

**ស៎**សោតាបន្នបុគ្គល មានប៉ុន្មានពួក ? អ្វីខ្លះ ? ចូរពន្យល់!

**ច**-មាន ៣ ពួក គឺ

**១-សោតាបន្នបុគ្គល** ជា **ឯកពីជី** គឺលោកនៅកើតមួយកំណើតទៀត គឺមានសំរេចអរហត្តផល ។ មានវិបស្សនាក្លៀវក្លាបំផុត ។

**២-សោតាបន្នបុគ្គល** ជា **ឯកោ កោលៈ** គឺលោកនៅកើត ២ ឬ ៣ ជាតិទៀត ទើបបានសម្រេចអរហត្តផល ។ មានវិបស្សនាក្លៀវក្លាជាមធ្យម ។

**៣-សោតាបន្នបុគ្គល** ជា **សត្តក្ខត្តុំបរម** គឺលោកនៅកើតត្រឹម ៧ជាតិទៀត នឹងបានសម្រេចអរហត្ត ។ មានវិបស្សនាទន់បំផុត ។ ពួកសោតាបន្នបុគ្គល ជាអ្នកបរិបូណ៌ដោយសីល ។

**ស**-សកទាគាមិបុគ្គល បើចែកតាមខណៈចិត្តដែលលះកិលេសបានតើមានប៉ុន្មានពួក ?

**ច**-បើចែកតាមលក្ខណៈចិត្តដែលលះកិលេស បាន ១២ គឺ សកទាគាមិបុគ្គលមួយៗ មារមោក្ខ ៣ ហើយក្នុងវិមោក្ខមួយៗមានបដិបទា៤ទៀត ។

**ស**-ចុះអនាគាមិបុគ្គលមានប៉ុន្មានពួកដែរ ? អ្វីខ្លះ ? ចូពន្យល់

**ច**-មាន ៥ ពួកគឺ

**១-អន្តរាបរិនិព្វាយី** កើតក្នុងសទ្ធាវាសព្រហ្មលោក តែមិនទាន់ដល់ពាក់កណ្តាលអាយុ ក៏សម្រេចអរហត្តមគ្គ លះសំយោជនៈ កិលេសបាន ។

**២-ឧបហច្ចបរិនិព្វាយី** លោកដែលមានអាយុជាងពាក់កណ្តាលលុះពេលជិត និង ផុតអាយុ ក៏សម្រេចអរហត្តមគ្គ លះសំយោជនៈខាងលើទាំង ៥ ។

**៣-អសង្ខារបរិនិព្វាយី** លោកដែលញ៉ាំងអរហត្តមគ្គឱ្យកើតដោយការលះ សំយោជនៈទាំង ៥ ខាងលើបានដោយងាយ ដោយមិនបាច់តាំងព្យាយាមតឹងតែងឡើយ ។

**៤-សសង្ខារបរិនិព្វាយី** លោកដែលញ៉ាំងអរហត្តមគ្គឱ្យកើតឡើងដោយ កម្រលុះណាតែប្រកបព្យាយាមតឹងរឹង ។

**៥-ឧទ្ធំសោតោអកនិដ្ឋគាមី** លោកដែលមានខ្សែ ខាងលើទៅកាន់ លោកភពអកនិដ្ឋ គឺច្យុតពីអវិហារព្រហ្ម ទៅកាន់អតប្បាព្រហ្ម ច្យុតពីនេះទៅកាន់សុទស្សាព្រហ្ម. ច្យុតទៅទៀតកើតនៅសុទស្សីព្រហ្មលុះច្យុតពីនេះទៅកាន់អកនិដ្ឋព្រហ្ម ទើបញ៉ាំងអរហត្តមគ្គឱ្យកើតឡើង លះសំយោជនៈខាងលើក្នុងព្រហ្មលោកនោះ ។

**ស.**ចុះលោកបរិបូណ៌ដោយធម៌អ្វី ?

**ច.**អនាគាមិបុគ្គលបរិបូណ៌ដោយសមាធិ ។

**ស.**ចុះ ព្រះអរហន្ត មានប៉ុន្មានពួកតើអ្វីខ្លះ ? មានសេចក្តីពន្យល់យ៉ាងណា?

**ច.**ព្រះអរហន្ត មាន ៤ ពួក គឺ :

**១.សុក្ខវិបស្សកោ** លោកអ្នកមានកិលេសរីងស្ងួត តែគ្មានឫទ្ធិអំណាចហោះហើរបានឡើយ ។

**២.តេវិជ្ជោ** លោកដែលមានវិជ្ជា ៣ ។

**៣.ឆឡភិញ្ញោ** លោកដែលមានអភិញ្ញា ៦ ។

**៤.បដិសម្ភិទប្បត្តោ** លោកដែលសម្រេចបដិសម្ភិទា ៤ ពួក

អរហន្តទាំង ៤ ពួកនេះជាអ្នកបរិបូណ៌ដោយប្រាជ្ញា ។

**ស.**ពាក្យថា **អាហុនេយ្យោ** មានន័យយ៉ាងណា ?

**ច.**អាហុនេយ្យោ មានន័យសេចក្តីថា លោកគួរទទួលនូវចតុប្បច្ច័យដែលបុគ្គលនាំអំពីចម្ងាយចូលមកបូជា ពោលគឺព្រះសង្ឃពុទ្ធសាវ័កទាំងឡាយ ជាបុគ្គលបរិបូណ៌ដោយគុណធម៌ មានសីលជាដើមយ៉ាងក្រៃលែង កាលលោកបានទទួលចតុប្បច្ច័យអំពីទាយកទាយិកា ហើយលោកអាចធ្វើអោយចតុប្បច្ច័យ មានផលានិសង្សច្រើន ដូចស្រែដែលមានជីរជាតិល្អ ។

**ស.**ចុះ **បាហុនេយ្យោ** មានសេចក្តីពន្យល់ដូចម្តេចដែរ ?

**ច.**បាហុនេយ្យោ មានសេចក្តីអធិប្បាយពន្យល់ថា ព្រះសង្ឃព្រះសាវ័កទាំងនោះ ជាអ្នកទទួលអាគន្តុកទានគឺជាទានបុគ្គលតាក់តែងដើម្បីញាតិ និងមិត្តដែលមកអំពីទីផ្សេងៗ ហើយបង្អោនចូលមកបូជា ។

**ស.**អាគន្តុកទាន គឺអ្វី ?

**ច.**គឺទានដែលបុគ្គលរៀបរកប្រគេនភិក្ខុដែលទើបមកដល់ថ្មី ។

**ស.**ចុះឯពាក្យ **ទក្ខិណេយ្យោ** មានសេចក្តីអធិប្បាយបែបណាដែរ?

**ច.** ទក្ខិណេយ្យោ មានសេចក្តីថាព្រះសង្ឃពុទ្ធសាសនានោះជាអ្នកគួរទទួលទក្ខិណាទាន គឺទានដែលបុគ្គលជឿកម្ម នឹងផលហើយបូជា ។ ព្រះសង្ឃនោះ អាចញុំាងទានដែលធ្វើបែបនេះ ឱ្យសម្រេចផលតាមសេចក្តីប្រាថ្នា ។

**ស.**ពាក្យថា **អញ្ជលិករណីយោ** ប្រែថាដូចម្តេច ? ចូរប្រែនិងពន្យល់!

**ច.**អញ្ជលិករណីយោ ប្រែថា ព្រះសង្ឃសាវ័កទាំងនោះជាបុគ្គលគួរនឹងថ្វាយបង្គំ ព្រោះលោកជាបុគ្គលប្រកបដោយគុណធម៌ប្រចាំក្នុងខ្លួនយ៉ាងបរិបូណ៌ ។

**ស.**ចុះគុណថា **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** មានសេចក្តីពន្យល់យ៉ាងណាដែរ ?

**ច.** មានសេចក្តីពន្យល់ថា ព្រះសង្ឃទាំងនោះ ជាស្រែបុណ្យដ៏ប្រសើររបស់សត្វលោក ដែលសត្វលោកអាចធ្វើទានហើយ នឹងមានផលានិសង្ស

ច្រើន ព្រោះ ព្រះសង្ឃទាំងនោះប្រៀបបាននឹងស្រែដែលមានជីជាតិល្អ កាលបុគ្គលសាបព្រួសដាំបណ្តុះ ស្រូវ សណ្តែក ល្ង ជាដើមស្រែនោះហើយ ពិតជានឹងបានល្អ បានទទួលផលច្រើនតាមសេចក្តីប្រាថ្នា ។

សេចក្តីអធិប្បាយរួចមកហើយ អំពីគុណរបស់ព្រះសង្ឃនេះបាន សរឱ្យឃើញថា ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគមានគុណ ២ ប្រការគឺ អត្តហិតគុណ គុណធម៌ល្អប្រចាំនៅក្នុងខ្លួន និង បរហិតគុណ គុណធម៌ល្អអាចជួយអ្នកដទៃបាន ។ !



## សន្តិកថា

សូមឱ្យព្រះពុទ្ធសាសនា រុងរឿងចំរើន

សូមឱ្យព្រះពុទ្ធសាសនាផ្សាយទូទៅពេញសកលលោក

សូមឱ្យលោកទាំងមូល បានប្រកបដោយសន្តិភាព ។

ព្រះសក្យមុនីសម្ពុទ្ធទ្រង់ត្រាស់ថា

**នត្ថិ សន្តិ បរំ សុខំ**

*ពុំមានសេចក្តីសុខដទៃ ក្រៅអំពីសេចក្តីស្ងប់ឡើយ ។*

